គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee for Cambodia
Comité de Coopération pour le Cambodge

# ការប្រឈមមុខក្នុងការរស់នៅរបស់ជនពិការ នៅតំបន់ជនបទ ក្នុងប្រទេសកម្ពុជា

## ការស្រាវជ្រាវអំពីជនពិការដែលមានបញ្ហាបំលាស់ទីនៅក្នុងបរិបទសង្គម

## ស្រុកព្រៃវែង ខេត្តព្រៃវែង



គំរោងវិភាគបញ្ហាអភិវឌ្ឍន៍ (ADI)

**សិក្ខាកាមអេឌីអាយជំនាន់ទី ១៦ និង អ្នកបណ្តុះបណ្តាល**

**ខែ មីនា ២០០៦**

# ការប្រឈមមុខក្នុងការរស់នៅរបស់ជនពិការ នៅតំបន់ជនបទ ក្នុងប្រទេសកម្ពុជា

## ការស្រាវជ្រាវអំពីជនពិការដែលមានបញ្ហាបំលាស់ទីនៅក្នុងបរិបទសង្គម
## ស្រុកព្រៃវែង ខេត្តព្រៃវែង


គំរោងវិភាគបញ្ហាអភិវឌ្ឍន៍ (ADI)

**សិក្ខាកាមអេឌីអាយជំនាន់ទី ១៦ និង អ្នកបណ្តុះបណ្តាល**



**ខែ មីនា ២០០៦**

# មាតិការឿង


សេចក្ដីថ្លែងអំណរគុណ ....................................................................................................៣

ខ្លឹមសារសង្ខេប ....................................................................................................៤

ការពិពណ៌នាអំពីបញ្ហា ....................................................................................................៥

ទិសដៅនៃការស្រាវជ្រាវ ....................................................................................................៦

សំនួរគន្លឹះនៃការស្រាវជ្រាវ ....................................................................................................៧

វិធីសាស្រ្តក្នុងការស្រាវជ្រាវ ....................................................................................................៨

ការស្វែងយល់ និងការគិតគូរចំពោះបញ្ហាពិការភាពនៅប្រទេសកម្ពុជា.......................................................៩

    ការស្វែងយល់អំពីប្រភេទពិការភាព.......................................................................................៩

    ការឆ្លើយតបទៅនឹងការប្រឈមមុខនៃបញ្ហាពិការភាព.............................................................១៥

ការវិភាគលទ្ធផលរកឃើញពីការធ្វើអង្កេតនៅតំបន់ជនបទ ..............................................................២៤

    មូលហេតុ និងផលវិបាករបស់ជនពិការដែលមានបញ្ហាផ្នែកបំលាស់ទី .....................................២៤

    ការប្រកបមុខរបរចិញ្ចឹមជីវិតរបស់គ្រួសារដែលមានសមាជិកពិការ .....................................២៩

    ការរើសអើង និងកង្វះការរាប់រកនៅក្នុងសង្គម ..............................................................៣៤

    ជំនួយ និងសេវាកម្មដែលពួកគេទទួលបាន ..................................................................................៤០

សេចក្ដីសន្និដ្ឋាន ....................................................................................................៤២

ឧបសម្ព័ន្ធ: ....................................................................................................៤៥

    បញ្ជីសំណួរស្រាវជ្រាវ ..........................................................................................................៤៥

    បញ្ជីឈ្មោះសិក្ខាកាម និងក្រុមអេឌីអាយ ....................................................................................៧០

ឯកសារស្រាវជ្រាវរបស់គំរោងអេឌីអាយ .......................................................................................៧១

# សេចក្តីថ្លែងអំណរគុណ

ក្រុមអេឌីអាយ និងសិក្ខាកាម សូមសំដែងនូវការដឹងគុណចំពោះជនពិការ និងគ្រួសាររបស់ពួកគេ នៅស្រុកព្រៃវែង ដែលបានចូលរួមផ្តល់ពតិមានក្នុងការស្រាវជ្រាវនេះ ។ ក្រុមអ្នកស្រាវជ្រាវក៏សូមថ្លែងអំណរគុណចំពោះលោកស្រី ចូសេហ្វីណា ម៉ាក់ខិនឌ្រូ លោកហ៊ត សីលា លោកស្រី ខ្លូឌី អ៊ុង និងលោក អ៊ុល ម៉េងហ៊ាវ ធ្វើការនៅអង្គការអតីតយុទ្ធជនអន្តរជាតិ ដែលបានផ្តល់ការគាំទ្រយ៉ាងពេញទំហឹងដល់ការសិក្សាស្រាវជ្រាវនេះ ព្រមទាំងបានផ្តល់នូវបញ្ជីឈ្មោះរបស់ជនពិការដែលរស់នៅក្នុងស្រុកព្រៃវែងផងដែរ ។ យើងខ្ញុំក៏សូមថ្លែង អំណរគុណផងដែរ ចំពោះលោក ឃុត ឈុនលី និង លោក គង់ ធឿន មន្រ្តីមកពីនាយកដ្ឋានសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត ចំពោះការសំរបសំរួលនៅពេលបំពេញការងារនៅមូលដ្ឋាន។ អ្នកស្រាវជ្រាវក៏សូមអរគុណផងដែរដល់ លោក វុន សុថាន ដែលបានជួយបកប្រែបញ្ជីសំនួរ និងការចុះតាមមូលដ្ឋាន ព្រមទាំងអរគុណដល់ លោក ថា សុផល បុគ្គលិកអង្គការ ស៊ីស៊ីស៊ី ដែលបានដឹកជញ្ជូន និងរៀបចំភស្តុភា សំរាប់វគ្គទាំងមូល ។ ចំពោះទស្សនៈ និងគំនិតនានានៅក្នុងរបាយការណ៏ស្រាវជ្រាវនេះ ជាការទទួលខុសត្រូវទាំងស្រុងរបស់អ្នកនិពន្ធ ។

រូបថតនៅលើក្របរបាយការណ៏នេះ គឺទទួលបានពីអង្គការអតីតយុទ្ធជនអន្តរជាតិ។

# ខ្លឹមសារសង្ខេប

ការស្រាវជ្រាវរបស់ក្រុមអេឌីអាយគឺ ពិនិត្យទៅលើការលំបាកដែលជនពិការជួបប្រទះក្នុងការបំលាស់ទី នៅស្រុកព្រៃវែង ខេត្តព្រៃវែង បានជួបប្រទះ ។ ជាពិសេសទៅទៀត ការសិក្សានេះមាន គោលបំណងចង់ពិនិត្យមើលទៅលក្ខណៈទូទៅខ្លះទាក់ទងនឹងយេនឌ័រ និងអាយុជនពិការ មូលហេតុនៃពិការភាព ផលប៉ះពាល់ទៅលើការផ្លាស់ទីរបស់គេ និងផលវិបាកមកលើគ្រួសារ ។ យើងក៏បានពិនិត្យមើលផងដែរ នូវស្ថានភាពជីវភាពក្នុងគ្រួសាររបស់គេស្វែងរកនូវបញ្ហាទាក់ទងនឹងការរើសអើង ការមិនយកចិត្តទុកដាក់ក្នុងសង្គម ព្រមទាំងប៉ាន់ប្រមាណនូវសេវាកម្ម និងជំនួយផ្សេងៗ ដែលបានផ្តល់ដោយរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលនានា។

ជារួម បុព្វហេតុសំខាន់នៃពិការភាព ក្នុងចំណោមអ្នកដែលត្រូវបានធ្វើអង្កេតគឺ ជំងឺរោគា ហើយដែលភាគច្រើននៃបញ្ហានេះ សុទ្ធតែអាចទប់ស្កាត់បាន ។ ទោះបីថា គ្រឿងទ្រទ្រង់រាងកាយបានផ្តល់ជាប្រយោជន៏ច្រើន តែលទ្ធភាពបំលាស់ទីកាន់តែឆ្ងាយ មានកំរិតធ្លាក់ចុះគួរកត់សំគាល់ ។ គ្រួសារដែលមានជនពិការភាគច្រើន មានការខ្វះខាតដីធ្លី និងធ្វើស្រែបានទិន្នផលទាប ។ ចំពោះការមិនអើពើពីសង្គមមានច្រើនរូបភាពដូចជា ការហៅឈ្មោះតាមប្រភេទនៃពិការភាព ឥរិយាបថធ្វើត្រាប់តាម កំរិតចូលសាលារៀននៅទាប ការរើសអើងក្នុងការជ្រើសរើសគូស្រករ និងការចូលរួមក្នុងការងារអភិវឌ្ឍន៏សហគមន៏ ក៏នៅក្នុងកំរិតទាបដែរ ។ ក្នុងចំណោមជនពិការ ៤0% ដែលបានទទួលជំនួយ ស្ទើរតែទាំងអស់គ្នាបានទទួលពីអង្គការអតីតយុទ្ធជនអន្តរជាតិ (វីអាយ) ។ ជាទូទៅ វិស័យពិការភាពពេលបច្ចុប្បន្នដែលស្ថិតនៅក្រៅរង្វង់នៃការអភិវឌ្ឍន៏ទ្រង់ទ្រាយធំ ជាប្រថ្នូលមិនល្អសំរាប់ជនពិការ នៅតំបន់ជនបទក្នុងប្រទេសកម្ពុជា នាពេលអនាគតនោះទេ ។ ដូច្នេះ សូមអំពាវនាវអោយមានការរួមកម្លាំងគ្នាអោយបានកាន់តែខ្លាំងឡើង ដើម្បីធានាអោយជនពិការបានចូលរួមយ៉ាងសកម្ម នៅក្នុងកម្មវិធីជាតិកាត់បន្ថយភាពក្រីក្រ និងធានាអោយពួកគេបានរស់នៅ ក្នុងនាមជាពលរដ្ឋពេញសិទ្ធិ ដូចពលរដ្ឋកម្ពុជាគ្រប់រូបដែរ ។

# ការប្រឈមមុខក្នុងការរស់នៅរបស់ជនពិការនៅតំបន់ជនបទក្នុងប្រទេសកម្ពុជា
## ការស្រាវជ្រាវអំពីជនពិការដែលមានបញ្ហាបំលាស់ទីនៅក្នុងបរិបទសង្គម
## ស្រុកព្រៃវែង ខេត្តព្រៃវែង

## ការពិពណ៌នាបញ្ហា

នៅក្នុងខែ កុម្ភៈ ឆ្នាំ ២០០៦ ធនាគាពិភពលោក បានបញ្ចប់ការវាយតំលៃភាពក្រីក្រសំរាប់រាយការណ៏នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់[១] ។ ការសិក្សាវាយតំលៃនេះ គឺជារបាយការណ៏មួយមានគុណភាពខ្ពស់ ដែលរៀបរាប់អំពីនិន្នាការនៃភាពក្រីក្រកាលជាងមួយទសវត្សរ៍ និងពិនិត្យទៅលើប្រភេទនៃភាពក្រីក្រយ៉ាងលំអិត ។ របាយការណ៏ក៏បានពិនិត្យផងដែរនូវផលវិបាកនៃភាពក្រីក្រចំពោះក្រុមមនុស្សដូចជា ក្រុមស្ត្រី ក្រុមជនជាតិដើមភាគតិច និងអ្នកក្រីក្រនៅតាមទីប្រជុំជន ។ ទោះជាគ្មានការសិក្សាស្រាវជ្រាវណាមួយដែលគេគិតថា នឹងអាចរៀបរាប់គ្រប់រឿងទាំងអស់នៃភាពក្រីក្រក្តី តែយ៉ាងហោចណាស់ក៏គេគួរតែបានលើកខ្លះៗអំពីតំរូវការពិសេស និងការប្រឈមមុខសំខាន់ៗរបស់ជនពិការ នៅក្នុងការសិក្សាវាយតំលៃដ៏ធំរបស់ធនាគារពិភពលោកនេះដែរ ។

ចំពោះការសិក្សាស្រាវជ្រាវរបស់នាយកដ្ឋានអភិវឌ្ឍន៏អន្តរជាតិរបស់ចក្រភពអង់គ្លេសថ្មីៗនេះអំពី *ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៏នៅប្រទេសកម្ពុជា: ការលើកកំពស់ជនពិការដើម្បីអោយមានតួនាទី* បានលើកឡើងថា ការឃើញមានវត្តមាននៃជនពិការច្រើននាក់នៅកម្ពុជា ព្រមទាំងឃើញមានការការយកចិត្តទុកដាក់របស់អន្តរជាតិទៅលើបញ្ហាមីន បានធ្វើអោយមានការយល់ច្រឡំថា បញ្ហាជនពិការត្រូវបានគេគិតគូរយ៉ាងខ្លាំងរួចទៅហើយ តែជាក់ស្តែងមិនដូច្នោះទេ។ ការសិក្សាស្រាវជ្រាវរកឃើញថា ភាគច្រើននៃជនពិការនៅប្រទេសកម្ពុជា គឺជាអ្នកដែលក្របំផុតនៅក្នុងប្រទេស ហើយមានឱកាសតិចក្នុងការចាកផុតពីភាពក្រីក្រ ជាងអ្នកដែលក្រដែលមិនពិការ ។ ការសិក្សាបានជំរុញអ្នករៀបចំគោលនយោបាយបង្កើនការផ្សព្វផ្សាយ និងការយល់ដឹងអោយកាន់តែប្រសើរឡើងអំពីពិការភាពនៅកម្ពុជា ព្រមទាំងទំនាក់ទំនងនៃបញ្ហាពិការភាពជាមួយភាពក្រីក្រ ។ នៅក្នុងសេចក្តីសន្និដ្ឋានរបាយការណ៏បានវែកញែកថា ការជឿនលឿនទៅមុខក្នុងការកាត់បន្ថយភាពក្រីក្រនៃប្រទេសកម្ពុជា មិនអាចកើតឡើងបានទេ បើគ្មានការខិតខំប្រឹងប្រែងក្នុងការបញ្ជ្រាបចូលវិស័យពិការភាពទៅក្នុងការអភិវឌ្ឍន៏ក្នុងទ្រង់ទ្រាយធំទេនោះ ហើយក៏ត្រូវដកចេញរបាំងដែលរាំងការចូលរួមពេញលេញរបស់ជនពិការគ្រប់រូបក្នុងសង្គមផងដែរ[២] ។

---

[1] Tim Conway and Chorching Goh, Task Team Leaders, *កម្ពុជា: ភាពក្រីក្រអាចបន្ថយពាក់កណ្តាលបានទេនាឆ្នាំ ២០១៥?* (Phnom Penh: World Bank, February 2006). គួរកត់សំគាល់ដែរថា *សេចក្តីថ្លែងការរបស់អង្គការមិនមែនរដ្ឋាភិបាលចំពោះកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីកម្ពុជានៅឆ្នាំ ២០០៦នេះ* មិនបានបញ្ចូលសាច់រឿងនៃវិស័យមួយគឺ ពិការភាព និងការស្តារលទ្ធភាពពលកម្ម តែប៉ុន្មានឆ្នាំកន្លងទៅ ធ្លាប់មានលើកឡើងពីបញ្ហានេះដែរ ។ សូមមើល *NGO Statement to the Consultative Group Meeting on Cambodia, (Phnom Penh: NGO Forum on Cambodia, March 2006).*

[2] Philippa Thomas, *Poverty Reduction and Development in Cambodia: Enabling Disabled People to Play a Role,* (United Kingdom: Department for International Development, April).

អង្គការអតីតយុទ្ធជនអន្តរជាតិ (វីអាយ) (VI) គឺជា អង្គការមួយក្នុងចំណោមអង្គការអន្តរជាតិចំនួន៥ ដែលកំពុងដំណើការមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មមួយចំនួននៅកម្ពុជា ។ មជ្ឈមណ្ឌលវីអាយនៅខេត្តព្រៃវែង ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៥ ហើយបានជួយជនពិការដែលមានបញ្ហាបំលាស់ទី មកពីខេត្តព្រៃវែង និងស្វាយរៀង។ ដោយសារស្រុកព្រៃវែងស្ថិតនៅជិតមជ្ឈមណ្ឌលស្តាលទ្ធភាពពលកម្មរបស់អង្គការវីអាយ ទើបស្រុកព្រៃវែង ត្រូវបានជ្រើសរើស ហើយចាត់ទុកថា ជាទីតាំងដែលមានរឿងរ៉ាវពិសេស សំរាប់ធ្វើការសិក្សាស្រាវជ្រាវអំពី ឧបសគ្គដែលប្រឈមមុខចំពោះជនពិការនៅតំបន់ជនបទ នៃប្រទេសកម្ពុជា ។ តាមពិត ស្ថានភាពជនពិការនៅតាមតំបន់ជនបទដែលមិនបានទទួលនូវសេវាស្តារលទ្ធភាពពលកម្ម ពិតជារឿងមួយគួរអោយសង្វេកណាស់។

ការស្រាវជ្រាវរបស់ក្រុមអេឱអាយគឺ ពិនិត្យលើការលំបាករបស់ជនពិការដែលមានបញ្ហាក្នុងការបំលាស់ទី នៅស្រុកព្រៃវែង ខេត្តព្រៃវែង បានជួបប្រទះ ។ ជាពិសេសទៅទៀត ការសិក្សានេះមាន គោលបំណងចង់ពិនិត្យមើលទៅលក្ខណៈទូទៅខ្លះទាក់ទងនឹងយេនឌ័រ និងអាយុជនពិការ មូលហេតុនៃពិការភាព ផលប៉ះពាល់ទៅលើការផ្លាស់ទីរបស់គេ និងផលវិបាកមកលើគ្រួសារ ។ យើងក៏បានពិនិត្យមើលផងដែរ នូវស្ថានភាពជីវភាពក្នុងគ្រួសាររបស់គេ ស្វែងរកនូវបញ្ហាទាក់ទងនឹងការរើសអើង ការមិនយកចិត្តទុកដាក់ក្នុងសង្គម ព្រមទាំងប៉ាន់ប្រមាណនូវសេវាកម្ម និងជំនួយផ្សេងៗ ដែលបានផ្តល់ដោយរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលនានា។

## ទិសដៅនៃការស្រាវជ្រាវ

- ពិនិត្យមើលមូលហេតុ និងផលវិបាករបស់ជនពិការដែលមានបញ្ហាបំលាស់ទី ។
- ដើម្បីស្វែងយល់អំពីស្ថានភាពជីវភាព និង ការចិញ្ចឹមជីវិតរបស់ក្រុមគ្រួសារដែលមានសមាជិកពិការមានបញ្ហាបំលាស់ទី។
- កំណត់រកបញ្ហាទាក់ទងទៅនឹងការមិនយកចិត្តទុកដាក និង ការរើសអើងពីសង្គមដែលជនពិការមានបញ្ហាបំលាស់ទី ធ្លាប់បានជួបប្រទះ ។
- ប៉ាន់ប្រមាណទៅលើជំនួយ និងសេវាកម្មដែលជនពិការបានទទួល យោងតាមសិទ្ធិរបស់ពួកគេ ។

## សំណួរគន្លឹះនៃការស្រាវជ្រាវ

### បុព្វហេតុ និងផលវិបាករបស់ជនពិការដែលមានបញ្ហាបំលាស់ទី

តើអ្នកពិការរាងកាយមានភេទប្រុស ឬស្រី ហើយមានអាយុប៉ុន្មាន? តើមានមូលហេតុជាទូទៅអ្វីខ្លះ? តើពួកគេធ្លាក់ខ្លួនពិការអស់រយៈពេលប៉ុន្មានឆ្នាំហើយ?

តើពិការភាពជះឥទ្ធិពលដូចម្តេចដល់ការបំលាស់ទី? តើជនពិការអាចថែទាំខ្លួនឯងបានក៏រិតណា? អាចផ្លាស់ទីជុំវិញផ្ទះ និងអាចទៅផ្ទះអ្នកជិតខាងបានទេ? អាចទៅវត្ត និងផ្សារបាន? អាចទៅសាលាឃុំ និង ទីរួមខេត្តបានទេ? តើជនពិការពឹងផ្អែកទៅលើឧបករណ៍ជំនួយក៏រិតណា? តើឧបករណ៍ទទួលបានពី NGO ឬរដ្ឋាភិបាល?

តើពិការពិបាកក្នុងការផ្លាស់ទីមានផលវិបាកអ្វីខ្លះដល់គ្រួសារនៅជនបទ? តើគេមានកំលាំងពលកម្ម គ្រប់គ្រាន់ដើម្បីទ្រទ្រង់គ្រួសារ និងថែទាំជនពិការទេ? តើគេមានខ្ចីលុយអ្នកដទៃរហូតដល់ជាប់បំណុលគេទេ? តើពួកគេមានលក់ដី ឬទ្រព្យសម្បត្តិទេ?

### ការប្រកបមុខរបរចិញ្ចឹមជីវិត

តើគ្រួសារជនពិការធ្វើស្រែប៉ុន្មានហិកតា? តើពួកគេមានដីជាកម្មសិទ្ធិ ឬជួលប៉ុន្មានហិកតា? តើមានប៉ុន្មានគ្រួសារដែលគ្មានដី? តើមានប៉ុន្មានគ្រួសារដែលបានលក់ ឬបញ្ចាំដី? តើការធ្វើស្រែបានផ្តល់ទិន្នផលក្នុងក៏រិតណា? តើទិន្នផលស្រូវបានបំពេញទៅតាមតម្រូវការទេ? តើជនពិការបានចូលរួមក្នុងការងារធ្វើស្រែចំការក្នុងក៏រិតណា?

ក្រៅពីការធ្វើស្រែចំការ តើគ្រួសារជនពិការមានប្រភពចំណូលសំខាន់ៗអ្វីខ្លះទៀត? តើសមាជិកគ្រួសារដែលពិការបានជួយក្នុងការរកចំណូលដែរឬទេ? តើសមាជិកគ្រួសារដែលពិការ បានជួយក្នុងការងារមិនបានប្រាក់កម្រៃ (ការងារក្នុង និងក្បែរផ្ទះ) បានក៏រិតណា?

### ការមិនយកចិត្តទុកដាក់ និងរើសអើងក្នុងសង្គម

តើជនពិការទទួលរងនូវការរើសអើងពីសង្គមទេ? តើរើសអើងបែបណា? ត្រូវបានគេហៅឈ្មោះទៅតាមពិការភាព និងធ្វើកំប្លែងលែងទេ? រើសអើងក្នុងការចូលរៀន? តើពួកគេអាចជ្រើសរើសគូរស្រករ និងរៀបចំគ្រួសារបានទេ? តើពួកគេអាចបោះឆ្នោតបានទេ? តើមានភាពខុសគ្នាបែបណាខ្លះចំពោះ ការរើសអើងរវាងបុរសពិការ និងស្ត្រីពិការ? រវាងកុមារពិការ និងមនុស្សចាស់ពិការ?

តើជនពិការមានការប្រាស្រ័យទាក់ទងគ្នាជាមួយអ្នកដទៃក្រៅពីសមាជិកគ្រួសារទេ?តើអ្នកដទៃមកលេងជនពិការញឹកញាប់ទេ? តើជនពិការទៅលេងអ្នកដទៃញឹកញាប់ទេ? តើជនពិការចូលរួមក្នុងពិធីបុណ្យ និងសកម្មភាពអភិវឌ្ឍន៍ផ្សេងៗ នៅសហគមន៍ក៏រិតណា? តើការចូលរួមនេះមានភាពខុសគ្នាឬទេ រវាងបុរសពិការ និងស្ត្រីពិការ?

### ការផ្តល់ជំនួយដល់ជនពិការដែលពិបាកក្នុងការផ្លាស់ទី

តើមានជនពិការប៉ុន្មាននាក់ដែលបានទទួលជំនួយ សំរាប់ពិការភាពរបស់គេ? ប្រភេទនៃជំនួយអ្វីខ្លះ? អ្នកណាជាអ្នកអោយ? ស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ? អង្គការ វីអាយ? អង្គការផ្សេងៗ? តើជំនួយមានប្រយោជន៍ឬយ៉ាងណា? នៅតែបន្តផ្តល់ឬយ៉ាងណា?

## វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាត្រូវបានធ្វើនៅក្នុងភូមិចំនួន ២៣ ក្នុងឃុំចំនួន ៦ ក្នុងស្រុកព្រៃវែង កាលពីថ្ងៃទី ២២ ដល់ ថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០០៥ ។ ឃុំទាំង៦នេះគឺ ឃុំអង្គរទ្រេត ដរីពួន ព្រៃខ្លា ស្វាយអន្ទរ មេបុណ្យ និងពពឹស ។ អង្គការអតីតយុទ្ធជនអន្តរជាតិ (VI) បានផ្តល់បញ្ជីឈ្មោះក្រុមគោលដៅរបស់គេនៅតាមភូមិទាំងនេះ ហើយបញ្ជីនោះ ត្រូវបានកែសំរួលជាមួយនឹងប្រធានភូមិ ដោយមានបញ្ចូលឈ្មោះជនពិការពិបាកបំលាស់ទីផ្សេងទៀតដែលគេស្គាល់នៅតាមភូមិនីមួយៗ ។ ឈ្មោះទាំងនេះជាចំនួនដែលផ្តល់លទ្ធភាពអោយក្រុមស្រាវជ្រាវជ្រើសរើសសំរាប់ធ្វើសំភាសន៍តាមរយៈបញ្ជីសំណួរ ហើយនៅទីបញ្ចប់ យើងបានសំភាសន៍ក្រុមគ្រួសារចំនួន ១៣៧ គ្រួសារ ដែលក្នុងមួយគ្រួសារមានសមាជិកម្នាក់ជាជនពិការ ។

បន្ថែមទៅលើបញ្ជីសំណួរអង្កេត ក៏មានការសំភាសន៍បុគ្គលសំខាន់ៗផងដែរគឺ ជាមួយនឹងបុគ្គលិករបស់អង្គការ VI ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនិតិសម្បទានៃខេត្តព្រៃវែង ប្រធានមន្ទីរសុខាភិបាលខេត្តព្រៃវែង តំណាងអង្គការភាពជាដៃគូនៃអភិបាលកិច្ចមូលដ្ឋានប្រចាំខេត្តព្រៃវែង (PLG) មេឃុំចំនួន ៣ នាក់ ប្រធានភូមិចំនួន ៦ នាក់ ហើយនិងការសំភាសន៍លំអិតជាមួយជនពិការមួយចំនួនទៀត ។

# ការស្វែងយល់ និងការគិតគូរចំពោះបញ្ហាពិការភាពនៅប្រទេសកម្ពុជា

ទោះបីបញ្ហាពិការភាព និងជាពិសេសអ្នករស់រានមានជីវិតពីគ្រោះថ្នាក់ដោយសារមីន បានក្លាយទៅជានិមិត្តរូបនៃកេរ្តិ៍ដំណែលនៃជម្លោះ/សង្គ្រាមនៅក្នុងប្រទេសកម្ពុជាក្តី ក៏ការផ្សព្វផ្សាយអំពីប្រភេទនៃពិការភាពគឺ ទើបតែកំពុងលេចចេញរូបរាងប៉ុណ្ណោះ។ ផ្នែកនេះធ្វើការពិនិត្យមើលទៅលើការប្រើប្រាស់ និងខ្លឹមសារនៃពាក្យ "ពិការភាព" ព្រមទាំងទំនាក់ទំនងរបស់វាទៅនឹងភាពក្រីក្រ និងការមិនអើពើពីសង្គម។ ផ្នែកនេះ ក៏ពិនិត្យមើលផងដែរទៅលើការបកស្រាយឡើងវិញអំពី សញ្ញាណនៃពាក្យនេះដែលមានឥទ្ធិពលទៅលើកម្មវិធីអភិវឌ្ឍន៍នានា។

## ការស្វែងយល់អំពីប្រភេទនៃពិការភាព

ចំនុចសំខាន់មុននឹងចាប់ផ្តើមធ្វើការសិក្សាពីវិស័យពិការភាពគឺ ការបំបែកអត្ថន័យនៃពាក្យនេះ និងការឱ្យនិយមន័យឡើងវិញទៅតាមស្ថានភាពសង្គម ជាជាងបុគ្គល[3]។ ភាពបត់បែននៃការគិតនេះ ធ្វើអោយមានការបែងចែកយ៉ាងច្បាស់រវាងអត្ថន័យនៃពាក្យពីរម៉ាត់គឺ “Impairment” (ភាពអន់ខ្សោយសរីរាង្គ ឬអ្នកដែលមានបញ្ហាបំលាស់ទី) និងពាក្យ “Disability” (ពិការភាព)។ ពាក្យ "Impairment" ត្រូវបានអោយនិយមន័យថា ជាលក្ខខ័ណ្ឌដែលមានក្នុងខ្លួនរបស់បុគ្គលម្នាក់ដែលលក្ខខ័ណ្ឌនោះ រារាំងដល់សមត្ថភាពរបស់បុគ្គលក្នុងការធ្វើអ្វីមួយ។ ផ្ទុយទៅវិញ ពាក្យ "Disability" ត្រូវគេអោយនិយមន័យថា ជាលទ្ធផលនៃការប្រាស្រ័យទាក់ទងរបស់មនុស្សដែលអន់ខ្សោយខាងសរីរាង្គ ជាមួយនឹងបរិកាសសង្គម និង រូបវ័ន្ត ។ ឧទាហរណ៏ អ្នកអន់ខ្សោយខាងសរីរាង្គគឺជា អ្នកទទួលរងទុក្ខដោយសារមានលក្ខខ័ណ្ឌកំណត់ដែលមានជាប់នឹងខ្លួនគេផ្ទាល់។ តែជនពិការវិញ គឺជាមនុស្សដែលមិនត្រូវបានគេរាប់រក ឬត្រូវបានគេរើសអើងដោយសារ ភាពអន់ខ្សោយខាងសរីរាង្គរបស់ពួកគេ។ ដូច្នេះ ពិការភាពគឺ មិនមែនមានជាប់មកជាមួយនឹងខ្លួនរបស់គេផ្ទាល់នោះទេ។ សង្គមបានបង្កឱ្យអ្នកអន់ខ្សោយខាងសរីរាង្គក្លាយទៅជាមនុស្សពិការ ព្រោះសង្គមមិនបានទទួលស្គាល់ និងជួយសំរួលដល់ភាពខុសប្លែកពីគេឯងដែលពួកគេមាននោះទេ ហើយរបាំងឧបសគ្គទាំងនេះមាន ឥរិយាបថ បរិយាកាសទូទៅ និងស្ថាប័ន។ ការរើកញែកខាងលើនេះ ធ្វើអោយគេកំណត់និយមន័យ និងបកស្រាយខ្លឹមសារនៃពិការភាព ថាជា បញ្ហាសង្គម និងបញ្ហាអភិវឌ្ឍន៍។

នៅក្នុងប្រទេសកម្ពុជា ពុំមានស្ថិតិពិតប្រាកដទាក់ទៅនឹងពិការភាពនៅឡើយទេ ។ ការប៉ាន់ប្រមាណអត្រានានារបស់ជាតិមានភាពខុសគ្នាយ៉ាងខ្លាំង។ នៅឆ្នាំ ២០០៣ វិទ្យាស្ថានជាតិស្ថិតិ (NIS) បានរាយការណ៏ថា មានជនពិការចំនួន ១៧០.០០០ នាក់ នៅក្នុងប្រទេស ឬ ស្មើនឹង ១.៥%នៃចំនួនប្រជាពលរដ្ឋទាំងអស់។ បើប្រៀបធៀបជាមួយតួលេខរបស់អង្គការសហប្រជាជាតិទទួលបន្ទុកការងារជនពិការ នៅឆ្នាំ ១៩៩៩ បានបង្ហាញថា មានជនពិការសរុប

---

[3] See Thomas, *Poverty Reduction and Development in Cambodia and Asian Development Bank, Disability Brief: Identifying and Addressing the Needs of Disabled People*, (Manila: Asian Development Bank, 2005).

មួយលានបួនសែននាក់ នៅប្រទេសកម្ពុជា គឺស្មើនឹង ១៥% នៃចំនួនប្រជាពលរដ្ឋទាំងអស់[៤] ។ យោងតាមការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា (CSES) ឆ្នាំ១៩៩៧ បានឱ្យដឹងថា បុព្វហេតុចំបងនៃពិការភាពដែលកើតមានញឹកញាប់ជាងគេគឺ ជំងឺ និងរោគា ពិការពីកំណើត គ្រោះថ្នាក់ផ្សេងៗ ជំលោះនិងសង្គ្រាម និងកត្តាគ្រាប់មីន។ នៅឆ្នាំ២០០២ ក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) បានបង្ហាញឱ្យឃើញថា នៅក្នុងខេត្តកំពង់ស្ពឺ ប្រភេទពិការដែលមានច្រើនជាងគេគឺ ពិការអវយវៈ ក្រៅពីនោះមានបញ្ហាភ្នែក និងត្រចៀក។ កង្វះខាតស្ថិតិផ្នែកបញ្ហាពិការភាពនេះ បានឆ្លុះបញ្ចាំងអោយឃើញ និងជំរុញអោយកាន់តែមានការមិនអើពើដល់ជនពិការថែមទៀត។

ទោះបីថា ពុំមានការអង្កេតស្រង់ទិន្នន័យជាមូលដ្ឋានដែលគួរអោយជឿជាក់បានសំរាប់យកមកធ្វើការប្រមាណអំពីនិន្នាការក្តី គេគិតថា អត្រានៃជនពិការនៅកម្ពុជានឹងកើនឡើងជាមិនខាន។ គេបានលើកឡើងថា កត្តាប្រជាសាស្រ្ត សុខភាព និង អភិវឌ្ឍន៏ គឺជាមូលដ្ឋានសំរាប់យកមកធ្វើការព្យាករណ៏អំពីកំណើន។ កត្តាលំអិតជាក់ស្តែងរួមមាន ១)-កើនអាយុកាល រួមផ្សំនឹងអត្រាពិការភាពខ្ពស់ក្នុងចំណោមមនុស្សចាស់ ២)-ការកាត់បន្ថយមរណភាពមាតា និងទារក អាចនាំឱ្យមានការរស់រានមានជីវិតរបស់ជនពិការច្រើន ៣)-កង្វះអាហារូបត្ថម្ភជាប្រចាំ (រួមមានកង្វះវីតាមីន A) ព្រមទាំងមានជំងឺរុំារ៉ៃ ៤)-របួសស្នាមផ្សេងៗ បណ្តាលមកពីគ្រោះថ្នាក់ចរាចរ និងក្នុងពេលបំពេញការងារ និងគ្រោះថ្នាក់ដោយសារគ្រាប់មីន ៥)-កង្វះខាតក្នុងការទទួលបានការថែទាំសុខភាពបឋម ការប្រើប្រាស់ទឹកស្អាត និងអនាម័យ[៥] ។

## *ពិការភាព និង ភាពក្រីក្រ*

ភាពក្រីក្រគឺមិនអាចផ្តាច់ចេញពីពិការភាពបានទេ ដោយសារតែបញ្ហាទាំង២ គឺជាមូលហេតុផង និងផលវិបាកផង។ ចំពោះមូលហេតុគឺសំដៅទៅលើ លក្ខខ័ណ្ឌនៃភាពក្រីក្រ ជាការបន្ថែមភាពគ្រោះថ្នាក់ដល់ពិការភាព។ តាមលទ្ធផលនៃការធ្វើអង្កេតទៅលើឯកសារនានាអំពីបញ្ហាភាពក្រីក្រ និងពិការភាព ធ្វើឡើងដោយធនាគារពិភពលោក បានបង្ហាញអោយឃើញថា គ្រួសារក្រីក្រមិនមានម្ហូបអាហារគ្រប់គ្រាន់ ខ្វះអនាម័យ និងមិនបានទទួលបាននូវសេវាថែទាំសុខភាពសមរម្យ។ ពួកគេរស់នៅក្នុងលំនៅដ្ឋានដែលមិនសូវល្អ ហើយធ្វើការងារដែលប្រកបដោយគ្រោះថ្នាក់ច្រើន ។ កង្វះអាហារូបត្ថម្ភដែលកើតឡើងពីភាពក្រីក្រ ជួនកាលបណ្តាលអោយមានពិការភាព និងធ្វើឱ្យកាន់តែងាយនឹងឆ្លងជំងឺដែលអាចនាំឱ្យពិការបាន ។ ម្តាយដែលខ្វះអាហាររូបត្ថម្ភនាំឱ្យទារកដែលកើតមកមានទំងន់មិនគ្រប់គ្រាន់ ហើយអាចនាំឱ្យទារកនោះ កាន់តែប្រឈមមុខទៅនឹងការកើតជំងឺដែលនាំឱ្យទន់ខ្សោយជាងទារកដែល

---

[4] The World Health Organization (WHO) estimates that disabled people make up approximately 10% of any society. The World Bank estimates that disabled people make up approximately 20% of the world' poorest. Cited in Rebecca Yeo, "To what extent are disabled people included in international development work? How can the barriers to inclusion be overcome?' A paper delivered at *Staying Poor*: *Chronic Poverty and Development Policy*, 7-9 April 2003, Manchester, UK

[5] Lorna Jean Edmonds, *Disabled People and Development*, (Manila: Asian Development Bank, June 2005).

មានសុខភាពល្អ។ កង្វះខាតការថែទាំសុខភាពប្រកបដោយប្រសិទ្ធិភាព អាចធ្វើឱ្យជំងឺកាន់តែខ្លាំងឡើងៗ ហើយដែលបណ្តាលអោយក្លាយទៅជាពិការភាពជាអចិន្ត្រៃយ៏បាន[៦] ។

ការស្រាវជ្រាវថ្មីៗដែលធ្វើឡើងនៅកម្ពុជា បានបង្ហាញថា ប្រជាជនក្រីក្រដែលដើរចូលក្នុងតំបន់ដែលមានគ្រាប់មីនដើម្បីរកអុស និងស្បៀងអាហារ ជាទូទៅគឺជាជនរងគ្រោះដោយសារគ្រាប់មីន ។ ប្រជាជនក្រីក្រភាគច្រើនគឺប្រឈមមុខនឹងការធ្វើដំណើរដែលពុំសូវមានសុវត្ថិភាព ហើយធ្វើការក្នុងស្ថានភាពគ្រោះថ្នាក់។ ប្រជាជនក្រីក្រដែលមានជំងឺ ឬរបួសស្នាម អាចនាំឱ្យមានពិការភាពអស់មួយជីវិត ដោយសារតែពួកគេពុំមានប្រាក់កាសសំរាប់យកទៅព្យាបាល។ ប្រជាជនក្រីក្រជាពិសេសកុមារ ក៏ប្រឈមមុខយ៉ាងខ្លាំងទៅនឹងកង្វះអាហាររូបត្ថម្ភដែលធ្វើអោយពួកគេ មានភាពទន់ខ្សោយដែរ[៧] ។

រីឯផលវិបាកវិញ លក្ខខ័ណ្ឌនៃពិការភាពបន្ថែមឥទ្ធិពលអាក្រក់ដល់ភាពក្រីក្រ។ ការអង្កេតរបស់ធនាគារពិភពលោកបានបង្ហាញថា អាត្រាពិការភាពខ្ពស់គឺទាក់ទងនឹងអនក្ខរភាពខ្ពស់ កង្វះអាហារូបត្ថម្ភ ការចាក់ថ្នាំបង្ការគ្របដណ្តប់បានក្នុងចំនួនតិច កូនដែលកើតមកមានទំងន់មិនគ្រប់ អាត្រាអ្នកអត់ការងារធ្វើ រីឯអ្នកមានការងារធ្វើតែទទួលបានប្រាក់ខែតិចគឺមានខ្ពស់ និងឱកាសតិចក្នុងការទទួលបានការតម្លើងឋានៈក្នុងការងារ[៨] ។ ការស្រាវជ្រាវថ្មីៗនេះរបស់ធនាគារអភិវឌ្ឍន៏អាស៊ីបានបង្ហាញថា ជនពិការគឺជាក្រុមមួយក្នុងចំណោមក្រុមប្រជាជនដែលក្រីក្រ និងងាយរងគ្រោះជាងគេបំផុតនៅក្នុងសង្គមកម្ពុជា។ ជាទូទៅ ជនពិការគឺជាជនក្រីក្របំផុត ក្នុងចំណោមជនក្រីក្រជាច្រើនហើយទទួលបាននូវសេវាក្នុង ក៏រិតទាបដូចជា សេវាសង្គមជាមូលដ្ឋាន ការអប់រំ ជំនាញ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ការទទួលបានការងារ និងឱកាសរកប្រាក់ចំណូល ហើយដែលបញ្ហានេះធ្វើឱ្យស្ថានភាពក្រីក្ររបស់គេកាន់តែមានភាពយ៉ាប់យ៉ឺនឡើង[9] ។

ជាទូទៅ ពិការភាព នាំឱ្យកើនឡើងនូវការចំណាយសំរាប់សុខភាព ហើយដែលនៅក្នុងប្រទេសកម្ពុជា វាជាប្រភពចំបងនៃការជំពាក់បំណុល បន្ទាប់មកក៏ឈានទៅដល់ការលក់ទ្រព្យសម្បត្តិរួមទាំងដីស្រែចំការផងដែរ។ ដូចគ្នានេះដែរ ភាពអន់ខ្សោយសរីរាង្គ អាចរារាំងដល់សមត្ថភាពរបស់ពួកគេក្នុងការបំពេញការងារ ជាពិសេសការងារធ្វើស្រែចំការ ហើយនេះជាការបាត់បង់នូវកំលាំងពលកម្ម និងកំលាំងរកប្រាក់ចំណូលនៅក្នុងគ្រួសារ ។ លើសពីនេះទៅទៀត តំរូវការក្នុងការផ្តល់ការថែទាំដល់សមាជិកគ្រួសារដែលពិការ អាចបង្អាក់ឱកាសរកចំណូលរបស់សមាជិក

---

6 Ann Elwan, *Poverty and Disability: A Survey of the Literature*, (Washington, DC: The World Bank, December 1999).
7 Thomas, *Poverty Reduction and Development in Cambodia.*
8 Elwan, *Poverty and Disability.*
9 Foundation for International Training and ADB Regional and Sustainable Development Department, *Disabled People and Development: Cambodia Country Report,* (Manila: Asian Development Bank, June 2005).

ដទៃទៀតនៅក្នុងគ្រួសារដែរ ។ ពិតប្រាកដណាស់គឺថា គ្រួសារដែល មានសមាជិកពិការមានកំរិតចំណូលក្រោមខ្សែបន្ទាត់នៃភាពក្រីក្រ ជាងគ្រួសារដែលមិនមានសមាជិកពិការ[១០] ។

ទោះជាយ៉ាងណាក៏ដោយ ពិការភាពភាគច្រើននៅកម្ពុជា ពិតជាអាចធ្វើការទប់ស្កាត់បាន ។ មានជនពិការប្រហែលពាក់កណ្តាលដែលបានធ្លាក់ខ្លួនបែបនេះ តាំងពីកំណើតមក ។ នៅក្នុងរបាយការណ៍សង្ខេបស្តីពី ពិការភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ីបានគូសបញ្ជាក់ពីសេចក្តីត្រូវការ ក្នុងការបង្កើនអោយមានកម្មវិធីការពារដែលអាចកាត់បន្ថយមូលហេតុដែលនាំឱ្យពិការដូចជា ការថែទាំមុននិងក្រោយពេលសំរាលកូន ការជួយក្នុងពេលសំរាលកូន ការផ្តល់អាហាររូបត្ថម្ភបានល្អ ការបរិភោគទឹកស្អាត អនាម័យ ការចាក់ថ្នាំបង្ការសុខភាព និងសុវត្ថិភាពការងារ និងការកសាងសន្តិភាព[១១] ។ ការលុបបំបាត់ភាពក្រីក្រគឺ ទំនងជាមិនអាចធ្វើទៅបានទេ បើសិទ្ធិ និងតំរូវការរបស់ជនពិការមិនត្រូវបានយកចិត្តទុកដាក់ទេនោះ[១២] ។ បើគេមិនចាត់ទុក បញ្ហាពិការភាព ជាបញ្ហាអភិវឌ្ឍន៍អាទិភាព និងមិនយកដាក់ជារបៀបវារៈដោយឡែក សំរាប់ការពិភាក្សាទេនោះ ស្ថានភាពដែលជនពិការកំពុងតែជួបប្រទះនឹងក្លាយជាឧបសគ្គរារាំង ចំពោះយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រជាមិនខានឡើយ[១៣] ។

## *ពិការភាព និងការមិនអើពើ*

អ្នកដែលអន់ខ្សោយក្នុងការបំលាស់ទី ត្រូវខិតខំពុះពារឧបសគ្គក្នុងការកសាងជីវិតរបស់ពួកគេ ។ ឧបសគ្គទាំងនោះរួមមាន ការទទួលបានទីជំរក និងបានទៅរៀនសូត្រ ការធ្វើស្រែចំការនិងការងារដទៃទៀត ព្រមទាំងពិបាកក្នុងការទទួលពត៌មាន និងទំនាក់ទំនង។ ឧបសគ្គដែលលើកឡើងមកនេះ ជាកត្តារារាំងជនពិការ មិនអាចចូលរួមសកម្មភាពក្នុងសង្គម និងសេដ្ឋកិច្ចបាន។ ទន្ទឹមនឹងពួកគេមានឧបសគ្គក្នុងការកសាងជីវិតយ៉ាងខ្លាំងក្លានោះ ពួកគេក៏ជួបនូវបញ្ហា ឥរិយាបថ និងរបាំងសង្គម ដែលកាន់តែធ្វើអោយមានភាពយ៉ាប់យ៉ឺនថែមទៀត។ ឧទាហរណ៍ទាក់ទងទៅនឹងឥរិយាបថ និងរបាំងសង្គមនៅប្រទេសកម្ពុជាគឺ ការហៅឈ្មោះ និង ការចំអកលេងសើចជាមួយជនពិការគឺជារឿងដែលកើតមានជាទូទៅ។ សមាជិកគ្រួសារ និងអ្នកជិតខាង ជាទំលាប់ហៅ ឈ្មោះក្មេងដែលពិការទៅតាមប្រភេទពិការជាជាងហៅឈ្មោះពិតរបស់គេ[១៤] ។ ការធ្វើបែបនេះ កាន់តែធ្វើអោយគេខ្វះការជឿជាក់លើខ្លួនគេ ហើយរឹតតែធ្វើអោយពួកគេស្ថិតនៅកាន់តែឯកោពីអ្នកដទៃ ។

---

[10] See Thomas, *Poverty Reduction and Development in Cambodia* and Elwan, *Povertry and Disability*
[11] Asian Development Bank, *Disability Brief*
[12] Foundation for International Training and ADB Regional and Sustainable Development Department, *Disabled People and Development*
[13] Edmonds, *Disabled People and Development*
[14] Thomas, *ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍នៅកម្ពុជា*

ការរើសអើងចំពោះជនពិការ ទោះបីធ្វើដោយចេតនា ឬអចេតនា ក៏ជាការនាំទៅរកការមិនអើពើពីសង្គមដែរ ។ ការស្រាវជ្រាវមួយនៅប្រទេសកម្ពុជាដែលបានធ្វើឡើង ដោយនាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិនៃចក្រភពអង់គ្លេស (DFID) បានរាយការណ៍ថា ជនពិការទាំងអស់ដែលបានសំភាសន៍ ធ្លាប់មានបទពិសោធន៍ក្នុងកំរិតណាមួយ នៃការនៅឯកោ និងការផាត់ចេញពីការចូលរួមនៅក្នុងពិធីផ្សេងៗនៅក្នុងសង្គម ។ ជនពិការទាំងនោះ បានរៀបរាប់ថា ពួកគាត់កម្រ ឬមិនដែលឃើញមានព្រះសង្ឃ ឬឧបាសក-ឧបាសិកានៅវត្តជិតខាង មកលេងនឹងគាត់ណាស់ ។ ពួកគាត់បន្ថែមថា គាត់មិនដែលត្រូវបានអញ្ជើញអោយចូលរួមក្នុងពិធីបុណ្យ ឬពិធីអាពាហ៍ពិពាហ៍ផ្សេងៗនោះទេ ។ ជាងនេះទៅទៀត ពួកគាត់បានត្អូញត្អែថា មិនដែលបានឃើញពីការជូនដំណឹង អំពីការប្រជុំភូមិ ឬក៏សកម្មភាពអភិវឌ្ឍន៍នានានោះទេ ។ ជនពិការមានកំរិតធ្ងន់ធ្ងរទាំងអស់ដែលបានសំភាសន៍ បានបញ្ជាក់ថា ពួកគេមិនត្រូវបានជូនដំណឹងពីការចុះឈ្មោះបោះឆ្នោតទេ[១៥] ។

ជាទូទៅជនពិការជាស្ត្រីភេទមានបញ្ហាពិបាកជាងជនពិការជាបុរស ។ ការសិក្សារបស់គណៈកម្មការសេដ្ឋកិច្ច-សង្គមទទួលបន្ទុកការងារអាស៊ី និងប៉ាស៊ីហ្វិករបស់អង្គការសហប្រជាជាតិ (ESCAP) បានពោលអះអាងថា បញ្ហាពិបាកនានាដែលក្មេងស្រីពិការបានជួបប្រទះគឺមានតាំងពីកំណើត ហើយបើក្មេងស្រីដែលពិការនោះ នៅមានជីវិតរស់ ពួកគេក៏ត្រូវទទួលរងការឈឺចាប់ដោយសារការរើសអើងក្នុងគ្រួសារ ទទួលបាននូវការថែរក្សា និងអាហារតិចតួច ហើយក៏មិនសូវបានប្រាស្រ័យទាក់ទងជាមួយសាច់សាលោហិត និងបំពេញការងារផ្សេងៗ ។ លើសពីនេះ កុមារីពិការក៏ទទួលបានមិនច្រើនដែរនូវការថែរក្សាសុខភាព និងសេវាស្តារលទ្ធភាពពលកម្ម ព្រមទាំងទទួលបាននូវឱកាសដ៏តិចតួច ក្នុងការរៀនសូត្រ និងមានការងារធ្វើ ។ ការស្រាវជ្រាវរបស់ ESCAP ក៏បានកត់សំគាល់ទៀតថា ស្ត្រីពិការមានការពិបាកជាងបុរសយ៉ាងខ្លាំងក្នុងការរើសគូស្រករៀបការ ហើយដែលជានិន្នាការនេះ ក៏ត្រូវបានគេសង្កេតឃើញមាន នៅក្នុងប្រទេសកម្ពុជាដែរ[១៦] ។

ជារួម សាលារៀន និងគ្រូបង្រៀនជាច្រើន នៅប្រទេសសកម្ពុជា មិនទាន់បានត្រៀមខ្លួនរួចជាស្រេចក្នុងការជួយបង្រៀនសិស្សដែលពិការទេ ។ សិស្សពិការតែងតែត្រូវបានដាក់ឱ្យនៅឆ្ងាយពីសាលា ដោយឪពុកម្តាយរបស់ពួកគេ ឬ ក៏ត្រូវបានគ្រូប្រាប់ មិនអោយមកចូលរៀន ។ ការមិនអើពើចំពោះកុមារពិការ និងយុវវ័យពិការក្នុងការអប់រំ គឺនាំមកនូវការបាត់បង់ឱកាសរបស់ពួកគេ ក្នុងការកសាងចំណេះដឹងបន្ថែមទៀត ធ្វើអោយថយចុះនូវលទ្ធភាពរបស់ពួគេ ក្នុងការចូលរួមក្នុងវគ្គបណ្តុះបណ្តាលជំនាញ ការរកការងារធ្វើ ព្រមទាំងបាត់នូវលទ្ធភាពរកប្រាក់ចំណូលទៀតផង ។ ការខកខានមិនបានទទួលនូវការសិក្សាអប់រំ និងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ គឺរាំងដល់ការចូលរួម

[15] Thomas, *ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍នៅកម្ពុជា*

[16] Economic and Social Commission for Asia and the Pacific (ESCAP), *Hidden Sisters: Women and Girls with disabilities in the Asian and Pacific Region,* (New York, United Nations, 1995) cited in Elwan, *Poverty and Disability.* See also Thomas*, Poverty Reduction and Development in Cambodia*

របស់កុមារពិការ និងយុវវ័យពិការនៅក្នុងសង្គមអោយបានពេញលេញ ហើយទីបំផុតគឺ ពួកគេនឹងងាយរងគ្រោះធ្លាក់ទៅក្នុងអន្ទាក់នៃភាពក្រីក្រ[១៧] ។

*ការគិតគូរឡើងវិញអំពី បញ្ហាពិការភាព*

ម៉ូដែលជាលក្ខណៈទ្រឹស្តីជាច្រើន ត្រូវគេលើកយកមកលាតត្រដាង ដើម្បីធ្វើការពិភាក្សាគ្នាអំពី បញ្ហាពិការភាព ហើយដែលម៉ូដែលទាំងនេះ បានផ្តល់នូវការវែកញែកផ្សេងៗពីគ្នាទៅលើប្រភេទនៃពិការភាព។ ការគិតគូរឡើងវិញជាបន្តបន្ទាប់អំពីពិការភាព នាំអោយគេរកឃើញនូវម៉ូដែលមួយចំនួនដូចជា **ម៉ូដែលមេត្តាធម៌ ម៉ូដែលវេជ្ជសាស្ត្រ ម៉ូដែលសង្គម និងម៉ូដែលសមភាពក្នុងនាមជាពលរដ្ឋ**[១៨] ។

ចំពោះម៉ូដែលមេត្តាធម៌គឺ សំដៅទៅលើ បញ្ហាពិការភាព ថាជារឿងសោកនាដកម្មរបស់បុគ្គល។ ដូច្នេះ មនុស្សដែលពិការ ត្រូវជាអ្នកដែលត្រូវតែមានការអាណិតអាសូរ ហើយត្រូវការជួយសង្គ្រោះ ការយកចិត្តទុកដាក់ និងការពារ។ ម៉ូដែលនេះលើកជាទស្សនៈថា មនុស្សពិការគឺ ត្រូវតែមានអ្នកជួយ ហើយនិងមើលឃើញថា ពួកគេគ្មានសមត្ថភាពក្នុងការក្លាយខ្លួនទៅជាសមាជិកនៃសង្គមក្នុងស្មារតីស្មើភាពគ្នា ឬក៏អាចជួយរួមចំណែកទាំងសេដ្ឋកិច្ច និងសង្គម នៅក្នុងការអភិវឌ្ឍន៍សហគមន៍របស់ពួកគេនោះទេ។

ចំពោះម៉ូដែលវេជ្ជសាស្ត្រវិញ សំដៅទៅលើភាពជឿនលឿនក្នុងវិស័យវិទ្យាសាស្ត្រ និងឧស្សាហកម្មផលិតឱសថទំនើបៗសំបូរបែប និងការបំពេញតួនាទីនៃអ្នកជំនាញវិជ្ជាជីវៈក្នុងវិស័យនេះដែលគេដឹងពីវិធីច្បាស់លាស់ ក្នុងការការពារ និងព្យាបាលដល់ជនពិការ ។ យោងតាមក្របខ័ណ្ឌការងារនេះ មនុស្សដែលពិការជាធម្មតាត្រូវបានមើលឃើញថា ជាអ្នកជំងឺម្នាក់ដែលអន់ខ្សោយខាងសរីរាង្គ ហើយត្រូវការសេវាសុខភាព។ ក្រៅតែពីជួយអោយជនពិការសប្បាយចិត្តមានលទ្ធភាពធ្វើដំណើរបាន ដោយសារទទួលបាននូវសេវាស្តារលទ្ធភាពនោះ ម៉ូដែលនេះ មិនបានគិតទៅដល់ការជួយផ្តល់សិទ្ធិអំណាចដល់ជនពិការ ឬលប់បំបាត់ចោលរបាំងសង្គម ឬឥរិយាបថ ដែលកើតមានចំពោះជនពិការនោះទេ ។

រីឯ ម៉ូដែលសង្គម មានគោលបំណងបង្កើតឡើងនូវឥរិយាបថដ៏ល្អរវាងជនពិការនិងជនពិការដូចគ្នា គ្រួសាររបស់គេ និងសង្គមទាំងមូល ។ ទស្សនៈនេះផ្លាស់ប្តូរពីការគិតគូរដែលថា ពិការភាពជាភាពអន់ខ្សោយរបស់បុគ្គលដែលត្រូវការមេត្តាធម៌ ទៅជាទស្សនៈមួយដែលគិតថា សង្គមទាំងមូលជាអ្នកដែលធ្វើអោយពួកគេពិការ ។ នេះមានន័យថា មនុស្សអន់ខ្សោយសរីរាង្គ ក្លាយទៅជាជនពិការបាន ក៏ព្រោះតែទម្លាប់ទូទៅរបស់សង្គម ការរើសអើងដែល

---

[17] សូមមើល Foundation for International Training and ADB Regional and Sustainable Development Department, *Disable people and Development* and Asia Development Bank, *Disabilities Brief.*

[18] ផ្នែកនេះស្រង់ចេញពី Edmonds, *Disabled People and Development*

មានជាហូរហែ និងឧបសគ្គសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរដែលរារាំងសមត្ថភាពជនពិការ ដើម្បីពួកគេចូលរួមអោយបាន ពេញលេញ និងស្មើភាពគ្នានៅក្នុងសង្គម ។ ម៉ូដែលនេះគឺ គិតគូរទៅដល់ការលើកកំពស់សិទ្ធិជនពិការ និង ការតស៊ូមតិ ដើម្បីអោយមានការរាប់បញ្ចូលជនពិការ ទៅក្នុងការសំរេចចិត្ត និងការរៀបចំគោលនយោបាយ។ ទោះជាយ៉ាងណាក្តី ម៉ូដែលនេះ មាននិន្នាការមិនសូវផ្តោតទៅលើ ការផ្តល់សេវាពីសំណាក់ស្ថាប័ន និងអ្នកជំនាញ ដែលអាចជួយផ្តល់ការស្តារលទ្ធភាពពលកម្ម ដើម្បីបំពេញនូវតំរូវការជនពិការនោះទេ។

ដោយឡែក ម៉ូដែលសមភាពក្នុងនាមជាពលរដ្ឋ បញ្ជាក់ថា ជនពិការសមនឹងទទួលបាន និងប្រាថ្នាអោយមាន ឱកាសដូចគ្នា នឹងពលរដ្ឋឯទៀតនៅក្នុងសហគមន៍របស់ពួកគេដែរ។ ម៉ូដែលនេះ ផ្តោតលើការលើកកំពស់សង្គមមួយ ដែលយកសិទ្ធិជាមូលដ្ឋាន ហើយដែលសង្គមនេះ បង្កលក្ខណៈអោយមានភាពចំរុះគ្នា សមភាព និងការចូលរួម ពីពលរដ្ឋទាំងអស់គ្នា។ ម៉ូដែលនេះទទួលស្គាល់ ភាពចំរុះគ្នា និងភាពប្លែកពីគេឯងរបស់ជនពិការ ជាពិសេសស្ត្រី កុមារ និង មនុស្សចាស់ ហើយថា ពលរដ្ឋទាំងអស់គ្នាត្រូវមានឱកាសស្មើគ្នា ដើម្បីអោយពួកគេទទួលបានសិទ្ធិ និង សំរេចបាននូវសក្តានុពលសេដ្ឋកិច្ចដ៏ពេញលេញរបស់ពួកគេ។ ម៉ូដែលនេះ ទទួលស្គាល់នូវសមត្ថភាព និងកង្វះខាត របស់ជនពិការប្រកបដោយភាពវិជ្ជមាន និងស្ថាបនា ព្រមទាំងលើកកំពស់ជនពិការអោយទទួលបាននូវសេវាច្រើន រាប់តាំងពីស្ថាប័នផ្សេងៗ រហូតដល់កំរិតសហគមន៍ ។

## ការឆ្លើយតបទៅនឹងការប្រឈមមុខនៃបញ្ហាពិការភាព

ភាពជឿនលឿនទៅមុខនៅក្នុងការគិតគូរជាលក្ខណៈទ្រឹស្តីអំពី បញ្ហាពិការភាព មានឥទ្ធិពលយ៉ាងច្បាស់ទៅលើ ការរៀបចំយុទ្ធសាស្ត្រ និង គោលនយោបាយអភិវឌ្ឍន៍ ។ ពាក្យពេជន៍ជាច្រើនដូចជា ការរាប់បញ្ចូល (Inclusive) គ្មានឧបសគ្គរារាំង (Barrier-free) យកសិទ្ធិជាមូលដ្ឋាន (Rights-based) ការជួយខ្លួនឯង (Self-help) យកសហគមន៍ជាមូលដ្ឋាន (Community-based) និងការបញ្ជ្រាបចូល (Mainstreaming) ត្រូវបានយក មកប្រើប្រាស់នៅក្នុងការរៀបចំកម្មវិធីសំរាប់បញ្ហាពិការភាព។ ពាក្យពេជន៍ទាំងនេះ ត្រូវបានបង្ហាញអោយឃើញ ច្បាស់ នៅក្នុងសំណើច្បាប់គ្រប់គ្រងវិស័យពិការភាពនៅប្រទេសកម្ពុជា ព្រមទាំងនៅក្នុងកម្មវិធីស្តារលទ្ធភាព ពលកម្មរបស់អង្គការអតីតយុទ្ធជនអន្តរជាតិ (វីអាយ) នៅខេត្តព្រៃវែង ដែលកម្មវិធីរបស់អង្គការនេះ គ្របដណ្តប់ ទៅលើតំបន់ដែលបានធ្វើការស្រាវជ្រាវនេះផងដែរ។

## *ការអនុវត្តន៍ក្របខ័ណ្ឌសហស្សវត្សដែលបានធ្វើឡើងនៅប៊ីវ៉ាកូ*

នៅឆ្នាំ២០០២ សមាជិកជាច្រើននាក់របស់គណៈកម្មការសេដ្ឋកិច្ច-សង្គម ទទួលបន្ទុកការងារអាស៊ី និងប៉ាស៊ីហ្វិក របស់អង្គការ សហប្រជាជាតិ (ESCAP) ដែលតំណាងឱ្យតំបន់អាស៊ីប៉ាស៊ីហ្វិក បានព្រមទទួលយកកិច្ចព្រមព្រៀង ក្របខ័ណ្ឌសហស្សវត្សប៊ីវ៉ាកូ (BMF) ស្ថិតនៅទីក្រុងអូតស៊ុ ប្រទេសជប៉ុន សំរាប់សកម្មភាពឆ្ពោះទៅរកការលើក ស្ទួយសង្គមមួយដែលមានការរាប់បញ្ចូល ដែលគ្មានឧបសគ្គ និងយកសិទ្ធិជាមូលដ្ឋាន សំរាប់ជនពិការក្នុងតំបន់ ។ ពាក្យពេជន៍ទាំងនេះ ត្រូវបានថែងយ៉ាងច្បាស់លាស់គឺ ពាក្យថា "សង្គមមួយដែលមានការរាប់បញ្ចូល" សំដៅទៅ លើសង្គមមួយដែលជាសង្គមសំរាប់ទាំងអស់គ្នា ។ ចំពោះពាក្យ " សង្គមមួយដែលគ្មានឧបសគ្គរាំង" មានន័យថា ជាសង្គមមួយ ដែលគ្មានការរាំងទាំងបញ្ហាខាងរូបវ័ន្ត និងឥរិយាបថ ចំពោះជនពិការ ហើយព្រមទាំងរបាំងសង្គម សេដ្ឋកិច្ច និង វប្បធម៌ផងដែរ។ រីឯ "សង្គមមួយដែលយកសិទ្ធិជាមូលដ្ឋាន" ជាសង្គមដែលប្រកាន់យកទស្សនៈ សិទ្ធិមនុស្ស រាប់ទាំងសិទ្ធិក្នុងការអភិវឌ្ឍន៍ផងដែរ។ តាមរយៈក្របខ័ណ្ឌ BMF, គណៈកម្មការ ESCAP មានបំណង លើកទឹកចិត្តដល់រដ្ឋាភិបាលនានា ដើម្បីអោយមានការផ្លាស់ប្តូរគោលនយោបាយអំពី បញ្ហាពិការភាព ពីបែបផែន មេត្តាធម៌ មកជាបែបផែនដែលយកសិទ្ធិជាមូលដ្ឋានវិញ។ គេផ្តល់អាទិភាពជាចំបងទៅដល់ការបង្កើតស្ថាប័ន/ក្រុម ជួយខ្លួនឯងរបស់ជនពិការ និងសមាគមនគ្រួសារ និងឪពុកម្តាយរបស់ជនពិការ[១៩] ។

ស្ថាប័នជួយខ្លួនឯង ឬអង្គការជនពិការ គឺជាក្រុមដែលគ្រប់គ្រងដោយជនពិការផ្ទាល់ ហើយដើម្បីជួយដល់ជនពិការ ទាំងអស់។ ស្ថាប័ននេះមានតួនាទីសំខាន់ក្នុងការធ្វើជាតំណាងអោយជនពិការទាំងមូល លើកកំពស់ការយល់ដឹង អំពីបញ្ហាពិការភាព និងតស៊ូមតិសំរាប់សិទ្ធិរបស់ជនពិការ ចំពោះរដ្ឋាភិបាល និងតួអង្គអភិវឌ្ឍន៍ផ្សេងៗទៀត[២០] ។ គេលើកហេតុផលបន្ថែមថា ការចូលរួមក្នុងក្រុម/អង្គការជួយខ្លួនឯងគឺជាការចាំបាច់ ដើម្បីកំណត់រកតំរូវការរបស់ ជនពិការ ព្រមទាំងធ្វើផែនការ អនុវត្តន៍ និងវាយតំលៃលើយុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រដោយប្រសិទ្ធិភាព[២១] ។

ការសិក្សាមួយដែលបានធ្វើនៅប្រទេសអាស៊ីចំនួន៦ ផ្តល់នូវការយល់ដឹងស៊ីជំរៅអំពី ការរួមចំណែកនៃក្រុម/ស្ថាប័ន ជួយខ្លួនឯងរបស់ជនពិការ ក្នុងការធ្វើអោយមានការផ្លាស់ប្តូរ និងជំរុញអោយមនុស្សគ្រប់រូបមានឥរិយាបថវិជ្ជមាន ចំពោះជនពិការ។ ការស្រាវជ្រាវរាយការណ៏ថា អង្គការជនពិការមានឥទ្ធិពលក្នុងយុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រ និងការធ្វើសេចក្តីសំរេចចិត្ត នៅថ្នាក់ជាតិ និងមូលដ្ឋាន។ ការស្រាវជ្រាវនេះ ក៏បានរកឃើញដែរថា ក្រុម/ស្ថាប័ន ទាំងនេះ តម្រូវអោយស្ត្រី និងប្រជាពលរដ្ឋនៅជនបទ ចូលរួមសំរេចចិត្ត លើកកំពស់សមត្ថភាពគ្រប់គ្រង និងទទួល បាននូវពតិមានថ្មីៗអំពី និន្នការពិការភាព និងការអភិវឌ្ឍន៍ ព្រមទាំង ទទួលនូវបទពិសោធន៍នៃការប្រតិបត្តិល្អ[២២] ។

---

[19] ធនាគារអភិវឌ្ឍន៍អាស៊ី, *Disabilities Brief.*

[20] Thomas, *Poverty Reduction and Development in Cambodia*.

[21] Edmonds, *Disabled People and Development.*

[22] A. Ninomiya, *Asian Persons with Disabilities and International NGOs,* (Tokyo: Akashi Co., 1999) cited in Edmonds, *Disabled People and Developmen.*

ដោយសារថា ជនពិការនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវពឹងផ្អែកច្រើនទៅលើការទទួលបានពត៌មានក្រៅផ្លូវការ ដើម្បីស្វែងរកការគាំទ្រ ទើបគេឃើញថា ការបង្កើតស្ថាប័ន/ក្រុមជួយខ្លួនឯង មានការផ្សារភ្ជាប់ជិតស្និតទៅនឹងសេវាស្តារលទ្ធភាពពលកម្ម នៅតាមមូលដ្ឋាន ។ នៅក្នុងរបាយការណ៏សង្ខេបរបស់ធនាគារអភិវឌ្ឍន៏អាស៊ីស្តីពីពិការភាព បានលើកឡើងថា ការស្តារលទ្ធភាពពលកម្មនៅតាមសហគមន៏មូលដ្ឋាន គឺជាមធ្យោបាយសមស្របជាពិសេស សំរាប់ការពារបុព្វហេតុដែលនាំអោយមានពិការភាព និង ការកំនត់មុខសញ្ញានិងអន្តរាគមន៍ជាមុនចំពោះកុមារពិការ ការជួយដល់ជនពិការនៅតាមជនបទដាច់ស្រយាល និងលើកកំពស់ការយល់ដឹង និងការតស៊ូមតិសំរាប់អោយជនពិការចូលរួមនៅគ្រប់សកម្មភាពទាំងអស់នៅសហគមន៏របស់គេរួមមាន ពិធីផ្សេងៗដែលមានក្នុងសង្គម ពិធីទាក់ទងនឹងវប្បធម៌និងសាសនាជាដើម ។ របាយការណ៏បានផ្តល់យោបល់ថា ការអប់រំ ការបណ្តុះបណ្តាល និងតម្រូវការអោយមានការងារធ្វើ អាចនឹងត្រូវបានបំពេញតាមយុទ្ធសាស្រ្តខាងលើនេះដែរ[២៣] ។

នៅក្នុងប្រទេសកម្ពុជា មានអង្គការមួយចំនួនតូចកំពុងធ្វើការនៅកំរិតសហគមន៏ទៅលើការផ្សព្វផ្សាយអំពី ទស្សនៈនៃការចេះជួយខ្លួនឯង និងកសាងសមត្ថភាពជនពិការ ។ អង្គការមួយចំនួនទាំងនេះ មានកម្មវិធីដូចជា ស្វែងរកឱកាសបង្កើតគំរោងបង្កើនប្រាក់ចំណូល មូលនិធិសាមគ្គី និង បង្កើតអោយមានក្រុមមិត្តអប់រំមិត្ត ។ ទោះបីមានកម្មវិធីដូចរៀបរាប់នេះក្តី ក៏ការគ្របដណ្តប់ទៅលើទីតាំងភូមិសាស្រ្ត មានតិចតួចនៅឡើយ ។ លើសពីនេះទៅទៀត ទំនាក់ទំនងជិតស្និទ្ធរវាងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មនានា និងសេវាកម្មនៅក្នុងសហគមន៏ ត្រូវតែបង្កើតឡើងដើម្បីផ្តល់សេវាកម្មស្តារលទ្ធភាពពលកម្មឱ្យកាន់តែបានទូលំទូលាយ[២៤] ។

## *ការបញ្ជ្រាបចូលបញ្ហាពិការភាព នៅក្នុងការអភិវឌ្ឍន៍ទ្រង់ទ្រាយធំ*

ការអភិវឌ្ឍន៏តម្រូវឱ្យជម្រុះចោលនូវឥរិយាបទអវិជ្ជមាន និងរបាំងសង្គម ហើយរាប់បញ្ចូលនូវអ្នកដែលនៅឯកោ ដូចជា ស្រ្តីពិការ និងកុមារពិការ អោយចូលរួមពេញលេញកនៅក្នុងសង្គម ។ ធ្វើដូច្នេះ ទើបធ្វើអោយពួកគេអាចមានឱកាសចូលរៀន ធ្វើការងារ មានកូន ចិញ្ចឹមគ្រួសារបាន ទទួលបានសេវាសុខភាព និងស្តារលទ្ធភាពពលកម្ម ចូលរួមពិធីបុណ្យនៅតាមវត្តអារាម និងមហោស្រពផ្សេងៗ ចូលរួមនៅក្នុងសកម្មភាពអភិវឌ្ឍន៏ និងបានចូលរួមបោះឆ្នោតជ្រើសរើសបេក្ខជនដែលគេពេញចិត្តដូចជាប្រជាពលរដ្ឋទូទៅដែរ ។ ជាការពិតណាស់ ជនពិការចង់ឱ្យគេគោរពសិទ្ធិរបស់ខ្លួនដែរ ព្រោះថា គេក៏ចង់បានសេវាសង្គម និងសុខភាពដូចអ្នកឯទៀត ។ ប៉ុន្តែលើសពីនេះទៅទៀត ជនពិការ និងគ្រួសាររបស់គេ ចង់បាន និងគួរតែទទួលបាននូវការទទួលស្គាល់ជាប្រជាពលរដ្ឋពេញលេញ[២៥] ។

---

[23] ធនាគារអភិវឌ្ឍន៏អាស៊ី, *Disabilities Brief*

[24] Foundation for International Training and ADB Regional and Sustainable Development Department, *Disable people and Development*

[25] Edmonds, *Disabled people and Development*

ជាអកុសល ការពឹងផ្អែកស្ទើរទាំងស្រុងរបស់រដ្ឋាភិបាលកម្ពុជា មកលើអង្គការមិនមែនរដ្ឋាភិបាល ក្នុងការផ្តោតការយកចិត្តទុកដាក់ទៅលើបញ្ហាពិការភាព មានន័យថា បញ្ហាពិការភាពត្រូវបានកាត់ផ្តាច់ចេញភាគច្រើនពីដំណើរការអភិវឌ្ឍន៏ក្នុងទ្រង់ទ្រាយធំ។ ទោះបីជាមានកិច្ចប្រឹងប្រែងគួរឱ្យកត់សំគាល់ ពីសំណាក់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងវិស័យនេះក្តី ក៏សេវាកម្មសំរាប់ជនពិការនៅតែមិនទាន់បានគ្រប់គ្រាន់ ជាពិសេស នៅតាមតំបន់ជនបទ។ ការពឹងផ្អែក ស្ទើរតែទាំងស្រុងទៅលើអង្គការមិនមែនរដ្ឋាភិបាលក្នុងការផ្តល់ជំនួយដល់ជនពិការ អាចចោទជាសំនួរសំខាន់មួយអំពី និរន្តរភាពនៃកិរិតសេវាកម្មសព្វថ្ងៃ ដោយមិនទាន់គិតទៅដល់លទ្ធភាពនៃការពង្រីកសេវាកម្មនេះបន្ថែម ដើម្បីឆ្លើយតបទៅនឹងតម្រូវការនាពេលអនាគតនោះនៅឡើយទេ។ ទោះបីជា បញ្ហាពិការភាពគឺជា បញ្ហាមួយដែលកើតមាននៅគ្រប់វិស័យ តែកន្លងមក បញ្ហានេះបានទទួលបានការយកចិត្តទុកដាក់តិចតួចក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៏របស់ជាតិ ផ្ទុយទៅវិញបញ្ហាដទៃទៀតដូចជា យេនឌ័រ ជនជាតិដើមភាគតិច និងជំងឺអេដស៏ ត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំង[២៦] ។

ដំណើរការនៃការបញ្ជ្រាបចូលបញ្ហាពិការភាពទៅក្នុងការអភិវឌ្ឍន៏ក្នុងទ្រង់ទ្រាយធំ តម្រូវឱ្យមានដាក់បញ្ចូលទៅក្នុងកម្មវិធីនៃវិស័យធំៗ និងកម្មវិធីជាក់លាក់ទៅលើក្រុមមនុស្សណាមួយ ហើយក្នុងខណៈនេះដែរ ក៏ត្រូវបន្តរក្សានូវកម្មវិធីផ្អែកពិការភាពនៃអង្គការមិនមែនរដ្ឋាភិបាល ដើម្បីជាការជួយបំពេញបន្ថែម ។ និយាយជារួម យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រនៅក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ នេសាទ និងឧស្សាហកម្ម មិនបានបំពេញទៅតាមតម្រូវការជនពិការ និងគ្រួសាររបស់គេទេ។ ស្រដៀងគ្នានេះដែរ កម្មវិធីផ្តោតលើវិស័យណាមួយសំរាប់អ្នកដែលងាយរងគ្រោះដូចជា ស្ត្រី កុមារ យុវជន និងជនជាតិដើមភាគតិច មិនបានរាប់បញ្ចូលជនពិការនៅក្នុងកិរិតមួយដែលរំពឹងទុកនោះទេ។ ដូច្នេះ ជនពិការមិនត្រូវបានគេភ្លេចអើពើ ឬក៏សន្មត់ថា ពួកគេបានរួមបញ្ចូលនៅកម្មវិធីដែលមានស្រាប់សព្វថ្ងៃនេះរួចទៅហើយនោះទេ។ គេត្រូវបង្ហាញអោយឃើញថា ជនពិការត្រូវបានរាប់បញ្ចូលទៅក្នុងគ្រប់កម្មវិធីវិស័យធំៗ និងកម្មវិធីជាក់លាក់ទៅលើក្រុមមនុស្សណាមួយ សំរាប់កាត់បន្ថយភាពក្រីក្រ។ បើគេគ្រាន់តែបញ្ជ្រាបចូលបញ្ហាពិការភាព ទៅក្នុងកម្មវិធីដែលមានស្រាប់សព្វថ្ងៃ នោះគឺមិនគ្រប់គ្រាន់ទេ។ ការពង្រីកកម្មវិធីពិសេសសំរាប់ជនពិការ គឺជាប្រការសំខាន់ណាស់ ក្នុងឆ្លើយតបទៅនឹងតម្រូវការ និងការទាមទារផ្សេងៗរបស់ជនពិការ[២៧] ។

នៅពេលដែលស្ថាប័នជំនួយអភិវឌ្ឍន៏ទ្វេភាគី និងពហុភាគី បានខិតខំដើម្បីលើកស្ទួយស្ថានភាពជនពិការ តាមរយៈការបញ្ជ្រាបចូលបញ្ហានេះ ទៅក្នុងកម្មវិធីអភិវឌ្ឍន៏ទ្រង់ទ្រាយធំ តែគេពុំទាន់បានទទួលពត៌មានអំពី លទ្ធផលនៃ

[26] Thomas, Poverty Reduction and Development in Cambodia
[27] Edmonds, *Disabled People and Development*

កិច្ចប្រឹងប្រែងនេះនៅឡើយទេ[២៨] ។ បន្តទៅទៀតនេះគឺជា ការសង្ខេបនូវយុទ្ធសាស្ត្រដែលបានរៀបចំឡើងដោយ DFID និង ADB ។ DFID បានប្រកាន់យកនូវយុទ្ធសាស្ត្រ "ពីរចំណុច" ចំពោះបញ្ហាពិការភាពគឺ ជនពិការគួរតែត្រូវបានរាប់បញ្ចូលនៅគ្រប់ការងារទាំងឡាយណាដែលផ្តល់មូលនិធិដោយ DFID និងការទទួលបានផលប្រយោជន៏ពីកម្មវិធីទាំងឡាយណាដែលផ្តួចផ្តើមគំនិតរៀបចំជាក់លាក់ សំរាប់តែជនពិការ ។ DFID ប្រមើលមើលឃើញថាយុទ្ធសាស្ត្រនេះចាំបាច់តម្រូវឱ្យមានការផ្លាស់ប្តូរនៅទៅលើ គោលនយោបាយ ការអភិវឌ្ឍន៏មនុស្ស និង សង្គមហេដ្ឋារចនាសម្ព័ន្ធ ជំនួយមនុស្សធម៌ និងជំនួយសំរាប់ពេលមានសង្គ្រាម/ជម្លោះ ព្រមទាំងការផ្តល់នូវ សិទ្ធិអំណាច ។ មានការរៀបចំវាយតម្លៃធ្វើឡើងដោយអង្គការមិនមែនរដ្ឋាភិបាលមួយឈ្មោះថា សកម្មភាពដើម្បីពិការភាព និងការអភិវឌ្ឍន៏នាឆ្នាំ២០០៣ ដើម្បីពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រខាងលើនេះបានសន្និដ្ឋានថា យុទ្ធសាស្ត្រ"ពីរចំណុច" ដែលស្នើឡើងដោយ DFID ត្រូវធ្វើដំណើរលើកំណាត់ផ្លូវមួយវែងឆ្ងាយ មុននឹងឃើញភាពជាក់ស្តែងទៅបាន[២៩] ។

រីឯធនាគារអភិវឌ្ឍន៏អាស៊ីវិញ បានរៀបចំក្របខ័ណ្ឌមួយដែលគេហៅ ចំណេះដឹង (Knowledge) ការរាប់បញ្ចូល (Inclusion) ការចូលរួម (Participation) និងការទទួលបាន (Access) (ឬ KIPA) សំរាប់ដាក់បញ្ចូលនូវបញ្ហាឬតម្រូវការរបស់ជនពិការ ទៅក្នុងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ។ យោងទៅតាមធនាគារអភិវឌ្ឍន៏អាស៊ីបានអោយដឹងថា ចំណេះដឹង ប្រមូលផ្តុំបានជាសមត្ថភាព ដើម្បីធានាថា ជនពិការមានគុណភាពជីវិតប្រសើរឡើង ។ ចំពោះ ការរាប់បញ្ចូល មានន័យថា ជាការបង្ហាញអោយឃើញនូវសមាហរណកម្មទៅសកម្មភាពសង្គម និងសេដ្ឋកិច្ចរាប់តាំងពី ការអប់រំ រហូតដល់ការទទួលបានការងារធ្វើ ។ រីឯការចូលរួមវិញ មានន័យថា ជនពិការ និងអង្គការរបស់គេ ត្រូវមានតំណាងចូលរួមនូវរាល់ការសំរេចចិត្ត នៅគ្រប់លំដាប់ថ្នាក់ ដែលអាចប៉ះពាល់ដល់ជីវិត និងសហគមន៏របស់គេ ។ ចំពោះ ការទទួលបាន មានន័យសំដៅទៅលើថា តើជនពិការ អាចប្រើប្រាស់ធនធានធម្មជាតិនិងធនធានអ្វីដែលបង្កើតឡើងដោយមនុស្ស ព្រមទាំងទទួលបានពត៌មាន និងមានចំណែកក្នុងប្រព័ន្ធទំនាក់ទំនង ។ ធនាគារអភិវឌ្ឍន៏អាស៊ី បានរៀបចំបញ្ជីត្រួតពិនិត្យសំរាប់ KIPA ក្នុងការធ្វើយុទ្ធសាស្ត្រអភិវឌ្ឍន៏លំដាប់ប្រទេស និងសកម្មភាពកម្មវិធី ព្រមទាំងសំរាប់ជួយរៀបចំគំរោង និងសំរាប់វិស័យណាដែលមានសក្តានុពល សំរាប់គិតគូរដល់បញ្ហាពិការភាព ។ គេកំពុងរង់ចាំមើលលទ្ធផលជាក់ស្តែងថា តើក្របខ័ណ្ឌ KIPA នឹងជះឥទ្ធិពលដល់កម្មវិធីកាត់បន្ថយភាពក្រីក្ររបស់ធនាគារអភិវឌ្ឍន៏អាស៊ីក្នុងក៏រិតណានោះ[៣០] ។

---

[28] ស្ថាប័នទាំងនេះរួមមាន ធនាគារអភិវឌ្ឍន៏អាស៊ី (ADB) ធនាគារពិភពលោក (WB), JICA, នាយកដ្ឋានចក្រភពអង់គ្លេសសំរាប់ការ អភិវឌ្ឍន៏អន្តរជាតិ (DFID), ភ្នាក់ងារអភិវឌ្ឍន៏អន្តរជាតិហ្វាំងឡង់ (FINNIDA), ភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់ការអភិវឌ្ឍន៏អន្តរជាតិ (USAID) ភ្នាក់ងារណរវ៉េយសំរាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៏ (NORAD) និងភ្នាក់ងារកាណាដាដើម្បីអភិវឌ្ឍន៏អន្តរជាតិ (CIDA) ។ សូមមើល Edmonds, *Disabled People and Development* ។ សូមមើល Takako Yoshimura, "Role of international development agencies: mainstreaming disabled people in poverty reduction in developing countries," Unpublished Masters of Arts Degree in Development Studies and Disability, The School of Politices and international Studies, The University of Leeds, July 2005.

[29] Yeo, "To what extent are disabled people included in international development work? How can the barriers to inclusion be overcome?"

[30] Asian Development Bank, *Disability Brief* and Edmonds, Disabled people and Development

*វិស័យពិការភាពនៅកម្ពុជា*

មានតួអង្គសំខាន់ៗចំនួនបីដែលធ្វើការងារផ្នែកពិការភាពនៅកម្ពុជាគឺ រដ្ឋ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការ ឬសមាគមជនពិការ (DPOs) ។ ប្រការសំខាន់ ស្ថាប័នរដ្ឋ គួរតែអនុម័តគោលនយោបាយ និងច្បាប់ បង្កើតបទដ្ឋាននានា ត្រួតពិនិត្យធនធានទាំងឡាយដែលមាន និងផ្តល់សេវា។ ចំពោះអង្គការមិនមែនរដ្ឋាភិបាល គួរតែធ្វើយ៉ាងណាអោយជនពិការទទួលបានសិទ្ធិរបស់គេ រីឯអង្គការ ឬសមាគមជនពិការវិញ គួរតែបញ្ចុះបញ្ចូល និងធ្វើការតស៊ូមតិតំណាងអោយជនពិការទាំងមូល[៣១] ។ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តន៍តួនាទី និងការទទួលខុសត្រូវ ចំពោះបញ្ហាពិការភាពនៅកម្ពុជាគឺ ស្ថិតនៅឆ្ងាយពីការគិត ។ រឿងនេះគេអាចយល់បានថា ដោយសារប្រទេសនេះធ្លាប់មានប្រវត្តិឆ្លងកាត់ភ្លើងសង្គ្រាមកន្លងមកនេះ តែរឿងនេះមិនត្រូវនៅបន្តចាត់ទុកជាបញ្ហារារាំងដល់ការអនុវត្តន៍ការងារបច្ចុប្បន្នទៀតទេ ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទារបស់រដ្ឋាភិបាល តាមរយៈនាយកដ្ឋានស្តារនិតិសម្បទា មានភារៈកិច្ចទទួលខុសត្រូវរួម ចំពោះជនពិការនៅកម្ពុជា។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា យល់ថា ការងារចម្បងរបស់ខ្លួនគឺ ទី១)-ពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗ និងអង្គការទទួលបន្ទុកខាងការងារសំរបសំរួល ទី២)-រៀបចំបង្កើតគោលនយោបាយ និងច្បាប់ ទី៣)-បង្កើតបទដ្ឋាននានា និងទី៤)-ត្រួតពិនិត្យ និងវាយតំលៃទៅលើការអនុវត្តន៍ ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មិនមានខ្ទង់ចំណាយសំរាប់ស្តារលទ្ធភាពពលកម្មសំរាប់ជនពិការ ហើយជាគោលការណ៍គឺ ត្រូវពឹងផ្អែកទាំងស្រុងទៅលើអង្គការមិនមែនរដ្ឋាភិបាល សំរាប់ការផ្តល់សេវា[៣២] ។

ទោះជាយ៉ាងណាក៏ដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា ក៏បំពេញតួនាទីក្នុងការផ្តល់ប្រាក់សោធននិវត្តន៍ សំរាប់អតីតមន្ត្រីរាជការពិការ និងអតីតយុទ្ធជនដែរ ។ ទោះបីចំនួនទឹកប្រាក់នេះ មានក៏រិតទាប ក៏នេះជាប្រភពចំណូលទៀងទាត់ និងជាធនធានសំខាន់សំរាប់អ្នកដែលបានទទួលទឹកប្រាក់នេះដែរ។ មានការជួបប្រទះនូវបញ្ហាមួយចំនួននៅក្នុងបញ្ហាប្រាក់សោធននិវត្តន៍នេះគឺ គឺការបើកមិនទៀងទាត់ និងយឺតយ៉ាវ តំរូវការក្នុងការសូកប៉ាន់ទៅមន្ត្រីខ្លះ ដើម្បីរក្សាឈ្មោះនៅក្នុងបញ្ជី និងការលក់ឈ្មោះអោយគេ ដោយព្រមទទួលយកនូវទឹកប្រាក់ដែលទាបជាងចំនួនត្រូវទទួលបានគួរអោយកត់សំគាល់[៣៣] ។

---

[31] មើល Thomas, *Poverty Reduction and Development in Cambodia*.

[32] Thomas, *Poverty Reduction and Development in Cambodia* and Foundation for International Training and ADB Regional and Sustainable Development Department, *Disable people and Development*

[33] Thomas, *Poverty Reduction and Development in Cambodia*.

នាឆ្នាំ១៩៩៧ រដ្ឋាភិបាលបានបង្កើតក្រុមប្រឹក្សាសកម្មភាពជនពិការ (Disability Action Council) ដើម្បីធ្វើការសំរបសំរួលក្នុងវិស័យនេះ និងផ្តល់ប្រឹក្សាលើបញ្ហាពិការភាព។ ក្រុមប្រឹក្សាសកម្មភាពជនពិការ ដើរតួជាវេទិកាមួយក្នុងការនាំយកអ្នកពាក់ព័ន្ធទាំងខាងរដ្ឋាភិបាល និងសង្គមស៊ីវិលទាំងអស់ ដើម្បីទាញយកជំនាញបច្ចេកទេសមកប្រើប្រាស់ ព្រមទាំងធនធានសំភារៈពីអង្គការមិនមែនរដ្ឋាភិបាលដែលជាអ្នកផ្តល់សេវា ដែលនេះជាតួនាទីមួយជួយដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ដែលជាក្រសួងត្រូវបានគេស្គាល់ជាយូរណាស់មកហើយថាជាក្រសួងមិនសូវមានលុយ ។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាសកម្មភាពជនពិការ ធ្វើការសំរបសំរួលនូវរាល់ការខិតខំប្រឹងប្រែងរបស់គណៈកម្មការស្តារលទ្ធភាពពលកម្ម ដែលគណៈកម្មការនេះមានតួនាទីធ្វើអោយផលិតផលសប្បនិមិត្តមានស្តង់ដា (ដោយប្រើបច្ចេកវិទ្យាទំនើប) ព្រមទាំងជួយបណ្តុះបណ្តាលដល់ផលិតករគ្រឿងសិប្បនិមិត្តទៀតផង ។ ដូចគ្នានេះដែរ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាសកម្មភាពជនពិការ ក៏ធ្វើការសំរបសំរួលក្រុមការងារដែលផ្តោតការយកចិត្តទុកដាក់ទៅលើស្ត្រីពិការ និងកុមារពិការ ការស្តារលទ្ធភាពពលកម្មដោយប្រើប្រាស់ថ្នាំពេទ្យរៀបចំច្បាប់ ធ្វើការងារតាមសហគមន៍ជាមួយជនពិការ និងផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ[៣៤] ។

នៅពេលបច្ចុប្បន្ននេះ ការផ្តោតការយកចិត្តទុកដាក់របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាសកម្មភាពជនពិការ គឺការឆ្លងសេចក្តីព្រាងច្បាប់ស្តីពី **សិទ្ធិនៃជនពិការ**។ សេចក្តីព្រាងច្បាប់នេះ មានប្រវត្តិរឿងនៃការរៀបចំឡើងជាយូរឆ្នាំមកហើយគឺតាំងពីទសវត្សឆ្នាំ ១៩៩០ មកម្លេះ ហើយបានពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធជាច្រើន ។ ដូចមានចែងក្នុងបទបញ្ញត្តិទូទៅ គោលបំណងនៃច្បាប់នេះគឺលើកកំពស់ និងការពារសិទ្ធិ និងផលប្រយោជន៍នៃជនពិការ ព្រមទាំងដើម្បីលប់បំបាត់នូវរាល់ទំរង់នៃការរើសអើងទាំងអស់ និងដើម្បីធានាថា ជនពិការមានសិទ្ធិពេញលេញ និងស្មើភាពគ្នាក្នុងការចូលរួមគ្រប់សកម្មភាពទាំងអស់ក្នុងសង្គមដូចមនុស្សទូទៅដែរ។ សេចក្តីព្រាងច្បាប់នេះមាន១៣ជំពូក និង៦៨មាត្រាដែលគ្របដណ្តប់នូវខ្លឹមសារសំខាន់៧ដូចជា គុណភាពនៃជីវិត ការស្តាលទ្ធភាពពលកម្ម សុខភាព ការការពារ ការចូលរួមជាសាធារណៈ ការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការទទួលបានការងារធ្វើ រង្វាន់លើកទឹកចិត្តក្នុងការងារ និងការចូលរួមបោះឆ្នោត។ នាដើមឆ្នាំ ២០០៦ សេចក្តីព្រាងច្បាប់នេះបានដាក់ឆ្លងគណៈកម្មការត្រួតពិនិត្យជាច្រើន តែមិនទាន់ឆ្លងទៅដល់គណៈរដ្ឋមន្ត្រី និងសភាជាតិនៅឡើយទេ។ ការឆ្លងច្បាប់ស្តីពីសិទ្ធិជនពិការដូចការរំពឹងទុកមកនេះ បង្ហាញអោយឃើញនូវការបោះជំហ៊ានដ៏សំខាន់ ក្នុងការលើកយកបញ្ហាពិការភាព ដាក់ចូលទៅក្នុងរបៀបវារៈនៃការអភិវឌ្ឍន៍របស់ជាតិយើង[៣៥] ។

---

[34] Thomas, *Poverty Reduction and Development in Cambodia* and Foundation for International Training and ADB Regional and Sustainable Development Department, *Disable people and Development*

[35] Thomas, *Poverty Reduction and Development in Cambodia* and Foundation for International Training and ADB Regional and Sustainable Development Department, *Disabled People and Development* *និងសូមមើលផងដែរនូវសេចក្តីព្រាងច្បាប់ អំពីសិទ្ធិជនពិការ*

ជារួម មានអង្គការមិនមែនរដ្ឋាភិបាលជាង៣០ បាន និងកំពុងផ្តល់សេវាដល់ជនពិការនៅក្នុងប្រទេសកម្ពុជា ។ មានម្ចាស់ជំនួយពហុភាគី និងទ្វេភាគី ព្រមទាំងមូលនិធិជាច្រើន និងអ្នកផ្តល់វិភាគទានឯកជននានា បានជួយគាំទ្រដល់អង្គការទាំងនេះ[៣៦] ។ ពីដំបូង អង្គការមិនមែនរដ្ឋាភិបាលដែលជាអ្នកផ្តល់សេវាស្តារលទ្ធភាពពលកម្ម ផ្តោតតែទៅលើតំរូវការខាងគ្រឿងសិប្បនិមិត្តចំពោះអ្នកដែលរស់រានមានជីវិតពីការគ្រោះថ្នាក់ដោយសារមីន ។ អង្គការទាំងនេះកំពុងពង្រីកសេវាស្តារលទ្ធភាពពលកម្ម ដើម្បីបញ្ចូលការងារផ្សេងៗទៀតដូចជា ១)-វគ្គបណ្តុះបណ្តាលផលិតករគ្រឿងសិប្បនិមិត្ត និងអ្នកធ្វើចលនា ២)-ផលិត បែងចែក និងការជួសជុលគ្រឿងសិប្បនិមិត្ត ៣)-ផលិតនិងបែងចែករទេះរុញ និងរទេះកង់បី ៤)-ផលិត បែងចែកឧបករណ៍ជំនួយធ្វើចលនា ៥)-ការព្យាបាលដោយចលនា និងទី ៦)-ផ្តល់សេវាថ្នាក់សហគមន៏ដូចជា ការចុះទៅដល់មូលដ្ឋាន និងការតាមដានផ្ទាល់ ។ ជាសរុបមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មចំនួន១១ កំពុងដំណើការបច្ចុប្បន្ននេះ នៅតាមតំបន់នានា នៅក្នុងប្រទេសកម្ពុជា ហើយបានទទួលជំនួយយ៉ាងសំខាន់ពីអង្គការអន្តរជាតិចំនួន៥ គឺ Cambodia Trust, Handicap International Belgium, Handicap International France, International Committee of the Red Cross និង Veterans International Cambodia ។ ចំពោះជំនួយសំរាប់រយៈពេលវែងជាបន្តទៅទៀតសំរាប់ មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មទាំងនេះ នៅមិនទាន់ច្បាស់នៅឡើយទេ[៣៧] ។ ក្នុងពេលជាមួយគ្នានេះដែរ តួនាទីអង្គការមិនមែនរដ្ឋាភិបាលក្នុងការលើកកំពស់នូវយុទ្ធសាស្ត្រដោយយកសិទ្ធិជាមូលដ្ឋាន (Rights-based approach) ដើម្បីធ្វើការជាមួយជនពិការ ក៏មិនទាន់បានយល់ច្បាស់ ឬអនុវត្តន៏ឱ្យបានពេញលេញនៅឡើយដែរ ។

អង្គការជនពិការកម្ពុជា (CDPO) ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៤ ជាអង្គការក្នុងស្រុកមួយរបស់ជនពិការ ។ អង្គការនេះ គាំទ្រ ការពារ បំរើ និងលើកកំពស់សិទ្ធិជនពិការ សមិទ្ធិផលសំរេចបាន និងផលប្រយោជន៏របស់ជនពិការ ដើម្បីអោយពួកគេចូលរួមពេញលេញ និងស្មើភាពគ្នានៅក្នុងសង្គម ។ សមាជិកទាំងអស់ និងបុគ្គលិកភាគច្រើនរបស់អង្គការនេះគឺជា ជនពិការកម្ពុជា ។ គិតត្រឹមឆ្នាំ ២០០១ អង្គការជនពិការកម្ពុជា មានសមាជិកភាពជាជនពិការជាង ២.០០០នាក់ ដែលតំណាងអោយ ២១ខេត្ត[៣៨] ។ ទោះជាយ៉ាងណាក៏ដោយ ការសិក្សាថ្មីៗនេះរបស់នាយកដ្ឋានអភិវឌ្ឍន៏អន្តរជាតិនៃចក្រភពអង់គ្លេសបានអះអាងថា អង្គការជនពិការកម្ពុជា និង អង្គការជនពិការដទៃទៀតហាក់ដូចជា ផ្តោតការយកចិត្តទុកដាក់តែលើការផ្តល់សេវាជាជាងការកសាងសមត្ថភាពរបស់ខ្លួនដើម្បីធ្វើការតស៊ូមតិ សំរាប់ទទួលបានសិទ្ធិរបស់ជនពិការ[៣៩] ។

[36] These donors include Asian Development Bank (ADB), the World Bank, the European Union (EU), United Nations Children's Fund (UNICEF), International Labor Oganization (ILO), Gesellschaft fur Technische Zusammenarbeit (GTZ), Japan International Cooperation Agency (JICA), UK Department for International Development (DFID), Finnish International Development Agency (FINNIDA), United States Agency for International Development (USAID), Danish Internatonal Development Agency (DANIDA), Australian Government Overseas Aid (AusAid), Swedish International Development Agency (SIDA), and the Canadian International Development Agency (CIDA). See Thomas, *Poverty Reduction and Development in Cambodia.*

[37] *Proposal for the Evaluation of the Physical Rehabilitation Sectpr in Cambodia, December 2005*

[38] Foundation for International Training and ADB Regional and Sustainable Development Department, *Disabled People and Development*

[39] Thomas*, Poverty Reduction and Development in Cambodia*

## *កម្មវិធីរបស់អង្គការអតីតយុទ្ធជនអន្តរជាតិ នៅខេត្តព្រៃវែង*

អង្គការអតីតយុទ្ធជនអន្តរជាតិ (វីអាយ) បានបង្កើតនូវមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម នៅខេត្តព្រៃវែងនៅឆ្នាំ ១៩៩៥ ដើម្បីពង្រីកសេវាកម្មដល់ជនពិការនៅតាមបណ្តាខេត្តនៅភាគអគ្នេយ៍នៃប្រទេសកម្ពុជា។ ចាប់តាំងពីដំណើរការមជ្ឈមណ្ឌលមក អង្គការនេះបានផ្តល់សេវាកម្មឧបករណ៍សិប្បនិមិត្ត ដល់ជនពិការជិត ៤.000 នាក់។ ផ្នែកសំខាន់មួយនៃកម្មវិធីនេះគឺ អង្គការនេះបានធ្វើការតាមដានជនពិការដែលបានទទួលសេវា ពីមជ្ឈមណ្ឌលនៃអង្គការវីអាយ នៅតាមសហគមន៏ផ្ទាល់។ កាលពីប៉ុន្មានឆ្នាំកន្លងមកនេះ អង្គការវីអាយ បានរៀបចំឡើងវិញនូវសកម្មភាពតាមដាននៅតាមសហគមន៏ អោយទៅជាយុទ្ធសាស្រ្តស្តារលទ្ធភាពពលកម្មនៅតាមសហគមន៏វិញ។ ការផ្លាស់ប្តូរនេះ តម្រូវអោយមានការបង្កើតក្រុមជួយខ្លួនឯងនៅតាមសហគមន៏ និងការផ្តល់ទុនបន្តិចបន្តួច ដល់ជនពិការ និងគ្រួសាររបស់គេ ដើម្បីអោយគេអាចរកប្រាក់ចំណូលបាន ។ គិតមកត្រឹមពេលស្រាវជ្រាវរបស់គំរោងអេឌីអាយនេះ អង្គការវីអាយ បានរៀបចំក្រុមជួយខ្លួនឯងចំនួន២ក្រុម ដោយមានការសន្សំ និងឥណទាន ហើយក្រុមនីមួយៗមានដើមទុនចំនួន ២00 ដុល្លារ ហើយផ្តល់នូវជំនួយជារបស់របរចំនួន១២0មុខ ដោយក្នុងមួយមុខៗ មានតម្លៃ១00ដុល្លារ។ ដើម្បីកសាងសមត្ថភាពនៅតាមមូលដ្ឋាន អង្គការវីអាយ ផ្តល់ការងារជាបន្តបន្ទាប់ទៅដល់មន្រ្តីរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត និងស្រុក ដែលបានសហការធ្វើការងារជាមួយ ដើម្បីគ្រប់គ្រង និងអនុវត្តន៏ការងារនៅតាមសហគមន៏ ។

តាមពិត ការផ្លាស់ប្តូរយុទ្ធសាស្រ្តពីការផ្តល់សេវាស្តារលទ្ធភាពពលកម្មនៅក្នុងមជ្ឈមណ្ឌលនៅក្នុងទីរួមខេត្តព្រៃវែងទៅជាការផ្តល់សេវាស្តារលទ្ធភាពពលកម្មនៅតាមសហគមន៏មូលដ្ឋានវិញនោះ នឹងប្រើរយៈពេល១ទសវត្សរ៍ ទើបអាចដំណើរការបានពេញលេញ។ ក្នុងពេលថ្មីៗនេះ ការវាយតម្លៃដោយ UNICEF ទៅលើកម្មវិធី វីអាយ នៅខេត្តព្រៃវែង បានកត់សំគាល់ថា អ្នកដែលបានទទួលជំនួយពីអង្គការ វីអាយ ដែលបានសំភាសន៏ទាំងអស់ បានលើកឡើងពីការប្រែប្រួលជាវិជ្ជមាននៅក្នុងស្ថានភាពជីវិតរបស់ពួកគេ។ ក្នុងពេលវាយតម្លៃកម្មវិធីវីអាយ អង្គការ UNICEF ក៏វាយតម្លៃកម្មវិធីស្រដៀងគ្នានេះ ជាមួយអង្គការដទៃទៀតដែរ ហើយបានរកឃើញថា កម្មវិធីរបស់អង្គការដទៃទៀត ច្រើនតែផ្តោតខ្លាំងទៅលើការសន្សំ និងកំចី ជាជាងផ្តោតលើផ្នែកតស៊ូមតិ និងការបំផុសចលនាសហគមន៏ ដូច្នេះ នេះជាមេរៀនមួយសំខាន់សំរាប់កម្មវិធី វីអាយ ព្រោះថាក្រុមជួយខ្លួនឯងដែលបានរៀបចំកន្លងមកនេះគឺស្ថិតនៅក្នុងដំណាក់ការដំបូងនៅឡើយ។ ឧបសគ្គចំបងនៅក្នុងកម្មវិធីរបស់អង្គការវីអាយដែលបានរកឃើញ នៅក្នុងការវាយតម្លៃដោយ UNICEF គឺសមត្ថភាពបច្ចេកទេស និងកត្តាពេលវេលារបស់មន្រ្តីនៃមន្ទីរសង្គមកិច្ចខេត្តដែលបាន និងកំពុងសហការ ដើម្បីបំពេញការងារស្តារលទ្ធភាពពលកម្មនៅតាមសហគមន៏ឱ្យបានគ្រប់គ្រាន់ នៅក្នុងតំបន់ការងារដ៏ច្រើនរបស់អង្គការវីអាយ[៤០] ។

---

[40] Bruce Powell, *External Evaluation of UNICEF Support to Rehabilitation/Re-integration of Mine Victims and Disabled People,* (Phnom Penh: UNICEF Child Protection Program, December 2005)

## ការវិភាគលទ្ធផលរកឃើញពីការធ្វើអង្កេតនៅតំបន់ជនបទ

### មូលហេតុ និងផលវិបាករបស់ជនពិការដែលមានការលំបាកផ្នែកបំលាស់ទី

*ចំពោះបុគ្គលដែលពិការ*

ក្នុងចំណោមគ្រួសារទាំង ១៣៧ ដែលត្រូវបានសំភាសន៍ មាន១០៨គ្រួសារ (៧៩%) ដែលក្រុមស្រាវជ្រាវបានធ្វើសំភាសន៍ដោយផ្ទាល់ជាមួយជនពិការ ។ ដោយឡែក មាន២៩គ្រួសារដែលក្រុមស្រាវជ្រាវ មិនបានសំភាសន៍សមាជិកជាជនពិការ តែសំភាសន៍ជាមួយសមាជិកឯទៀតនៅក្នុងគ្រួសារដែលភាគច្រើនគឺជា ម្តាយរបស់ជនពិការ (ចំនួន១៧នាក់) ជាឪពុករបស់ជនពិការ (ចំនួន៦នាក់) និងជីដូនជីតារបស់ជនពិការ (ចំនួន៤នាក់) ។ លើសពីនេះទៅទៀត សាច់ញាតិរបស់ជនពិការក៏ត្រូវបានសំភាសន៍ ពោលគឺនៅតាមគ្រួសារ ដែលមានជនពិការក្រោមអាយុ ១៨ ឆ្នាំ ។ គេបានធ្វើសំភាសន៍បែបនេះជាមួយនឹងគ្រួសារចំនួន ២៣ក្នុងចំណោម គ្រួសារចំនួន ៣២ដែលមានជនពិការ ស្ថិតនៅក្នុងអាយុក្រោម ១៨ ឆ្នាំ ។

សរុបទៅ ការអង្កេតធ្វើទៅលើបុរសនិងកុមារាពិការចំនួន ៧៩ នាក់ ហើយនិងនារីនិងកុមារីពិការចំនួន ៥៨ នាក់ ។ អាយុគិតជាមធ្យមរបស់ជនពិការប្រុសគឺ ៣៨ ឆ្នាំ ។ អាយុគិតជាមធ្យមរបស់ជនពិការស្រីគឺ ៣៣ ឆ្នាំ ។ នៅក្នុងចំណោមជនពិការប្រុសចំនួន ៧៩ នាក់ មាន១៤ នាក់ (១៨%) គឺមានអាយុក្រោម ១៨ ឆ្នាំ និង ៥៥ នាក់ (៧0%) គឺមានអាយុចន្លោះពី ១៨-៥៩ ឆ្នាំ ហើយ ១0 នាក់ (១៣%) មានអាយុចាប់ពី ៦0 ឆ្នាំឡើងទៅ ។ ផ្ទុយទៅវិញ ក្នុងចំណោមមនុស្សស្រីពិការសរុបចំនួន ៥៨ នាក់ មាន ១៨ នាក់ (៣១%) មានអាយុក្រោម ១៨ ឆ្នាំ ៣២ នាក់ (៥៥%) មានអាយុចន្លោះពី ១៨-៥៩ ឆ្នាំ និង មាន៨ នាក់ (១៤%) ដែលមានអាយុចាប់ពី ៦0ឆ្នាំឡើងទៅ ។ ភាគរយខ្ពស់នៃមនុស្សស្រីពិការដែលមានអាយុក្រោម ១៨ ឆ្នាំ ធ្វើអោយយើងកត់សំគាល់ថា បញ្ហាពិការភាពនៅតែបន្តមានក្នុងចំណោមកុមារីមកទល់នឹងបច្ចុប្បន្ននេះ ទោះបីជាគេមិនទាន់ប្រាកដក្នុងចិត្តថា តើតួលេខដែលលើកឡើងនេះ តំណាងអោយនិន្នាការរួមឬយ៉ាងណាក៏ដោយ ។

ជាទូទៅ ជនពិការទាំង ១៣៧នាក់ ដែលត្រូវបានអង្កេត ទទួលធ្លាក់ខ្លួនពិការក្នុងរយៈពេលគិតជាមធ្យមចំនួន ១៨,៧ ឆ្នាំមកហើយ ។ នៅពេលដែលគេពិនិត្យអោយបានជិតដល់បន្ថែមទៀត ទើបឃើញថា ៤៤,៥% ក្នុងចំណោមអ្នកពិការក្នុងការអង្កេតនេះ បានធ្លាក់ខ្លួនពិការក្នុងអំឡុងណាមួយដែលគិតចាប់ពីឆ្នាំ ១៩៩២ រហូតមកទល់នឹងពេលស្រាវជ្រាវនៅឆ្នាំ ២00៥ នេះ។ ២៩,៩%បានធ្លាក់ខ្លួនពិការក្នុងចន្លោះពេលដែលគិតចាប់តាំងពីរដ្ឋាភិបាលកម្ពុជាដែលលើកបន្តុបដោយប្រទេសវៀតណាមនាឆ្នាំ ១៩៧៩ រហូតដល់កិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសឆ្នាំ ១៩៩១។ ជនពិការ៦,៦% បានទទួលរងពិការភាពក្នុងចន្លោះពេលជំនាន់ ប៉ុល ពត គឺចាប់ពីឆ្នាំ ១៩៧៥-១៩៧៨ និងជនពិការ ១៩%ផ្សេងទៀត បានទទួលរងពិការភាពតាំងពីមុនឆ្នាំ ១៩៧៥ មកម្ល៉េះ ។

## *បុព្វហេតុនៃពិការភាព*

បុព្វហេតុនៃពិការភាពគឺមានប្រហែលពាក់កណ្តាលនៃអ្នកដែលត្រូវបានសំភាសន៍ បានបញ្ជាក់ថា បណ្តាលមកពីជំងឺ និង រោគា (សូមមើលតារាងទី១) ។ បុព្វហេតុបន្ទាប់គឺ គ្រោះថ្នាក់ និងពិការពីកំណើត ។ ដោយឡែក គេឃើញមានចំនួនតិចដែលពិការដោយសារសង្គ្រាម និង គ្រាប់មីន ។ នៅពេលមានការចោទសួរអំពី ប្រភេទនៃពិការភាពជាក់ស្តែង ទើបឃើញមានយល់ច្រឡំលើការប្រើពាក្យពេចន៍ ដែលជាការធ្វើអោយមានការពិបាកក្នុងការរៀបរាប់អោយបានច្បាស់លាស់នៅត្រង់ផ្នែកនេះ ។ ក្នុងចំណោមពិការភាពដែលបានលើកឡើងច្រើនជាងគេគឺ បណ្តាលមកពីជំងឺស្វិតដៃជើង ដាច់ដៃជើង ការបាក់ឆ្អឹង ការស្លាប់អវៈយវៈទាំងបួន ខ្វិនជើងទាំងពីរ ស្លាប់មួយ ចំហៀងខ្លួន ពិការពីកំណើត ពិការខួរក្បាល ស្វិតសាច់ដុំ ជើងកោង ខ្សោយសាច់ដុំ និងជើងខ្វេ ។

ទាក់ទងនឹងបុព្វហេតុនៃពិការភាព មានលក្ខណៈមួយចំនួនត្រូវបានគេមើលឃើញ ។ ឧទាហរណ៍ ជនពិការដោយសារគ្រាប់មីន ៦នាក់ ហើយជនរងគ្រោះដោយសារសង្គ្រាមចំនួន ៨ នាក់ក្នុងចំណោម ៩ នាក់ គឺសុទ្ធតែបុរសដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ ។ លើសពីនេះទៀត មានបុរស ៦នាក់ដែលរងគ្រោះដោយសារគ្រាប់មីន ហើយបុរស ៦ នាក់ក្នុងចំណោម ៨ នាក់ដែលរងគ្រោះដោយសារសង្គ្រាម បានធ្លាក់ខ្លួនពិការដោយសារគេធ្វើទាហ៊ាន ។ ការសំភាសន៍ជាមួយនឹងមនុស្សសំខាន់ៗបង្ហាញថា ការរងរបួសដោយសារគ្រាប់មីន និងសង្គ្រាមរបស់អតីតយុទ្ធជន គឺ កើតមាននៅក្រៅស្រុកព្រៃវែង ពិសេសគឺនៅតំបន់ភាគពាយ័ព្យនៃប្រទេស ។ ដោយសារស្រុកព្រៃវែង មិនមែនជាតំបន់មានគ្រាប់មីនឬមានការបាញ់ប្រហារគ្នាខ្លាំងក្លានោះ ទើបនារីនិងកុមារជាទូទៅ មិនរងគ្រោះធ្លាក់ខ្លួនពិការដោយសារសង្គ្រោមទេ ។

| **តារាងទី ១: បុព្វហេតុនៃពិការភាពរបស់ជនពិការ ស្រុកព្រៃវែង ខែ កញ្ញា ឆ្នាំ ២០០៥** | | |
|---|---|---|
| | **ចំនួន** | **ភាគរយ** |
| ជំងឺ រោគា | 70 | 51,1 % |
| គ្រោះថ្នាក់ | 31 | 22,6 % |
| ពិការពីកំណើត | 21 | 15,3 % |
| សង្គ្រាម | 9 | 6,6 % |
| គ្រាប់មីន | 6 | 4,4 % |
| **n = 137** | | |

ដូចគ្នានេះដែរ មានភាគរយបុរសច្រើនដែលពិការដោយសារគ្រោះថ្នាក់ ។ ២៧%នៃបុរស និងកុមារា (២១ នាក់ក្នុងចំណោម ៧៩ នាក់) ពិការដោយសារគ្រោះថ្នាក់ ។ នារី និងកុមារីចំនួនតែ ១៧% (១០ នាក់ ក្នុងចំណោម ៥៨ នាក់) តែប៉ុណ្ណោះ ដែលពិការដោយសារគ្រោះថ្នាក់ ។ បញ្ហានេះអាចនិយាយបានថា ដោយសារបុរសធ្វើដំណើរ និងធ្វើការងារដែលប្រឈមនឹងគ្រោះថ្នាក់ច្រើនជាង ។ មានជនពិការចំនួនតែ ៩% (៣នាក់ ក្នុងចំណោម ៣២ នាក់) ដែលមានអាយុក្រោម ១៨ ឆ្នាំរងគ្រោះដោយសារគ្រោះថ្នាក់ ។ មាន ៣៩% (៧នាក់ ក្នុងចំណោម ១៨ នាក់) នៃជនពិការដែលមានអាយុចាប់ពី ៦០ ឆ្នាំឡើងទៅ ក៏ពិការដោយសារគ្រោះថ្នាក់ដែរ ។ ចំណុចនេះបង្ហាញថា មនុស្សចាស់ងាយរងនឹងភាពពិការ ដោយសារគ្រោះថ្នាក់ ។

ជារួម បុព្វហេតុដែលធំជាងគេនៃពិការភាពនៅក្នុងតំបន់នោះគឺ ជំងឺ និង រោគា ដែលភាគច្រើនអាចការពារបាន ហើយបញ្ហាទាំងនេះកើតឡើងដោយសារប្រព័ន្ធសុខាភិបាលនៅក្នុងប្រទេសកម្ពុជា ត្រូវបានបំផ្លិចបំផ្លាញដោយសារសង្គ្រាម និងការមិនយកចិត្តទុកដាក់ជាយូរឆ្នាំមកហើយ ។ ដូច្នេះ អ្នកដែលធ្លាក់ខ្លួនពិការដោយសារជំងឺទាំងអស់ដែលបានសំភាសន៏រាប់ទាំងស្ត្រី កុមារី និងទាំងមនុស្សចាស់ក្មេង អាចចាត់ទុកថា ជាជនរងគ្រោះដោយប្រយោលពីសង្គ្រាម ។ តាមពិត ស្ត្រី និងកុមារីដែលធ្លាក់ខ្លួនពិការដោយសារជំងឺ មានភាគរយខ្ពស់ជាងបុរស និងកុមារា ។ ជាក់ស្តែង ស្ត្រី និងកុមារីចំនួន ៦២% (៣៦ នាក់ក្នុងចំណោម ៥៨ នាក់) ធ្លាក់ខ្លួនពិការដោយសារជំងឺ រីឯបុរស និងកុមារាចំនួនតែ ៤៣% (៣៤ នាក់ក្នុងចំណោម ៧៩ នាក់) ដែលធ្លាក់ខ្លួនពិការដោយសារជំងឺដែរ ។ ចំណុចនេះអាចបញ្ជាក់បានថា គ្រួសារ និងសង្គមហាក់ដូចជាយកចិត្តទុកដាក់លើសេចក្តីត្រូវការផ្នែកសុខភាពនៃសមាជិកគ្រួសារដែលជាបុរសច្រើនជាង ។ លើសពីនេះទៀត ពិការភាពដែលបណ្តាលមកពីជំងឺ មានអត្រាខ្ពស់ជាងអត្រាមធ្យមក្នុងចំណោមមនុស្សដែលមានអាយុយក្រោម ១៨ ឆ្នាំ (៥៩%) និង ក្នុងចំណោមមនុស្សដែលមានអាយុចាប់ពី ៦០ ឆ្នាំឡើងទៅ (៦១%) ។

ការកើតមកមិនគ្រប់លក្ខណៈដែលបណ្តាលអោយពិការឃើញថា មានច្រើនក្នុងចំណោមនារី និងកុមារី (១៩%) ចំណែកឯបុរស និងកុមារាមានចំនួនតែ១៣%ប៉ុណ្ណោះ។ ប្រការគួរអោយកត់សំគាល់ដែរនោះគឺ ការកើតមកមិនគ្រប់លក្ខណៈ មានចំនួនខ្ពស់នៅក្នុងចំណោមមនុស្សដែលមានអាយុក្រោម ១៨ ឆ្នាំ (៣១%) ។ ចំណុចនេះ បញ្ជាក់អោយឃើញពីកង្វះខាតធ្ងន់ធ្ងរផ្នែកអាហាររូបត្ថម្ភនៅក្នុងចំណោមមាតាដែលមានផ្ទៃពោះ ការយល់ដឹង និងទំលាប់របស់គេក្នុងការថែទាំខ្លួនមុនពេលឆ្លងទន្លេ និងការខ្វះលទ្ធភាពក្នុងការទទួលបាន សេវាសុខភាពក៏រិតសមស្របដែលអាចទទួលយកបាន ។

### *ផលប៉ះពាល់ទៅលើបំលាស់ទី*

ពិការភាពរាងកាយមានផលប៉ះពាល់ដល់ការផ្លាស់ទីរបស់ជនពិការដែលត្រូវបានអង្កេតកន្លងមកនេះ ។ ទំនោរមួយដែលគេមើលឃើញគឺថា កាលណារយៈចំងាយកាន់តែឆ្ងាយពីផ្ទះរបស់គេ ជនពិការអាចផ្លាស់ទីទៅកាន់ទី ឆ្ងាយនោះក្នុងកំរិតមិនញឹកញាប់ដូចនៅទីជិតទេ (សូមមើលតារាងទី ២) ។ ប៉ុន្តែគេត្រូវមានការប្រុងប្រយ័ត្ន នៅពេលដែលបកស្រាយទិន្នន័យទាំងនេះ ។ តារាងទី ២ គូសបញ្ជាក់ពីជនពិការទាំង ១៣៧ ដែលត្រូវបានអង្កេត ដោយរួមទាំងបុគ្គលដែលមានអាយុក្រោម ១៥ឆ្នាំ និងចាប់ពីអាយុ ៦០ឆ្នាំឡើងទៅ ។ដូច្នេះ មនុស្សក្នុងវ័យនេះ ជានិច្ចកាលមិនអាចធ្វើដំណើរបានច្រើនទៅឆ្ងាយពីកន្លែងរស់នៅរបស់គេទេ បើទោះបីជាគេមិនពិការក្តី ហើយចំពោះអ្នកពិការកាន់តែពិបាកថែមទៀត។ នេះមិនមែនជារឿងគួរឱ្យភ្ញាក់ផ្អើលទេ ។ មានជនពិការតែ ៤ នាក់ ក្នុងចំណោមជនពិការចំនួន ២៦ នាក់ដែលមានអាយុក្រោម ១៥ ឆ្នាំ និងជនពិការ ៣ នាក់ ក្នុងចំណោម ១៨ នាក់មានដែលមានអាយុចាប់ពី ៦០ ឆ្នាំឡើង បានធ្វើដំណើរទៅដល់ទីរួមខេត្តព្រៃវែង ។ ទោះបីជាមានករណីខ្លះៗដូចលើកឡើងមកនេះក្តី តែទិន្នាការជាទូទៅបង្ហាញឃើញច្បាស់ថា ពួកគេមិនសូវធ្វើដំណើរបានឆ្ងាយទេ ពោលគឺ កាលណាទីតាំងនៅឆ្ងាយពីភូមិដ្ឋានដែលពួកគេរស់នៅ ការធ្វើដំណើររបស់គេថយចុះគួរឱ្យកត់សំគាល់ ។

**តារាងទី ២: ការធ្វើដំណើររបស់ជនពិការនៅស្រុកព្រៃវែង**
**ខែ កញ្ញា ឆ្នាំ ២០០៥**

| | បច្ចុប្បន្ន អាចផ្លាស់ទីខ្លួនឯង | ជនពិការប្រើប្រាស់ឧបករណ៍ | | មុនពេលទទួលបានឧបករណ៍ ជនពិការមិនអាចផ្លាស់ទី | |
|---|---|---|---|---|---|
| | ចំនួន | ចំនួន | %នៃអ្នកផ្លាស់ទីខ្លួនឯង និងប្រើឧបករណ៍ | ចំនួន | %នៃអ្នកផ្លាស់ទីខ្លួនឯង និងប្រើឧបករណ៍ |
| ផ្លាស់ទីនៅជុំវិញផ្ទះ | 120 | 54 | 45% | 28 | 52% |
| ទៅបន្ទប់ទឹក | 120 | 49 | 41% | 30 | 61% |
| ទៅងូតទឹក | 118 | 48 | 41% | 31 | 64% |
| ទៅលេងផ្ទះអ្នកជិតខាង | 115 | 50 | 43% | 34 | 68% |
| ទៅវត្តដែលនៅជិតៗ | 97 | 39 | 40% | 29 | 74% |
| ទៅផ្សារដែលនៅជិតៗ | 80 | 33 | 41% | 23 | 70% |
| ទៅសាលាឃុំ | 74 | 27 | 36% | 18 | 67% |
| ទៅទីប្រជុំជនព្រៃវែង | 63 | 23 | 34% | 19 | 83% |
| **n = 137** | | | | | |

ដូចគ្នានេះដែរ តាមរយៈការអង្កេតគេមើលឃើញថា ការផ្លាស់ទីមិនមែនសុទ្ធតែប្រើឧបករណ៍ជំនួយទាំងអស់ ទើបអាចធ្វើដំណើរបាននោះទេ ។ ជាក់ស្តែង ភាគច្រើននៃអ្នកដែលធ្វើដំណើរដោយខ្លួនឯងបាន នៅក្នុងចំណាត់ថ្នាក់និមួយៗ ក្នុងចំណោមចំណាត់ថ្នាក់ទាំង៨ ដែលបានបង្ហាញនៅក្នុងតារាង ២ គឺមិនមានប្រើឧបករណ៍ជំនួយទេ ។ អ្នកដែលប្រើឧបករណ៍ជំនួយ សំរាប់ការធ្វើដំណើរដោយខ្លួនឯងដើម្បីធ្វើដំណើរនៅជុំវិញផ្ទះរបស់គេ មានពី ៤៥% ហើយសំរាប់ធ្វើដំណើរដោយខ្លួនឯងមកទីរួមខេត្តព្រៃវែងវិញ ថយចុះមកត្រឹម ៣៤% (សូមមើលតារាងទី ២) ។

ចំណុចមួយដែលគួរអោយចាប់អារម្មណ៍គឺថា ឧបករណ៍ ពី ២៧-៣៣%ដែលជនពិការបានប្រើនៅក្នុងចំណាត់ថ្នាក់ទាំង៨គឺ ធ្វើដោយខ្លួនឯង។ ចំណុចនេះបញ្ជាក់ពីការពឹងពាក់លើខ្លួនឯងរបស់ជនពិការ បំណងប្រាថ្នា និងសមត្ថភាពរបស់គេនៅក្នុងការជួយខ្លួនឯង។ ទន្ទឹមនឹងនេះដែរ ឧបករណ៍ ពី៦៥-៧៣%ដែលជនពិការបានប្រើប្រាស់នៅក្នុងចំណាត់ថ្នាក់ទាំង៨នេះដែរគឺ ត្រូវបានផ្តល់អោយដោយអង្គការ VI ។ ចំណុចនេះបញ្ជាក់ពីតួនាទីដ៏សំខាន់របស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងការផ្តល់ឧបករណ៍ដល់ជនពិការនៅក្នុងតំបន់ស្រាវជ្រាវ ។ ដោយឡែក រដ្ឋាភិបាលមិនបានផ្តល់ជាឧបករណ៍អ្វីដល់ជនពិការនៅក្នុងតំបន់ស្រាវជ្រាវនេះទេ ។

ជារួម ឧបករណ៍ដែលផ្តល់ឱ្យជនពិការ បានផ្តល់អត្ថប្រយោជន៍ដល់អ្នកដែលប្រើប្រាស់។ តាមរយៈឧបករណ៍នេះជួយឱ្យអ្នកដែលពីពេលមុនមិនអាចធ្វើដំណើរបាន មានលទ្ធភាពអាចធ្វើដំណើរបាននាពេលបច្ចុប្បន្ន ។ ជាក់ស្តែង អត្រានៃអ្នកដែលអាចផ្លាស់ទីបាន មានពី ៥២% អាចធ្វើដំណើរខ្លួនឯងបាននៅជុំវិញផ្ទះ រហូតដល់ទៅ ៨៣% អាចទៅទីរួមខេត្តព្រៃវែងដោយខ្លួនឯងបាន តែពីមុនមានឧបករណ៍ ពួកគេមិនអាចផ្លាស់ទីបានទេ (សូមមើលតារាងទី ២) ។

## *ផលវិបាកសំរាប់គ្រួសារ*

ការមានសមាជិកណាម្នាក់ជាជនពិការ ធ្វើអោយគ្រួសារមានបញ្ហាពិបាកច្រើន នៅក្នុងចំណោមគ្រួសារដែលបានអង្កេត។ បញ្ហាប្រឈមមួយគឺទាក់ទងនឹងមានកំលាំងពលកម្មគ្រប់គ្រាន់ឬមិនគ្រប់គ្រាន់ សំរាប់បំពេញតម្រូវការផ្នែកការងាររកចំណូល និងការងារមិននាំមកនូវប្រាក់ចំណូលក្នុងគ្រួសារ ។ ចំនួនសមាជិកនៅក្នុងគ្រួសារចំនួន ១៣៧ ដែលបានអង្កេតគិតជាមធ្យមគឺ ៥.៣១ (គឺមានជាមធ្យម ប្រុសចំនួន ២.៤៨ និងស្រី ២.៨៣)។ ដូចគ្នានេះដែរ ចំនួនគិតជាមធ្យមនៃសមាជិកនៅក្នុងគ្រួសារទាំង ១៣៧ ដែលបានអង្កេត បានរួមចំណែកដល់ការចិញ្ចឹមជីវភាពគ្រួសារគឺ ២.៥១ (គិតជាមធ្យមគឺ ១.0៨ សំរាប់បុរស និង ១.៤៣ សំរាប់នារី) ។ ក្នុងចំណោមគ្រួសារចំនួន ១៣៧ ដែលត្រូវបានសំភាសន៏ មាន ៨៨ គ្រួសារ (៦៤%) បានលើកឡើងថា មិនមានសមាជិកគ្រប់គ្រាន់ ក្នុងការជួយទ្រទ្រង់ជីវភាពគ្រួសារ។ លើសពីនេះទៅទៀត មាន៥៦គ្រួសារ(៤១%) នៃគ្រួសារទាំង

១៣៧ដែលបានអង្កេត បាននិយាយថា តំរូវការសមាជិកក្នុងគ្រួសារដើម្បីមើលថែទាំជនពិការ បានកាត់បន្ថយនូវលទ្ធភាពរបស់គេយ៉ាងច្រើន នៅក្នុងការជួយរួមចំណែកដល់ជីវភាពគ្រួសារ ។

បញ្ហាមួយទៀតដែលគ្រួសារជនពិការប្រឈម គឺការរកលុយសំរាប់ថ្លៃសុខភាពរបស់ជនពិការ ។ ដោយសារគ្រួសាររបស់ពួកគេធ្វើស្រែ ដើម្បីគ្រាន់តែចិញ្ចឹមក្រពះ គ្រួសារខ្លះត្រូវខ្ចីលុយគេ ឬលក់ទ្រព្យសម្បត្តិ ដើម្បីបានលុយមកបំពេញតំរូវការ ។ ក្នុងចំណោមគ្រួសារទាំង ១៣៧ ដែលត្រូវបានអង្កេត មាន៧៣គ្រួសារ (៥៣% ) បាននិយាយថា គេបានខ្ចីលុយអ្នកដទៃ ដើម្បីយកមកមើលជំងឺរបស់ជនពិការនៅក្នុងគ្រួសារ ។ ទោះជាដូច្នេះក៏ដោយ ក្នុងចំណោមគ្រួសារទាំង៧៣ ដែលបានខ្ចីលុយគេ មាន ៥៦គ្រួសារ (៧៧%) បានសងបំណុលគេវិញអស់ហើយ ។

នៅក្នុងករណីភាគច្រើន ការលក់ទ្រព្យសម្បត្តិមានផលវិបាកធ្ងន់ធ្ងរសំរាប់គ្រួសារជាងខ្ចីលុយគេ ។ ជារួម មាន ៣៥ គ្រួសារ (២៥%) នៃគ្រួសារដែលបានអង្កេតទាំង ១៣៧ បានលក់ទ្រព្យសម្បត្តិរបស់គេក្រៅពីដីដែលគេមាន ដើម្បីមើលជំងឺរបស់សមាជិកគ្រួសារដែលពិការ ។ លើសពីនេះទៀត មាន ១៨ គ្រួសារ (១៣%) នៃគ្រួសារទាំង ១៣៧ ដែលបានអង្កេត បានលក់ដី ដោយសារសមាជិកពិការនៅក្នុងគ្រួសារមានជំងឺ ។ គួរឱ្យកត់សំគាល់ផងដែរ មាន៨ គ្រួសារ ក្នុងចំណោមគ្រួសារទាំង ១៨ ដែលបានលក់ដីហើយ បានក្លាយជាអ្នកអត់ដីនាពេលបច្ចុប្បន្ននេះ ។ ជាងនេះទៅទៀត មាន១០គ្រួសារ (៧%) នៃគ្រួសារដែលត្រូវបានអង្កេតទាំង១៣៧ បានបញ្ចាំដីស្រែ ដោយសារសមាជិកពិការនៅក្នុងគ្រួសារមានជំងឺ ។ តាមរយៈការលក់ និងបញ្ចាំដី គ្រួសារបានបាត់បង់ទ្រព្យសម្បត្តិដ៏សំខាន់នេះសំរាប់រកចំណូលដល់គ្រួសារ ហើយទាំងនេះរឹតតែកាត់បន្ថយលទ្ធភាពរបស់គេបន្ថែមទៀត នៅក្នុងការដោះស្រាយបញ្ហា ឬតម្រូវការរបស់សមាជិកគ្រួសារដែលពិការខាងរាងកាយ ។

## ការប្រកបរបរចិញ្ចឹមជីវិតរបស់គ្រួសារដែលមានសមាជិកពិការ

### *កម្មសិទ្ធិដីធ្លី*

ជាទូទៅ គ្រួសារជនពិការជួបប្រទះនូវការខ្វះខាតដីធ្លី ។ នៅក្នុងចំណោមគ្រួសារទាំង១៣៧ ដែលបានអង្កេត មាន ១០៩ គ្រួសារ (៨០%) មានដីស្រែ នេះមានន័យថា ២៨ គ្រួសារ (២០%) នៃគ្រួសារដែលបានសំភាសន៍ មិនមានដីទេ ។ ទំហំដីជាមធ្យមរបស់គ្រួសារចំនួន ១០៩ ដែលមានដី គឺ ១,០៤ ហិកតា ។ មានតែ ៩ គ្រួសារ (៨%) នៃគ្រួសារទាំង ១០៩ មានដីលើសពី ២ ហិកតា ។ ផ្ទុយទៅវិញ មាន៤៤ គ្រួសារ (៤០%) នៃគ្រួសារទាំង ១០៩ មានដីកន្លះហិកតា ឬតិចជាងនេះ ។ ដោយឡែក មានគ្រួសារចំនួន ២៨ គឺពុំមានដីទាល់តែសោះ ហើយ៤៤ គ្រួសារគឺស្ទើរតែគ្មានដីសោះ (មានន័យថា មានដីតិចជាង ០,៥ ហិកតា ឬតិចជាងនេះ) ដូច្នេះសរុបមក គ្រួសារចំនួន ៧២ (៥២%) ពុំមានដីគ្រប់គ្រាន់ទេ ។

**រឿងរ៉ាវ របស់ អ៊ុក វុទ្ធី និង ជុំ សោភា**

ជុំ សោភា កើតមកពុំមានដៃស្តាំទេ ហើយដៃឆ្វេងរបស់នាងក៏ពិការដែរ ដោយមានតែម្រាមដៃពីរ និងមេដៃមួយ ប៉ុណ្ណោះ។ ថ្វីបើនាងពិការដូច្នេះ តែឪពុកម្តាយសោភាបានរៀបចំគូរស្រករឱ្យនាងជាមួយនឹងអ៊ុក វុទ្ធី ដោយរៀបចំពិធីមង្គលការតូចមួយនៅផ្ទះរបស់ក្រុមគ្រួសារនាងនៅខេត្តព្រៃវែង ។ វុទ្ធី មកពីខេត្តកណ្តាល ហើយមានអាយុ តិចជាងសោភាយ៉ាងច្រើន ។ ពួកគេទាំងពីនាក់បានរៀបការអស់រយៈពេលជាង២០ឆ្នាំហើយ។ វុទ្ធី បានរំលឹកឡើងវិញថា គាត់មានការអាណិតដល់ប្រពន្ធរបស់គាត់ ពេលដែលគាត់បានជួបនាងដំបូង ។ ក្រោយមក គូរស្រករនេះ រស់នៅជាមួយគ្នាមានកូនប្រុសចំនួនបីនាក់។

ក្រោយពីរៀបការរួច វុទ្ធីបានចូលបំរើក្នុងជួរកងទ័ព ។ នៅឆ្នាំ ១៩៩១ គាត់ធ្វើជាកងទ័ពនៅខេត្តបាត់ដំបង ហើយ ពេលនោះដៃស្តាំរបស់គាត់ត្រូវបានពិការដោយសារមីន។ បន្ទាប់ពីគ្រោះថ្នាក់នោះភ្លាម គាត់ក៏បានលាឈប់ពីជួរ កងទ័ព ហើយត្រលប់មករស់នៅក្នុងខេត្តព្រៃវែងវិញ។ ដូច្នេះ នាពេលបច្ចុប្បន្ននេះ គាត់ជាជនពិការដែលមានប្រពន្ធក៏ជាជនពិការដែរ។

ដោយសារភាពពិការនេះ វុទ្ធី និង សោភា ជួបប្រទះនូវការលំបាកក្នុងការទ្រទ្រង់ជីវភាពគ្រួសាររបស់គេ ។ ជាទូទៅ គូរស្រករនេះអាចប្រមូលផលស្រូវវស្សាបានមួយតោនពីផ្ទៃដីស្រែទំហំកន្លះហិកតាដែលគេមាន នៅស្រុកព្រៃវែង ។ ប៉ុន្តែ ដោយសារពិបាកក្នុងការធ្វើស្រែគឺ ពួកគេបានជួលកំលាំងពលកម្មអ្នកដទៃ ដើម្បីធ្វើការភ្ជួររាស់ ដកស្ទូង ច្រូតកាត់ និងដឹកជញ្ជូន ស្រូវពីស្រែមកទុកនៅផ្ទះ ។ ដូច្នេះ ផលស្រូវដែលគេប្រមូលបាន ត្រូវបានកាត់បន្ថយដោយត្រូវចំណាយទៅលើការជួលកំលាំងពលកម្ម។ គ្រួសារវុទ្ធីមានកង់មួយ គាត់ក៏បាន ប្រើប្រាស់កង់នោះ ដើម្បីទិញបន្លែនៅផ្សារជិតផ្ទះ យកទៅលក់នៅតាមភូមិ ។ គាត់មិនបានទិញ និងលក់ទំនិញ វេចខ្ចប់ចេញពីរោងចក្រទេ ដោយសារធ្ងន់ពេកគាត់មិនអាចយួរបាន។ សោភា ក៏បានប្រើដៃឆ្វេង និងខ្លួនរបស់ គាត់ទប់កង់ ដើម្បីដឹកជញ្ជូនត្រីដែលទិញពីអ្នកនេសាទ ទៅលក់នៅតាមភូមិ ។ គូស្រករនេះ បានដាំត្រកួន និងស្ពៃ ព្រមទាំងចិញ្ចឹមមាន់ផងដែរ។ ជួនកាលវុទ្ធី ធ្វើការងារលក់កំលាំងពលកម្មដូចជា រែកដីនៅក្នុងភូមិជាដើម។

នៅឆ្នាំ ២០០២ កូនប្រុសរបស់វុទ្ធី និងសោភា ដែលមានអាយុ១៨ ឆ្នាំ បានធ្វើចំណាកស្រុកទៅប្រទេសថៃ ជាមួយនឹងអ្នកភូមិផ្សេងទៀត។ គាត់បានផ្ញើប្រាក់មកផ្ទះចំនួនពីរលើក ។ បន្ទាប់មក រឿងនឹកស្មានមិនដល់បានកើតឡើង ឪពុកម្តាយបានដឹងថា កូនប្រុសនេះបានស្លាប់ ហើយត្រូវបានគេបូជានៅឯប្រទេសថៃ។ អ្វីដែលគាត់ បានទទួលចុងក្រោយនេះគឺ ត្រឹមតែរូបថតសាកសពរបស់កូនមួយសន្លឹកដែលមិត្តភក្តិ បានថតទុកជាអនុស្សាវរីយ៍។ កាលពីឆ្នាំកន្លងទៅ កូនទីពីររបស់គាត់ដែលមានអាយុ១៦ឆ្នាំ បានបួសជាសង្ឃ ហើយបានគង់នៅវត្តមួយ នៅ ស្រុកមួយផ្សេងទៀតនៅក្នុងខេត្តនេះ ។ កូនពៅរបស់គាត់ដែលរស់នៅជាមួយសព្វថ្ងៃនេះ មានអាយុ១០ឆ្នាំ ហើយបានចូលរៀននៅសាលាបឋមសិក្សា។

វុទ្ធី និង សោភា បានប្រាប់ឱ្យដឹងថា ពួកគេមិនត្រូវបានអ្នកដទៃអញ្ជើញឱ្យចូលរួមនៅក្នុងពិធីអាពាហ៍ពិពាហ៍ និងបុណ្យទានផ្សេងៗទេ ដោយសារពួកគេក្រីក្រ។ ទោះជាដូច្នេះក៏ដោយ ជួនកាល វុទ្ធី ជួយរែកទឹក និងពុសអុស សំរាប់ចំអិនអាហារនៅក្នុងពិធីផ្សេងៗបែបនេះដែរ រួចហើយចូលរួមបរិភោគអាហារជាមួយគេក្នុងពិធីនោះ។ ក្នុងពេលជាមួយគ្នានេះដែរ វុទ្ធីត្រូវ

បានប្រធានភូមិអញ្ជើញឱ្យចូលរួមនៅក្នុងការប្រជុំធ្វើផែនការឃុំ និងប្រជុំ ផ្សព្វផ្សាយពត៌មានផ្សេងៗទៀត ។ ក្នុងខណៈពេលដែលក្រុមស្ត្រីឯទៀតៗ បានចូលរួមនៅក្នុងការប្រជុំទាំងនោះ សោភា ពុំហ៊ានចូលរួមទេ ដោយសារពិការភាពរបស់គាត់ ។ ចាប់តាំងពីឆ្នាំ ១៩៩៣មក វុទ្ធី និង សោភា បាន ចូលរួមបោះឆ្នោតជាតិទាំងបីលើក និងបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ផងដែរ ។

ចាប់តាំងពីឆ្នាំ ១៩៩៥ វុទ្ធី បានទទួលប្រាក់ខែ ៥០.០០០ រៀល (១២,៥ ដុល្លារអាមេរិក) ក្នុងមួយខែ ពី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងនាមជាអតីតយុទ្ធជនពិការ ។ គាត់បានអះអាងថា ទោះបីជាជំនួយឧបត្ថម្ភនេះ មិនគ្រប់គ្រាន់ក្តី តែបើគ្មានជំនួយនេះទេ ស្ថានភាពគ្រួសាររបស់គាត់ និងកាន់តែលំបាក ខ្លាំងជាងនេះទៀត ។

ក្នុងចំណោមគ្រួសារទាំង១៣៧ដែលត្រូវបានអង្កេត មាន១៣គ្រួសារ (៩%) នៅពេលនេះ បានជួលដីស្រែគេ ។ ទំហំដីគិតជាមធ្យមដែលជួលដោយគ្រួសារទាំង ១៣ នោះគឺ ០,៦៤ ហិកតា ។ ភាគច្រើននៃគ្រួសារទាំងនេះ (៧ គ្រួសារ) បានជួលដីកន្លះហិកតា ឬតិចជាងនេះ ។ ចំណុចមួយដែលគួរអោយកត់សំគាល់គឺថា ១២ គ្រួសារក្នុងចំណោម ១៣ គ្រួសារដែលបានជួលដីស្រែ គេក៏មានដីស្រែខ្លួនឯងដែរ ដែលធ្វើអោយចំនួនអ្នកមានដី ឬអ្នកជួលដីមាន១១០គ្រួសារ ។

ជារួម ២២ គ្រួសារ (១៦%) នៃគ្រួសារទាំង១៣៧ដែលបានសំភាសន៍ បានលក់ដីស្រែ ដោយគិតជាមធ្យមគឺមួយគ្រួសារបានលក់ដីចំនួន ០,៩២ ហិកតា ។ ស្ទើរតែពាក់កណ្តាល (១០គ្រួសារ) នៃគ្រួសារទាំង២២ ដែលបានលក់ដី បានក្លាយជាអ្នកអត់ដី នាពេលបច្ចុប្បន្ននេះ ។ ដូចគ្នានេះដែរ ១៣គ្រួសារ (៩%) នៃគ្រួសារដែលបានសំភាសន៍ទាំង ១៣៧ បានបញ្ចាំដីស្រែរបស់គេ ដោយគិតជាមធ្យមគឺកន្លះហិកតាក្នុងមួយគ្រួសារ ។ ភស្តុតាងបញ្ជាក់នូវការប្រៀបធៀបតួលេខខាងដើម បានបង្ហាញថា ដីស្រែដែលបានលក់ ឬបញ្ចាំភាគច្រើន (ប៉ុន្តែ មិនមែនទាំងអស់នោះទេ) គឺដោយសារបង់ថ្លៃសុខភាពសំរាប់សមាជិកគ្រួសារដែលពិការ ។

## *ផលិតកម្មកសិកម្ម*

មាន ១០៥គ្រួសារ (៩៥%) ក្នុងចំណោម ១១០ គ្រួសារដែលមាន និង/ឬ ជួលដីស្រែគេ បានធ្វើការដាំដុះ កាលពីឆ្នាំកន្លងទៅនេះ ហើយក្នុងចំណោមអ្នកដែលបានដាំដុះនេះ មាន ៣១គ្រួសារបានធ្វើទាំងស្រែវស្សា និងស្រែប្រាំង ។ រីឯ ២គ្រួសារផ្សេងទៀត បានធ្វើតែស្រែប្រាំង ។ ដោយឡែក មាន ៧២គ្រួសារបានធ្វើតែស្រែវស្សាប៉ុណ្ណោះ ។ ក្នុងឆ្នាំកន្លងទៅនេះ គ្រួសារទាំង ៣១ ដែលធ្វើស្រែវស្សា និងស្រែប្រាំង បានដាំដុះលើផ្ទៃដីស្រែគិតជាមធ្យមចំនួន ១.៩៧ ហិកតា ហើយទទួលបានទិន្នផលជាមធ្យម ៣.១៩១គីឡូក្រាម ។ ចំណែកឯ ២គ្រួសារដែលធ្វើតែស្រែប្រាំង បានធ្វើដាំដុះលើផ្ទៃដីស្រែគិតជាមធ្យមមួយហិកតា ហើយទទួលបានទិន្នផលជាមធ្យម ២.០០០គីឡូក្រាម ។ ដោយឡែក

គ្រួសារទាំង៧២ ដែលបានធ្វើតែស្រែវស្សាវិញនោះ បានដាំដុះលើផ្ទៃដីស្រែគិតជាមធ្យមចំនួន ០.៨៥ហិកតា ហើយទទួលបានទិន្នផលជាមធ្យម ៩៨៧ គីឡូក្រាម ។

ជាក់ស្តែង ទិន្នផលស្រូវក្នុងចំណោមគ្រួសារដែលមានជនពិការ មានកំរិតខុសៗគ្នា ។ ចំពោះគ្រួសារដែលបានធ្វើស្រែវស្សា និងស្រែប្រាំងបានទទួលផលច្រើន។ ចំពោះពីរគ្រួសារដែលបានធ្វើតែស្រែប្រាំង បានទទួលទិន្នផលជាមធ្យម។ រីគ្រួសារដែលបានធ្វើតែស្រែវស្សាវិញ បានទទួលផលយ៉ាងទាបបំផុត ហើយពួកគេបានប្រឈមមុខនឹងការខ្វះស្បៀងយ៉ាងខ្លាំង ។ ដូច្នេះ គ្រួសារដែលបានធ្វើស្រែវស្សា ហើយមិនមានលទ្ធភាពធ្វើនៅរដូវប្រាំង ឃើញថាស្ថិតនៅក្នុងស្ថាបភាពលំបាកលំបិន ។

ក្នុងចំណោមគ្រួសារដែលធ្វើស្រែទាំង ១០៥ មាន ៨០គ្រួសារ (៧៦%) និយាយថា តាមធម្មតា ស្រូវដែលធ្វើមកមិនបានគ្រប់គ្រាន់សំរាប់ចិញ្ចឹមគ្រួសារពេញមួយឆ្នាំទេ។ ភាគច្រើន (៩១%) នៃពួកគេ គឺខ្វះខាតស្បៀងដោយត្រូវទិញស្រូវសំរាប់រយៈជាងពេលពីរខែ ហើយមានគ្រួសារ ជាងពាក់កណ្តាល (៥៤%) ត្រូវទិញស្រូវបន្ថែមសំរាប់រយៈពេលជាង ៤ ខែ ។ គ្រួសារជាងមួយភាគបី (៣៦%) ត្រូវទិញស្រូវគេសំរាប់រយៈពេលជាង ៦ខែ។ កង្វះខាតស្រូវជាធម្មតាគឺមានច្រើន ដោយសារនៅពេលប៉ុន្មានឆ្នាំនេះ មានទឹកជំនន់ផង និងគ្រោះរាំងស្ងួតផង បន្តបន្ទាប់គ្នានៅខេត្តព្រៃវែងនេះ ។

ប្រហែលមិនមានអ្វីដែលគួរអោយភ្ញាក់ផ្អើលទេថា គ្រួសារដែលធ្វើស្រែចំនួន ៥១ គ្រួសារ (ដែលមានសមាជិកគ្រួសារជាជនពិការជិត១៥ឆ្នាំមកហើយ) បានប្រាប់ពីនិន្នាការចុះថយនៃផលិតកម្មរបស់ពួកគេ ។ នៅខណៈដែលមាន៤គ្រួសារ បានប្រាប់ឱ្យដឹងថា ទិន្នផលស្រូវរបស់គាត់មានការកើនឡើង មាន ២៧គ្រួសារបាននិយាយថា ទិន្នផលស្រូវរបស់គាត់ថយចុះ ហើយ ២០ គ្រួសារនិយាយថា ទិន្នផលស្រូវរបស់គេ មិនមានអ្វីប្រែប្រួលទេ ។

## *យុទ្ធសាស្ត្រប្រកបរបរចិញ្ចឹមជីវិត*

គ្រួសាររបស់ជនពិការដែលបានសំភាសន៏ភាគច្រើនធ្វើស្រែ។ ក្រៅពីនេះ គ្រួសារជាច្រើនបានចិញ្ចឹមមាន់ ទា ដាំបន្លែ និងដំណាំផ្សេងទៀត និងរកស្បៀងអាហារដែលប្រមូលបានពីវាលស្រែសំរាប់បំពេញបន្ថែមទៀត ។ ប្រហែលពាក់កណ្តាលនៃគ្រួសារទាំងនោះ បានស៊ីឈ្នួលគេនៅជុំវិញភូមិ ហើយមានចំនួនច្រើនគួរសមគឺ ២/៥ រកប្រាក់ចំណូលតាមរយៈ ការធ្វើចំណាកស្រុក ។ អ្នកធ្វើចំណាកស្រុកភាគច្រើនចេញទៅធ្វើការនៅភ្នំពេញ តែក៏មានធ្វើនៅខេត្តព្រៃវែងដែរ និងនៅតាមបណ្តាខេត្តផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា នៅប្រទេសថៃ និងនៅប្រទេសម៉ាឡេស៊ី ។ មានគ្រួសារជនពិការក្នុងចំនួនតិច មានមុខជំនួញខ្នាតតូច រកត្រី ចិញ្ចឹមជ្រូក និងធ្វើរបស់របរលក់ (សូមមើលតារាងទី ៣) ។

គេយល់បានថា ភាគច្រើននៃជនពិការបានចូលរួមនៅក្នុងសកម្មភាពទ្រទ្រង់ជីវភាពនៅក្បែរៗផ្ទះ និងជាការងារដែលមិនសូវត្រូវបញ្ចេញកំលាំងកាយខ្លាំងដូចជា ចិញ្ចឹមមាន់ទា និងដាំបន្លែ ។ ទោះជាយ៉ាងណាក្តី ជនពិការក៏បានចូលរួមនៅក្នុងការងារធ្វើស្រែដែរដូចជា ភ្ជួររាស់ ដកសំណាប ស្ទូង ដកស្មៅ ច្រូតកាត់ និងបោកបែន ។ ដូចគ្នានេះដែរ ជនពិការបានជួយគ្រួសាររបស់គេនៅក្នុងការដើររកស្បៀងអាហារដែលមាននៅតាមវាលស្រែ ហើយនិងបង្កើតជាតូបលក់ដូរតិចតួច ។ ជនពិការមួយចំនួនតូចធ្វើការយកកំរៃនៅជុំវិញភូមិ ហើយរឹតតែតិចជាងនេះទៀត បានរកចំណូលតាមរយៈការធ្វើចំណាកស្រុក ។ ពាក់កណ្តាលនៃជនពិការដែលបានចំណាកស្រុកគឺ ធ្វើការនៅតាមតំបន់ដទៃទៀតនៃខេត្តព្រៃវែង (សូមមើលតារាងទី ៣) ។

| តារាងទី ៣: ការចូលរួមរបស់ជនពិការ និងគ្រួសារនៅក្នុងយុទ្ធសាស្ត្រប្រកបរបរចិញ្ចឹមជីវិត ស្រុកព្រៃវែង ខែ កញ្ញា ឆ្នាំ ២០០៥ | | | | |
|---|---|---|---|---|
| | គ្រួសារដែលចូលរួម | | ជនពិការដែលចូលរួម | |
| **យុទ្ធសាស្ត្រចិញ្ចឹមជីវិត** | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ធ្វើស្រែ | 105 | 76.6% | 37 | 27.0% |
| ចិញ្ចឹមមាន់ឬទា | 78 | 56.9% | 55 | 40.1% |
| ដាំបន្លែ ឬដំណាំផ្សេងទៀត | 76 | 55.5 | 44 | 32.1% |
| ស៊ីឈ្នួលគេនៅជុំវិញភូមិ | 76 | 50.4% | 16 | 11.7% |
| ចេញទៅធ្វើការក្រៅ | 56 | 40.9% | 8 | 5.8% |
| ដើររកស្បៀងតាមបឹង វាលស្រែឬព្រៃ | 49 | 35.8% | 26 | 19.0% |
| មានមុខរបរតូចតាច | 44 | 32.1% | 24 | 17.5% |
| នេសាទ | 41 | 29.9% | 16 | 11.7% |
| ចិញ្ចឹមជ្រូក | 40 | 29.2% | 16 | 11.7% |
| ធ្វើរបស់របរលក់ | 14 | 10.2% | 8 | 5.8% |
| **n = 137** | | | | |

នៅពេលសួរអំពីស្ថានភាពនៃការប្រកបរបរចិញ្ចឹមជីវិតរបស់គេជាទូទៅ គ្រួសារចំនួន ៧០ (ដែលមានសមាជិកពិការអស់រយៈពេល ១៥ ឆ្នាំឬតិចជាងនេះ) បាននិយាយថា កំរិតនៃប្រាក់ចំណូលរបស់ពួកគេជារួម បានធ្លាក់ចុះ ។ ជាក់ស្តែង ទោះបីមានគ្រួសារចំនួន ៣ បាននិយាយថា ចំណូលជារួមរបស់គេមានការកើនឡើង តែគ្រួសារចំនួន៤៤ បាននិយាយថា ចំណូលសរុបរបស់គេមានការធ្លាក់ចុះ ហើយមានគ្រួសារចំនួន ២៣ បានឆ្លើយថា ចំណូលជារួមរបស់គេ មិនមានការប្រែប្រួលទេ។

### *ការងារមិនទទួលបានប្រាក់កម្រៃ*

ទោះបីជនពិការមិនសូវបានចូលរួមចំណែកដល់ការងារផលិតឬការងាររកចំណូលសំរាប់គ្រួសារក្តី តែមានជនពិការចំនួន ១០៥ នាក់ (៧៧%) ក្នុងចំណោម ១៣៧ នាក់ដែលបានអង្កេត បានចូលរួមនៅក្នុងការងារថែទាំផ្ទះសម្បែង ឬការងារគ្មានប្រាក់កម្រៃដែរ ។ ជាក់ស្តែង ជនពិការបានជួយសំអាតផ្ទះ (៧៦នាក់) ជួយចំអិនអាហារ (៧៤នាក់) ជួយមើលក្មេងតូចៗ (៦៥នាក់) ជួយដងទឹក (៤៩នាក់) ជួយបោកខោអាវ (៣៤នាក់) និងជួយមើលថែទាំមនុស្សចាស់ (១៦នាក់) ។ ទាំងនេះបញ្ជាក់ពីការចូលរួមចំណែកយ៉ាងសំខាន់ដល់គ្រួសារ ។

## **ការរើសអើង និងកង្វះការរាប់រកនៅក្នុងសង្គម**

### *ការហៅឈ្មោះ និងការចំអកលេងសើច*

ការរើសអើងចំពោះជនពិការមានក្នុងរូបភាពច្រើនយ៉ាង ហើយបញ្ហានេះមានតាំងពីពួកគេនៅពីក្មេងមកម្ល៉េះ ។ ការរើសអើងដែលគេមើលឃើញជាទូទៅមាន ការហៅឈ្មោះ និងការចំអកលេងសើចចំពោះពិការភាពរបស់គេ ។ ទោះបីមនុស្សជាទូទៅយល់ថា ការធ្វើបែបនេះមិនប៉ះពាល់ដល់ជនពិការក្តី ក៏ការបញ្ចេញឥរិយាបថដដែលៗពីសំណាក់អ្នកដែលស្គាល់គ្នា បានធ្វើអោយខូចខាតទៅដល់ភាពជឿជាក់របស់ជនពិការ ហើយថែមទាំងធ្វើអោយគេកាន់តែអសមត្ថភាពតទៅទៀត ។ ជារួម មានជនពិការ ៥០នាក់ ក្នុងចំណោម ១៣៧នាក់ ត្រូវបានគេហៅឈ្មោះលេងសើចទៅតាមប្រភេទពិការភាព។ អ្នកដែលលេងសើចទាំងនេះមានដូចជា អ្នកជិតខាង (៣៧នាក់) មិត្តភក្តិ (៣១នាក់) សមាជិកគ្រួសារ (១៨នាក់) សិស្សរួមថ្នាក់ (១០នាក់) ហើយមានភាគតិចជាអ្នកដែលគេមិនដែលធ្លាប់ស្គាល់សោះ (២នាក់) ។ បើយើងប្រៀបធៀបវិញ ជនពិការដែលមានអាយុក្រោម ១៨ឆ្នាំ ក្នុងចំនួនច្រើន (៤៤%) បានទទួលរងនូវការហៅឈ្មោះលេងសើចបែបនេះ។

**រឿងរ៉ាវរបស់ ចន សារុន**

នៅឆ្នាំ ១៩៧៩ ចន សារុន មានអាយុ ១៧ឆ្នាំ បានចូលបំរើក្នុងជួរកងទ័ព។ លុះដល់៦ឆ្នាំក្រោយមក គាត់បានចូលរួមការច្បាំងគ្នាយ៉ាងខ្លាំងក្លាមួយជាមួយនឹងទ័ពខ្មែរក្រហម នៅតាមព្រំដែនកម្ពុជា-ថៃ។ ក្រោយមកនៅថ្ងៃទី ០១ ខែសីហា ឆ្នាំ ១៩៨៥ គាត់បានជាន់មីន ហើយធ្វើឱ្យជីវិតរបស់គាត់មានការប្រែប្រួល។ សារុនបានដាច់ជើងម្ខាង ហើយត្រូវបានធ្វើបញ្ជូនទៅកាន់ជំរុំជនភៀសខ្លួនសាយធូ នៅប្រទេសថៃដើម្បីព្យាបាលរបួសរបស់គាត់។ នៅឯជំរុំ គាត់ត្រូវបានគេដាក់ជើងសិប្បនិមិត្តឱ្យ។ គាត់ក៏បានរៀនជំនាញជួសជុលវិទ្យុ និងទូរទស្សន៍។ ក្នុងអំឡុងពេល៧ឆ្នាំ ដែលគាត់បានរស់នៅក្នុងជំរុំសាយធូនេះ សារុនបានរៀបការហើយមានកូនស្រីចំនួន២នាក់។ ប៉ុន្តែ នៅពេលធ្វើមាតុភូមិនិវត្តន៍នៅឆ្នាំ១៩៩២ គាត់បានលែងលះគ្នាជាមួយប្រពន្ធ។ សារុន បានត្រលប់មកផ្ទះ របស់គាត់វិញ នៅខេត្តព្រៃវែង ហើយប្រពន្ធរបស់គាត់បាននាំកូនស្រី

ទាំងពីរទៅនៅឯខេត្តបន្ទាយមានជ័យ ។

នៅពេលត្រលប់មកព្រៃវែងវិញ សារុនបានឮអំពីមណ្ឌលស្តារលទ្ធភាពពលកម្មរបស់អង្គការអតីតយុទ្ធជនអន្តរជាតិ (វីអាយ) នៅគៀនឃ្លាំង ទីក្រុងភ្នំពេញ។ នៅទីនោះ គាត់ត្រូវបានគេដាក់ជើងសិប្បនិមិត្តជាថ្មីដែលអាចជួយឱ្យ គាត់ផ្លាស់ទីបានដូចពេលមុន ។ នៅឆ្នាំ ១៩៩៥ អង្គការអតីតយុទ្ធជនបានបង្កើតមណ្ឌលស្តារលទ្ធភាពពលកម្ម នៅខេត្តព្រៃវែងដែលធ្វើឱ្យ សារុន ងាយស្រួលក្នុងការជួសជុល និងផ្លាស់ជើងសិប្បនិមិត្តរបស់គាត់បាន។ សារុន បានបញ្ជាក់ឱ្យដឹងថា ជាច្រើនឆ្នាំកន្លងមកនេះ គុណភាពជើងសិប្បនិមិត្តរបស់គាត់មានភាពប្រសើរឡើង ហើយភាពប្រសើរឡើងនេះ បូករួមនឹងបំណងប្រាថ្នាយ៉ាងមោះមុតរបស់គាត់ក្នុងការលើកស្ទួយជីវភាពរបស់គាត់ផង បានជួយឱ្យគាត់អាចកាត់បន្ថយបាននូវបញ្ហាលំបាកនានា បណ្តាលមកពីពិការភាពរបស់គាត់ ។

ឥឡូវនេះ គាត់បានរៀបការម្តងទៀត ហើយព្រមទាំងមានកូនពីរទៀតដែរ។ សារុន បានប្រឹងប្រែងធ្វើការងារ ដើម្បីកសាងជីវិតថ្មី។ គាត់បានបើកតូបជួសជុលវិទ្យុ និងទូរទស្សន៍មួយតាមបណ្តោយផ្លូវនៅមុខផ្ទះរបស់គាត់។ នៅក្នុងតូបនេះ ប្រពន្ធរបស់គាត់ក៏បានលក់ចំណីអាហារ និងទំនិញរេចខ្ចប់តិចតួចផងដែរ ។ សារុន តែងតែជិះកង់ ទៅផ្សារដែលមានចំងាយប្រមាណជា ៥គីឡូម៉ែត្រពីផ្ទះ ដើម្បីទិញទំនិញមកឱ្យប្រពន្ធរបស់គាត់លក់។ នៅក្បែរ តូបនេះ សារុន បានជីកស្រះតូចមួយ ព្រមទាំងចិញ្ចឹមកូនត្រីជាច្រើន ដែលបានទិញពីអង្គការមួយ។ ដោយមាន ជំនួយជើងសិប្បនិមិត្ត សារុន អាចធ្វើការភ្ជួររាស់ នៅលើដីស្រែរបស់គាត់ដែលមានទំហំ ០,៤ ហិកតា ព្រមទាំង ធ្វើការដកស្ទូង និងច្រូតកាត់ជាមួយនឹងប្រពន្ធគាត់ផងដែរ។ នៅឆ្នាំនេះ គាត់បានជីកអណ្តូងទឹកដោយខ្លួនឯង នៅលើដីស្រែរបស់គាត់ ដើម្បីបានទឹកធ្វើស្រែប្រាំង។ សកម្មភាពទាំងនេះ អាចទ្រទ្រង់គ្រួសាររបស់ សារុន ដែលរស់នៅព្រៃវែងបាន ហើយម្តងម្កាល គាត់បានទៅលេងកូនស្រីរបស់គាត់ នៅឯខេត្តបន្ទាយមានជ័យ ព្រមទាំងជួយ ឧបត្ថម្ភថវិកាខ្លះទៀតផង។

សារុនត្រូវបានគេស្គាល់ច្រើននៅក្នុងភូមិ។ គាត់បានទៅវត្ត ចូលរួមក្នុងពិធីអាពាហ៍ពិពាហ៍ បុណ្យសពជាធម្មតា។ ស្រដៀងគ្នានេះដែរ គាត់បានចូលរួមការប្រជុំភូមិ ដើម្បីរៀបចំផែនការឃុំ ហើយព្រមទាំងចូលរួមក្នុងការងារ ស្បៀងពលកម្ម។ សារុន បានចូលរួមបោះឆ្នោតជាតិនៅឆ្នាំ ១៩៩៨ និងឆ្នាំ ២០០៣ និងចូលរួមបោះឆ្នោត ក្រុមប្រឹក្សាឃុំ/សង្កាត់នៅឆ្នាំ ២០០២។ ថ្មីៗនេះ គាត់បានទទួលជំនួយឧបត្ថម្ភជាសំភារៈដែលមានតម្លៃ ១០០ ដុល្លារពីអង្គការ Rotary International តាមរយៈអង្គការវីអាយដែលជំនួយទាំងនោះមានគ្រឿងផ្សារ និងប្រដាប់វាស់ចរន្តអគ្គីសនី សំរាប់ជួយដល់មុខរបរជួសជុលរបស់គាត់។ តាំងពីឆ្នាំ ២០០០មក តាមរយៈការជួយ ជ្រោមជ្រែងរបស់អតីតមេបញ្ជាការរបស់គាត់ គាត់បានទាមទារនូវប្រាក់ឧបត្ថម្ភ ចំនួន ១០០.០០០រៀល (២៥ដុល្លារ) ក្នុងមួយខែពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងនាមជាអតីតយុទ្ធជនពិការម្នាក់ ។

ស្រដៀងគ្នានេះដែរ ជនពិការ ៥៦ (៤១%) ក្នុងចំណោម ១៣៧ នាក់ ក៏បានទទួលរងនូវការលេងសើចតាមរយៈ ការដើរត្រាប់តាម ការនិយាយស្ដីតាម និង ការរំកិលតាម ។ អ្នកដែលធ្វើត្រាមតាមក៏មានស្រដៀងគ្នាទៅនឹងខាងលើនេះដែរគឺ អ្នកជិតខាង (៣៧នាក់) មិត្តភក្តិ (៣៤នាក់) សមាជិកគ្រួសារ (១១នាក់) សិស្សរួមថ្នាក់ (៩នាក់) ហើយមានភាគតិចជាអ្នកដែលគេមិនដែលធ្លាប់ស្គាល់សោះ (៤នាក់) ។ បើយើងប្រៀបធៀបវិញ ជនពិការដែលមានអាយុក្រោម ១៨ឆ្នាំ ក្នុងចំនួនច្រើន (៥៦%) បានទទួលរងនូវការលេងសើចបែបនេះ ។

## *ការចូលរៀននៅសាលា*

ទោះបីគ្មានជនពិការណាម្នាក់ក្នុងចំណោម ១៣៣នាក់ដែលបានសំភាសន៍ហើយដែលគ្រប់អាយុចូលសាលា ត្រូវបានគេបដិសេធន៍ក្នុងការចូលរៀនសាលាក៏ដោយ តែឥរិយាបថដែលគ្រួសារ និងសង្គមបានធ្វើមកលើជនពិការបានរារាំងដល់ពួកគេក្នុងការចូលរៀនក្នុងសាលាអោយបានពេញលេញរួចទៅហើយ ។ គេមើលឃើញថា មានភាពស្រដៀងគ្នាទៅនឹងការដាក់កំរិតមកលើក្មេងស្រីដែរគឺ ក្រុមគ្រួសារមានអារម្មណ៍ថា មិនចាំបាច់លើកទឹកចិត្ត ឬជួយដល់ការរៀនសូត្ររបស់សមាជិកគ្រួសារដែលពិការនោះទេ ។ ដោយហេតុនេះហើយ ទើបធ្វើអោយការចូលរៀនរបស់ជនពិការ មានកំរិតទាប រីឯការចូលរៀនរបស់ស្ត្រី និងកុមារីពិការវិញ នោះរឹតតែគួរអោយ សង្វេកថែមទៀត ។

នៅក្នុងការអង្កេតនេះ កំរិតសិក្សាអប់រំជាមធ្យមរបស់ជនពិការប្រុសចំនួន ៧៦នាក់គឺ ត្រឹមថ្នាក់ទី ៤ប៉ុណ្ណោះ។ មធ្យមភាគនេះ រួមទាំងបុរសពិការចំនួន ២២ នាក់ (២៩%នៃចំនួនសរុប) ដែលគ្រប់អាយុចូលរៀន តែមិនបានចូលរៀនសោះ។ ក្នុងពេលជាមួយគ្នានេះដែរ មានបុរសពិការ ១៩នាក់ (២៥%នៃចំនួនសរុប) បានបញ្ចប់ថ្នាក់ទី៦។ បើយើងធ្វើការប្រៀបធៀបវិញ នៅក្នុងការអង្កេតនេះ កំរិតសិក្សាអប់រំជាមធ្យមរបស់ស្ត្រីពិការដែលគ្រប់អាយុចូលរៀនចំនួន ៥៦នាក់នោះគឺ រៀនបានត្រឹមតែថ្នាក់ទី ២ ប៉ុណ្ណោះ ។ មធ្យមភាគនេះ រួមទាំងស្ត្រីពិការចំនួន ២៣ នាក់ (៤១%នៃចំនួនសរុប) ដែលគ្រប់អាយុចូលរៀន តែមិនបានចូលរៀនសោះ។ ក្នុងពេលជាមួយគ្នានេះដែរ មានស្ត្រីពិការតែ ៦នាក់ (១១%នៃចំនួនសរុប) បានបញ្ចប់លើពីថ្នាក់ទី៦។

## *ការរៀបអាពាហ៍ពិពាហ៍*

សង្គមខ្មែរ អោយតម្លៃខ្ពស់ទៅលើការរៀបអាពាហ៍ពិពាហ៍ ព្រមទាំងការទទួលខុសត្រូវរបស់គូស្វាមីភរិយា ទៅលើការលើកស្ទួយគ្រួសារ ។ ជាថ្មីម្តងទៀតគឺ នៅត្រង់ចំណុចនេះ ឥរិយាបថដែលមាននៅក្នុងគ្រួសារ និងសង្គម តែងតែមានការរើសអើងចំពោះជនពិការ ក្នុងការមានឱកាសជ្រើសរើសគូស្រករ ។ រីឯការរើសអើងចំពោះស្ត្រីពិការក្នុងរឿង អាពាហ៍ពិពាហ៍វិញនោះ រឹតតែមានកាន់តែច្រើនថែមទៀត ។ ជារួម មានស្ត្រីពិការ ១៣នាក់ (៣៣%) ក្នុងចំណោមស្ត្រីពិការ ៣៩នាក់ដែលមានអាយុគ្រប់ការធ្លាប់បានជួបការលំបាក ដោយសារក្រុមគ្រួសាររបស់ខ្លួន ឬគ្រួសារខាងអនាគតស្វាមី ក្នុងការផ្តល់ឱកាសអោយគេសំរេចចិត្តដោយខ្លួនគេ ។ បើធ្វើការប្រៀបធៀប យើង

ឃើញថា បុរសពិការមានចំនួនតិចជាងស្ត្រីពិការ ក្នុងរឿងនេះ ពោលគឺ ក្នុងចំណោមបុរសពិការ ៦២នាក់ មានបុរសពិការតែ ៧នាក់ (១១%) ប៉ុណ្ណោះ ។

ទោះបីបញ្ហាពិការភាព មិនបានរារាំងដល់ការរៀបអាពាហ៍ពិពាហ៍របស់ពួកគេភាគច្រើនក្តី តែនៅមានជនពិការមួយភាគធំទៀតដែលមានអាយុគ្រប់ការ ហើយបន្តនៅលីវរហូតដល់សព្វថ្ងៃ។ ដូច្នេះ នេះជាការបង្ហាញអោយឃើញច្បាស់ថា ឧបសគ្គសំរាប់អាពាហ៍ពិពាហ៍គឺ ជាបញ្ហាសង្គមជាជាងបញ្ហារូបកាយ ។ ក្នុងចំណោមបុរសពិការដែលបានអង្កេត ហើយដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ មាន ១៧% (១១នាក់ ក្នុងចំណោម ៦៥នាក់) ដែលនៅលីវនៅឡើយ ។ ផ្ទុយទៅវិញ ក្នុងចំណោមស្ត្រីពិការដែលបានអង្កេតដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ មាន ៥២% (២១នាក់ ក្នុងចំណោម ៤០នាក់) ដែលនៅលីវដែរ។ តាមសំដីរបស់ស្ត្រីម្នាក់បានលើកឡើងថា *"ខ្លួនខ្ញុំជាជនពិការ ដូច្នេះមិនមានបុរសណាម្នាក់ នឹងមកសុំរៀបការជាមួយនឹងនាងខ្ញុំទេ"* ។

## *ការបោះឆ្នោត*

នៅក្នុងការអង្កេតនេះ គ្មានជនពិការណាម្នាក់ ក្នុងចំណោមជនពិការ ១០៥ នាក់ដែលមានសិទ្ធិបោះឆ្នោតត្រូវបានគេបដិសេធនឹក្នុងការចូលរួមបោះឆ្នោត ដោយសារបញ្ហាពិការភាពរបស់ពួកគេនោះទេ ។ តាមពិត ចំនួនអ្នកដែលបានបោះឆ្នោត មានកំរិតខ្ពស់គឺ ៨២នាក់ (៧៨%) នៃជនពិការ១០៥នាក់នៅក្នុងការអង្កេតនេះ ដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ បានចូលរួមបោះឆ្នោត យ៉ាងហោចណាស់ម្តងក្នុងការបោះឆ្នោតទាំងបីលើកកន្លងមកនេះ ។ នៅពេលពិនិត្យមើលអោយស៊ីជំរៅទៅទៀត គេឃើញថា មានជនពិការ ៦៩នាក់ បានទៅបោះឆ្នោតក្នុងឆ្នាំ ២០០៣ និងមាន ៧១នាក់ បានបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ឆ្នាំ ២០០២ ព្រមទាំង ៧៩នាក់បានបោះឆ្នោតជាតិនាឆ្នាំ ១៩៩៨។ ហេតុផលសំខាន់មួយដែលធ្វើអោយជនពិការខ្លះ មិនបានទៅបោះឆ្នោត ដោយសារពួកគេមិនមានលទ្ធភាពទៅកាន់មណ្ឌលបោះឆ្នោតបាន ។

ចំពោះចំនួនអ្នកបោះឆ្នោតរវាងបុរសពិការ និងស្ត្រីពិការ គេបានឃើញថា បុរសមានចំនួនខ្ពស់ជាង ។ ជាក់ស្តែងបុរសពិការដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ មាន ៨៦% (៥៦ នាក់ក្នុងចំណោម ៦៥នាក់) បានចូលរួមយ៉ាងហោចណាស់ម្តង ក្នុងការបោះឆ្នោតទាំងបីលើកកន្លងមក តែចំពោះស្ត្រីពិការវិញ មានតែ ៦៥% (២៦នាក់ក្នុងចំណោម ៤០នាក់) ប៉ុណ្ណោះ ។ លើសពីនេះទៅទៀត គេមានការគិតថា ជនពិការទាំងបុរសនារីដែលមានអាយុចាប់ពី៦០ឆ្នាំឡើងទៅ នឹងមិនសូវបានចូលរួមក្នុងការបោះឆ្នោត តែផ្ទុយទៅវិញ ការចូលរួមមានកំរិតខ្ពស់គឺ ៨៣% (១៥នាក់ ក្នុងចំណោម ១៨ នាក់) បានចូលរួមបោះឆ្នោត យ៉ាងហោចណាស់ម្តង ក្នុងការបោះឆ្នោតទាំងបីលើកកន្លងមក ។ តែទោះជាយ៉ាងណាក្តី ក៏ការចូលរួមរបស់ជនពិការដែលមានអាយុចាប់ពី ៦០ឆ្នាំឡើងទៅ ឃើញមានការធ្លាក់ចុះជាបន្តបន្ទាប់ នៅក្នុងការបោះឆ្នោតទាំងបីលើកនោះ ។

*ការប្រាស្រ័យទាក់ទងនៅក្នុងសង្គម*

ច្រកមួយទៀតនៃការរើសអើងពីសង្គមគឺ កំរិតនៃការប្រាស្រ័យទាក់ទងរបស់ជនពិការជាមួយអ្នកដទៃ ក្រៅពីរង្វង់ក្រុមគ្រួសារ ។ គេបានពិនិត្យមើលបញ្ហានេះពីចំណុចពីរសំខាន់គឺ ភាពញឹកញាប់នៃអ្នកដទៃមកសួរសុខទុក្ខជនពិការ ភាពញឹកញាប់នៃការទៅសួរសុខទុក្ខរបស់ជនពិការចំពោះអ្នកដទៃ ។ សាច់សាលោហិត និងមិត្តភក្តិក្រៅរង្វង់ក្រុមគ្រួសារ ឃើញថា មានចំនួនច្រើនបានមកទាក់ទងជាមួយជនពិការ ។ រីឯការមកលេងពីសំណាក់មិត្តភក្តិ ក៏មិនសូវជាញឹកញាប់ ។ ចំពោះការមកសួរសុខទុក្ខរបស់បុគ្គលិករដ្ឋ និង បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ក៏រឹតតែកម្រមានទៅទៀត (សូមមើលតារាងទី ៤) ។

| **តារាងទី ៤: ភាពញឹកញាប់នៃការមកសួរសុខទុក្ខជនពិការ<br>ស្រុកព្រៃវែង ខែ កញ្ញា ឆ្នាំ ២០០៥** | | | | | | |
|---|---|---|---|---|---|---|
| បរិយាយ | ញឹកញាប់ | |ម្តងម្កាល | | មិនធ្លាប់សោះ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| សាច់សាលោហិតក្រៅរង្វង់គ្រួសារមកសួរសុខទុក្ខជនពិការ | 87 | 63.5% | 45 | 32.8% | 5 | 3.6% |
| អ្នកជិតខាងមកសួរសុខទុក្ខជនពិការ | 84 | 61.3% | 47 | 34.3% | 6 | 4.4% |
| មិត្តភក្តិមកសួរសុខទុក្ខជនពិការ | 56 | 41.2% | 55 | 40.4% | 25 | 18.4% |
| បុគ្គលិក ឬមន្ត្រីរាជការមកសួរសុខទុក្ខជនពិការ | 17 | 12.4% | 55 | 40.1% | 65 | 47.4% |
| បុគ្គលិកអង្គការតែងតែមកសួរសុខទុក្ខជនពិការ | 8 | 5.8% | 48 | 35.0% | 81 | 59.1% |
| **n = 137** | | | | | | |

ទោះបីថា ការប្រាស្រ័យទាក់ទងរបស់ជនពិការជាមួយអ្នកដទៃមានក្នុងកំរិតតិចតួចក្តី តែគេមើលឃើញនិន្នាការប្រហាក់ប្រហែលគ្នា ទៅនឹងការមកសួរសុខទុក្ខជនពិការពីសំណាក់អ្នកដទៃដែរ ។ អ្នកដទៃក្រៅរង្វង់គ្រួសារដែលជនពិការបានទៅលេងជាមួយញឹកញាប់មានដូចជា អ្នកជិតខាង និងសាច់សាលោហិតជាដើម តែមិនសូវញឹកញាប់ជាមួយមិត្តភក្តិ និងរឹតតែមិនសូវញឹកញាប់ទៅទៀត ជាមួយបុគ្គលិករដ្ឋ និង បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល (សូមមើលតារាងទី ៥) ។

| តារាងទី ៤: ភាពញឹកញាប់នៃការប្រាស្រ័យទាក់ទងរបស់ជនពិការជាមួយអ្នកដទៃ<br>ស្រុកព្រៃវែង ខែ កញ្ញា ឆ្នាំ ២០០៥ | | | | | | |
|---|---|---|---|---|---|---|
| បរិយាយ | ញឹកញាប់ | |ម្តងម្កាល | | មិនធ្លាប់សោះ | |
| | ចំនួន | ភាគរយ | ចំនួន | ចំនួន | ភាគរយ | ចំនួន |
| ជនពិការទៅលេងអ្នកជិតខាង | 64 | 46.7% | 52 | 38.0% | 21 | 15.3% |
| ជនពិការទៅលេងសាច់សាលោហិតក្រៅរង្វង់គ្រួសារ | 58 | 42.3% | 53 | 38.7% | 26 | 19.0% |
| ជនពិការទៅលេងមិត្តភក្តិ | 35 | 25.7% | 60 | 44.1% | 41 | 30.1% |
| ជនពិការទៅជួបបុគ្គលិករដ្ឋ/មន្ត្រីរាជការ | 7 | 5.1% | 45 | 32.8% | 85 | 62.0% |
| ជនពិការទៅជួបបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល | 4 | 2.9% | 39 | 28.5% | 94 | 68.6% |
| **n = 137** | | | | | | |

## *ការចូលរួមនៅក្នុងពិធីផ្សេងៗនៅក្នុងសហគមន៏ និងការងារអភិវឌ្ឍន៏*

ការចូលរួមរបស់ជនពិការនៅក្នុងពិធីផ្សេងៗនៅក្នុងសហគមន៏ មានភាពល្អប្រសើរ ។ ជារួម ជនពិការចំនួន ១០១ នាក់ (៧៦%) ក្នុងចំណោម ១៣៣នាក់ ដែលមានអាយុចាប់ពី ៦ឆ្នាំឡើងទៅសុទ្ធតែបានចូលរួមនៅក្នុងពិធីផ្សេងៗ។ ដើម្បីជាពត៌មានលំអិតបន្ថែមទៀតនោះគឺ មានជនពិការ ៩២ នាក់បានចូលរួមនៅក្នុងពិធីបុណ្យនៅតាមវត្តអារាម និងចំនួន ៨៩នាក់ បានចូលរួមពិធីបុណ្យសព ព្រមទាំង ៦៨នាក់បានចូលរួមនៅក្នុងពិធីអាពាហ៏ពិពាហ៏ ។ ដោយឡែក មានចំនួន ៣២នាក់ បានចូលរួមនៅក្នុងពិធីនៅតាមសាលារៀន ។ ហេតុផលសំខាន់ដែលមួយចំនួនមិនបានចូលរួម បណ្តាលមកពីការពិបាកធ្វើដំណើរ ឬក៏អ្នកពិការនៅតូចពេក ។

រីឯការចូលរួមរបស់ជនពិការនៅក្នុងការងារអភិវឌ្ឍន៏សហគមន៏វិញ មិនសូវមានច្រើនដូចខាងលើនេះទេ។ ជារួម ជនពិការចំនួន ៥៣នាក់ (៥0%) ក្នុងចំណោម ១០៥នាក់ ដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅសុទ្ធតែបានចូលរួមនៅក្នុងការងារអភិវឌ្ឍន៏សហគមន៏ ។ ក្នុងចំណោមអ្នកដែលបានចូលរួមទាំងអស់នេះ មាន ២៩នាក់ បានចូលរួមនៅក្នុងកម្មវិធីស្បៀងពលកម្ម និង ២៧នាក់ បានចូលរូមនៅក្នុងការប្រជុំធ្វើផែនការក្រុមប្រឹក្សាឃុំ។ ដោយឡែកមាន ២១ នាក់ បានចូលរួមនៅក្នុងសមាគមភូមិ និង ១៦នាក់បានចូលរួមនៅក្នុងការងារអភិវឌ្ឍន៏របស់អង្គការមិនមែនរដ្ឋាភិបាល ។ ហេតុផលសំខាន់ដែលជនពិការជាច្រើននាក់ទៀត មិនបានចូលរួមគឺ បណ្តាលមកពីការពិបាកធ្វើដំណើរ អ្នកពិការនៅតូចពេក និងមិនត្រូវបានគេអញ្ជើញ ឬលើកទឹកចិត្តអោយចូលរួម ។

បើគិតទៅដល់បញ្ហាយេនឌ័រវិញ គេឃើញថា ការចូលរួមនៅក្នុងពិធីបុណ្យនៅតាមសហគមន៍របស់បុរសពិការ និង កុមារាពិការ មានកំរិតខ្ពស់ជាង ស្ត្រីពិការ និង កុមារីពិការក្នុងកំរិតតិចតួចប៉ុណ្ណោះ ។ ជាក់ស្តែង បុរសពិការ និង កុមារាពិការដែលមានអាយុចាប់ពី ៦ឆ្នាំឡើងទៅចំនួន ៧៨% (៥៩នាក់ ក្នុងចំណោម ៧៦នាក់) បានចូលរួម នៅក្នុងពិធីបុណ្យនៅតាមសហគមន៍ តែចំពោះស្ត្រីពិការ និង កុមារីពិការក្នុងកំរិតអាយុដូចគ្នាដែរនោះ មានចំនួន ៧៤% (៤២នាក់ក្នុងចំណោម ៥៧ នាក់) ។ ផ្ទុយទៅវិញ ការចូលរួមនៅក្នុងការងារអភិវឌ្ឍន៍ របស់បុរសពិការ មានកំរិតខ្ពស់ជាងការចូលរួមរបស់ស្ត្រីពិការ ។ ជាក់ស្តែង បុរសពិការដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ ចំនួន ៦០% (៣៩នាក់ ក្នុងចំណោម ៦៥នាក់) បានចូលរួមនៅក្នុងការងារអភិវឌ្ឍន៍សហគមន៍ តែចំពោះស្ត្រីពិការ ក្នុងកំរិតអាយុដូចគ្នាដែរនោះ បានចូលរួមតែ ៣៥% (១៤នាក់ក្នុងចំណោម ៤០ នាក់) ប៉ុណ្ណោះ ។ មានស្ត្រីពិការ ៧ នាក់ បានលើកឡើងថា ពួកគេមានការខ្មាស់អៀន ក្នុងការចូលរួមក្នុងការងារអភិវឌ្ឍន៍ ។

**ជំនួយ និងសេវាកម្មដែលពួកគេទទួលបាន**

ជាការគួរអោយស្រងាកចិត្តបន្តិច ដោយសារថា មានជនពិការតែ ៥៥ នាក់ (៤០%) ក្នុងចំណោម ១៣៧នាក់ដែល បានអង្កេត បានទទួលជំនួយ ដើម្បីអោយពួកគេអាចផ្លាស់ទីបាន ។ អត្រានៃការទទួលបានជំនួយ គេឃើញថា ចំនួនបុរសពិការច្រើនជាងចំនួនស្ត្រីពិការ បានទទួលនូវជំនួយ ព្រមទាំងឃើញថា ជនពិការនៅវ័យក្មេងជាច្រើននាក់ បានទទួលជំនួយជាងជនពិការវ័យចំណាស់ ។ ក្នុងខណៈដែលបុរសពិការ និងកុមារាពិការចំនួន ៤៤% (៣៥នាក់ ក្នុងចំណោម ៧៩នាក់) បានទទួលជំនួយ គេឃើញមានស្ត្រីពិការ និងកុមារីពិការតែ ៣៤% (២០នាក់ក្នុងចំណោម ៥៨ នាក់) ដែលបានទទួលជំនួយដែរនោះ ។ ចំពោះប្រការដែលល្អនោះគឺថា មានកុមារពិការក្រោមអាយុ ១៨ឆ្នាំ រហូតដល់ទៅ ៧២% (២៣នាក់ ក្នុងចំណោម ៣២ នាក់) បានទទួលជំនួយ តែបើយើងក្រឡេកមើលទៅលើ ជនពិការវ័យចំណាស់ចាប់ពីអាយុ ៦០ឆ្នាំឡើងទៅ មានតែ ១១% (២នាក់ ក្នុងចំណោម ១៨ នាក់) ប៉ុណ្ណោះ ។ ជំនួយស្ទើរតែទាំងអស់បានទទួលពីអង្គការ វីអាយ ។ ទោះបីអង្គការ វីអាយ មានលទ្ធភាពច្រើន ក្នុងការជួយដល់ មធ្យោបាយបំលាស់ទីរបស់កុមារ តែក៏មិនសូវមានលទ្ធភាពជួយពិនិត្យទៅលើពិការភាពរបស់មនុស្សវ័យចំណាស់ ដែលកើតមកពីការមានជំងឺផ្សេងៗ ។

នៅក្នុងតំបន់ស្រាវជ្រាវ អង្គការ វីអាយ បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់ជំនួយ និងសេវាកម្មដល់ជនពិការ ។ គួរកត់សំគាល់ដែរថា ជនពិការ ៥២ នាក់ (៩៤%) ក្នុងចំណោមជនពិការដែលបានទទួលជំនួយចំនួន៥៥ នាក់ គឺ ជាអ្នកដែលបានទទួលជំនួយពីអង្គការ វីអាយ ។ ការជួយរបស់អង្គការនេះ មានច្រើនរូបភាព ។ ជាក់ស្តែង ក្នុងចំណោម ៥២ នាក់ដែលបានទទួលជំនួយពីអង្គការនេះ មាន ១៦នាក់ទទួលបានរទេះរុញ ១១នាក់បានទទួល ជើងសិប្បនិមិត្ត ១០នាក់បានទទួលឈើច្រត់ ៨នាក់បានទទួលរណប ៧នាក់បានទទួលការព្យាបាលជំងឺ ៦នាក់

បានទទួលជំនួយជារបស់របរ ៣នាក់បានទទួលនូវការធ្វើចលនា ៣នាក់ផ្សេងទៀតបានទទួលការបង្រៀនកំរិតបឋមសិក្សា និង ២នាក់បានទទួលការបណ្តុះបណ្តាលខាងកីឡា ។ គិតមកត្រឹមដំណាក់កាលនៃការអង្កេតនេះ នាចុងឆ្នាំ ២០០៥ អង្គការ វីអាយ នៅតែបន្តជួយដល់ជនពិការ ៣៩នាក់ (៧៥%) ក្នុងចំណោមជនពិការ ៥២នាក់ ដែលបានទទួលជំនួយផ្ទាល់ពីអង្គការ វីអាយ កន្លងមក ។ ក្នុងចំណោម ៥០នាក់ដែលបានទទួលជំនួយពីអង្គការ វីអាយ មាន ៤៥នាក់បានលើកឡើងថា ជំនួយនេះពិតជាមានប្រយោជន៍ណាស់ និង ២ នាក់បាននិយាយថា មិនសូវមានប្រយោជន៍ទេ ។ ដោយឡែក មាន ៣នាក់ ដែលបាននិយាយថា មិនមានប្រយោជន៍សោះ ។

ជនពិការភាគច្រើនបានទទួលជំនួយជាលើកដំបូង តាំងពីឆ្នាំ ១៩៩៥ គឺនៅពេលដែលមានវត្តមានរបស់អង្គការ វីអាយ នៅខេត្តព្រៃវែងនាពេលនោះ ។ ក្នុងចំណោម ៥៥នាក់ដែលបានទទួលជំនួយ មាន ៥នាក់ (៩%) បានទទួលមុនឆ្នាំ ១៩៩៥ និង ១៧នាក់ (៣១%) បានទទួលក្នុងចន្លោះឆ្នាំ ១៩៩៥-១៩៩៩ ព្រមទាំង ៣៣នាក់ (៦០%) បានទទួលពីចន្លោះឆ្នាំ ២០០០ រហូតមកដល់សព្វថ្ងៃ ។ ការដែលមានជនពិការបានទទួលជំនួយក្នុងសហសវត្សរ៍ថ្មីភាគច្រើន ជាការបង្ហាញអោយឃើញថា មានការកើនឡើងនូវការយល់ដឹងអំពីសេវាកម្មដែលមាននៅក្នុងតំបន់នោះ ។ តែទោះជាយ៉ាងណាក្តី នៅតែមានគ្រួសារមិនសូវជាច្រើនទេគឺ ៦៧ (៤៩%) ក្នុងចំណោមគ្រួសារដែលបានអង្កេតចំនួន ១៣៧ គ្រួសារ បានដឹងឮអំពីសេវាកម្មស្តារលទ្ធភាពពលកម្មដែលផ្តល់ដោយអង្គការ វីអាយ ដោយមិនគិតថ្លៃ សំរាប់ជនពិការ ប្រចាំនៅទីរួមខេត្តព្រៃវែង ។ ម្យ៉ាងវិញទៀត គ្រួសារចំនួន ៥៧ (៨៦%) នៃគ្រួសារ ៦៦ ដែលមិនធ្លាប់ស្គាល់អង្គការ វីអាយ បានលើកឡើងថា ពួកគេចង់ដឹងចង់ឮពីកម្មវិធីស្តារលទ្ធភាពរបស់អង្គការនេះ ។

## សេចក្តីសន្និដ្ឋាន

យោងតាមការដកស្រង់អត្ថបទស្រាវជ្រាវថ្មីៗនេះជាច្រើន ទើបធ្វើអោយការសិក្សានេះធ្វើការវែកញែកនូវពាក្យពីរ គឺ "ភាពអន់ខ្សោយសរីរាង្គ ឬអ្នកមានបញ្ហាបំលាស់ទី" ឬ "Impairment" ដែលគេចង់និយាយសំដៅទៅលើលក្ខខ័ណ្ឌដែលមាននៅក្នុងខ្លួនរបស់បុគ្គលម្នាក់ៗ រីឯពាក្យ"ពិការភាព" ឬ "Disability" មានន័យថា ជាផ្លែផ្កានៃការរើសអើង និងការមិនអើពើរបស់សង្គម ចំពោះមនុស្សដែលអន់ខ្សោយខាងសរីរាង្គ ។ ភាពខុសគ្នាគឺ មិនគ្រាន់តែសំដៅទៅលើការប្រើប្រាស់ពាក្យនោះទេ តែខ្លឹមសារនៃពាក្យគឺជាប្រការសំខាន់។ ឧទាហរណ៍ បើសង្គមធ្វើអោយមនុស្សដែលមានភាពអន់ខ្សោយខាងសរីរាង្គ ក្លាយទៅជាជនពិការ ដូច្នេះ គ្រប់គ្នាដែលប្តេជ្ញាចិត្ត ចង់ឃើញសង្គមមួយដែលមានការរាប់បញ្ចូលមនុស្សទាំងអស់នៅក្នុងសង្គម ហើយជាសង្គមដែលប្រកាន់យកសិទ្ធិជាមូលដ្ឋាននោះត្រូវតែកំចាត់ចោលនូវរាល់ឧបសគ្គចង្រៃ ដែលកើតមានចំពោះជនពិការអោយបាន ។ គេត្រូវតែធ្វើការជាមួយជនពិការ ដោយកុំផ្តោតការយកចិត្តទុកដាក់តែទៅលើការបណ្តុះបណ្តាលជំនាញទៅដល់ផលិតករគ្រឿងសប្បនិម្មិត និងអ្នកជំនាញខាងធ្វើចលនា មានន័យថា គ្រប់អ្នកធ្វើការងារអភិវឌ្ឍន៍ទាំងអស់ ត្រូវតែធ្វើអោយជនពិការ ស្គាល់ និង ទទួលបាននូវសិទ្ធិរបស់ពួកគេពេញលេញ ។ ដូច្នេះ ការបញ្ជ្រាបចូលជនពិការទៅក្នុងការងារអភិវឌ្ឍន៍អោយបានទូលំទូលាយគឺ គ្មានអ្វីក្រៅពីការទាមទារអោយមានការរៀបចំនូវកម្មវិធីគ្រប់លំដាប់ថ្នាក់ឡើងវិញប៉ុណ្ណោះ ។

លទ្ធផលនៃការស្រាវជ្រាវនៅជនបទជាក់ស្តែងនេះ បានជួយបំភ្លឺអោយកាន់តែច្បាស់ទៅលើស្ថានភាពជីវិតពិតរបស់ជនពិការនៅតាមជនបទនៃប្រទេសកម្ពុជា ។ ពិតណាស់ដែលថា កេរ្តិ៍ដំណែលនៃសង្គ្រាមបានបន្សល់ទុកជនពិការតែនៅក្នុងតំបន់ស្រាវជ្រាវនេះ បញ្ហាមីន និងការគ្រោះថ្នាក់ផ្សេងទៀតនៅក្នុងសង្គ្រាមកន្លងមក ធ្វើអោយមានជនពិការតិចតួច តែអ្វីដែលមានលើសពីនេះគឺ កត្តាជំងឺរោគា ។ ភាគច្រើននៃជំងឺរោគាទាំងនេះ សុទ្ធតែអាចការពារ និងទប់ស្កាត់បាន ហើយការដែលមិនអាចការពារបានក៏ព្រោះតែប្រព័ន្ធសុខាភិបាលនៅកម្ពុជា ត្រូវបានបំផ្លាញក្នុងកំឡុងពេលនៃសង្គ្រាម និងការមិនយកចិត្តទុកដាក់ជាច្រើនឆ្នាំមកហើយ ។ គេអាចយល់បានថា ភាពអន់ខ្សោយខាងសរីរាង្គ ពិតជាមានការប៉ះពាល់ដល់បញ្ហាបំលាស់ទីរបស់ជនពិការ ។ ជាក់ស្តែង កាលណាការបំលាស់ទីទៅកាន់តែឆ្ងាយពីផ្ទះអ្នកជិតខាង ចំនួនជនពិការដែលបានសំភាសន៍ទាំងនោះ មានលទ្ធភាពផ្លាស់ទី ក្នុងកំរិតកាន់តែទាបទៅៗ។ ទោះជាយ៉ាងណាក្តី ការដែលបានទទួលជំនួយជាគ្រឿងទ្រទ្រង់រាងកាយ ធ្វើអោយចំនួនជនពិការជាច្រើនដែលពីមុនមិនធ្លាប់ផ្លាស់ទី អាចផ្លាស់ទីបាននាពេលបច្ចុប្បន្ននេះ ។ នៅក្នុងគ្រួសារដែលមានសមាជិកពិការ ឃើញថាត្រូវខិតខំធ្វើការយ៉ាងច្រើនជាងមុន ដើម្បីឆ្លើយតបនឹងតំរូវការការងាររកប្រាក់ចំណូល ព្រមទាំងការងារផ្ទះសម្បែងដែរ ។ ប៉ុន្តែតំរូវការក្នុងការមើលថែទាំសមាជិកពិការ មិនបានកាត់បន្ថយលទ្ធភាពរកចំណូលយ៉ាងខ្លាំង ក្នុងចំណោមគ្រួសារភាគច្រើននោះទេ ។ គេបានដឹងថា គ្រួសារជាច្រើនបានខ្ចីលុយសំរាប់ចំណាយលើសុខភាព ឬការព្យាបាលជំងឺ

របស់អ្នកពិការ តែពួកគេភាគច្រើនបានសងបំណុលទាំងនោះរួចអស់ហើយដែរ ។ មានគ្រួសារមួយចំនួនតូចដែលបានលក់ទ្រព្យសម្បត្តិដូចជា ដីធ្លី ដើម្បីចំណាយលើសុខភាព និងព្យាបាលជំងឺអ្នកពិការ តែពួកគេកំពុងប្រឈមមុខនូវផលវិបាកយ៉ាងធ្ងន់ធ្ងរ ។

ជាទូទៅ គ្រួសារដែលមានសមាជិកជនពិការ មានការលំបាកដោយសារបញ្ហាខ្វះដីធ្លី ។ គ្រួសារចំនួន ២៨ បានបាត់បង់ដីធ្លីទាំងស្រុង ហើយ៤៤គ្រួសារជិតនឹងបាត់បង់ដីដែរ (គឺនៅសល់តែ ០.៥ហិកតា ឬតិចជាងនេះ) ដូច្នេះសរុបជារួមមាន ៧២គ្រួសារ (៥២ភាគរយ) នៃចំនួនសរុប១៣៧គ្រួសារ ដែលបានធ្វើអង្កេតគឺ មានបញ្ហាខ្វះដីធ្លី ។ ការប្រមូលទិន្នផលស្រូវនៅរដូវវស្សាត្រូវបានថយចុះ ហើយអ្នកដែលមិនបានធ្វើស្រែប្រាំងគឺ បានជួបបញ្ហាដាច់ស្បៀងយ៉ាងធ្ងន់ធ្ងរ។ ច្រើនជាងមួយភាគបីនៃគ្រួសារដែលធ្វើស្រែបានជួបបញ្ហាដាច់ស្បៀង ហើយត្រូវការទិញស្រូវថែមរហូតដល់ទៅ៦ខែ ។ ក្រៅពីការធ្វើស្រែ គ្រួសារដែលមានសមាជិកជាជនពិការ បានចិញ្ចឹមមាន់ទា ដំណាំបន្លែស៊ីឈ្នួលនៅជុំវិញភូមិ និងធ្វើការចំណាកស្រុក ។ មិនជាការគួរអោយភ្ញាក់ផ្អើលនោះទេ ភាគច្រើននៃអ្នកពិការពួកគេបានចូលរួមក្នុងសកម្មភាពរកប្រាក់ចំណូលនៅជុំវិញផ្ទះ ហើយជាការងារស្រាលៗ ដើម្បីជួយគ្រួសារដែរ ដូចជាការចិញ្ចឹមមាន់ទា និងដាំបន្លែក្បែរផ្ទះ។ តែក៏មានជនពិការមួយភាគបួនដែរ ដែលចូលរួមក្នុងការងារធ្វើស្រែចំការ។

ការមិនអើពើពីសង្គមចំពោះជនពិការដែលបានធ្វើអង្កេតនេះ មានច្រើនទំរង់ ហើយពួកគេបានជួបប្រទះនូវបញ្ហានេះតាំងពីវ័យកុមារម្ល៉េះ។ ជនពិការគ្រប់រូបនៅក្នុងការអង្កេតនេះ មានបទពិសោធន៍ ដោយមានគេហៅឈ្មោះទៅតាមប្រភេទពិការភាព ហើយក៏មានមនុស្សខ្លះ បានចំអកលេងសើចដូចជា ធ្វើដំណើរតាម និយាយត្រាប់តាម ឬរំកិលផ្លាស់ទីជាដើម។ ការចូលរួមរៀនសូត្រនៅតាមសាលារបស់ជនពិការ គឺមានតិចតួចបំផុត រីឯស្ត្រីពិការវិញ រឹតតែតិចជាងនេះថែមទៀត។ ទោះជនពិការភាគច្រើនដែលត្រូវបានធ្វើអង្កេតនេះ គ្មានឧបសគ្គក្នុងការរៀបអាពាហ៍ពិពាហ៍ក៏យើងឃើញថា មានជនពិការជាច្រើននាក់ទៀត ដែលស្ថិតនៅលីវនៅឡើយ ។ ការរើសអើងប្រឆាំងនឹងជនពិការជាស្ត្រីភេទ ក្នុងការរើសគូស្រករគឺជា បញ្ហាធំដុំមួយ ។ ផ្ទុយទៅវិញ ការចូលរួមបោះឆ្នោតនៅក្នុងចំណោមជនពិការបុរស និងស្ត្រី មានកំរិតខ្ពស់ ។ ការចូលរួមរបស់ជនពិការនៅក្នុងពិធីផ្សេងៗនៅក្នុងសង្គមដូចជា ពិធីរៀបការពិធីបុណ្យសព និងពិធីបុណ្យនានានៅតាមវត្តអារាម ត្រូវបានមើលឃើញថា មានកំរិតខ្ពស់ដែរទាំងបុរសពិការនិងស្ត្រីពិការ ។ ចំពោះការចូលរួមរបស់ជនពិការក្នុងការងារអភិវឌ្ឍន៍វិញគឺ មិនសូវជាច្រើនប៉ុន្មានទេ តែក្នុងចំនួននេះ គេបានបញ្ជាក់ថា បុរសពិការបានចូលរួមច្រើនជាងស្ត្រីពិការ ។

គេហាក់ដូចជាខកចិត្តបន្តិច ដោយសារថា មានជនពិការតែ ៤០%ក្នុងចំណោមគ្រួសារដែលបានសំភាសន៍ បានទទួលជំនួយទ្រទ្រង់រាងកាយសំរាប់ធ្វើការបំលាស់ទី។ កំរិតនៃការទទួលជំនួយ គឺបុរសមានអត្រាខ្ពស់ជាងស្ត្រី ហើយចំនួនជនពិការវ័យក្មេងច្រើនជាង ជាងមនុស្សចាស់ បានទទួលជំនួយនេះ។ ជំនួយសឹងតែទាំងអស់ត្រូវបានទទួលពីអង្គការ

អតីតយុទ្ធជនអន្តរជាតិ (វីអាយ)។ នេះជាការបង្ហាញអោយឃើញនូវការរួមចំណែកដ៏វិសេសវិសាលនៃកម្មវិធីរបស់អង្គការនេះ ក្នុងការជួយទៅលើការស្តារលទ្ធភាពពលកម្មសំរាប់ជនពិការ នៅក្នុងតំបន់ដែលបានស្រាវជ្រាវ ។ ជាទូទៅ ដោយសារខ្វះខាតសេវាស្តារលទ្ធភាពពលកម្មពីស្ថាប័នដទៃផង ហើយនិងមើលឃើញថា ជនពិការតិចជាងពាក់កណ្តាល បានទទួលសេវាពីមជ្ឈមណ្ឌលរបស់អង្គការវីអាយដូចលើកឡើងខាងលើនេះស្រាប់ គេអាចនិយាយបានថា ចំពោះជនពិការរស់នៅស្រុកណា ដែលនៅកាន់តែឆ្ងាយពីមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មរបស់អង្គការវីអាយ នោះរឹតតែធ្វើអោយពួកគេកាន់តែពិបាកនឹងទទួលបានសេវា ពីមជ្ឈមណ្ឌលរបស់អង្គការនេះថែមទៀត ។ ការផ្លាស់ប្តូរមកជា កម្មវិធីស្តារលទ្ធភាពពលកម្មតាមសហគមន៍របស់អង្គការវីអាយគឺជា រឿងមួយគួរអោយមានការអបអរសាទរ ហើយនិងបានជាទីសង្ឃឹមរបស់ជនពិការរស់នៅក្នុងតំបន់ស្រាវជ្រាវពិតមែន តែគេមើលឃើញថា វិស័យពិការភាពពេលបច្ចុប្បន្នដែលស្ថិតនៅក្រៅរង្វង់នៃ ការអភិវឌ្ឍន៏ទ្រង់ទ្រាយធំ ជាប្រផ្នូលមិនល្អសំរាប់ជនពិការនៅតំបន់ជនបទក្នុងប្រទេសកម្ពុជា នាពេលអនាគតនោះទេ ។ ដូច្នេះ អ្នករៀបចំគោលនយោបាយថ្នាក់ជាតិ ម្ចាស់មូលនិធិពហុភាគី និងទ្វេភាគី អង្គការធ្វើការខាងកិច្ចការជនពិការនិងអភិវឌ្ឍន៏ ព្រមទាំងអង្គការជនពិការត្រូវតែរួមកម្លាំងគ្នាអោយបានកាន់តែខ្លាំងឡើង ដើម្បីធានាអោយបានជនពិការចូលរួមយ៉ាងសកម្ម នៅក្នុងកម្មវិធីជាតិកាត់បន្ថយភាពក្រីក្រ និងធានាអោយពួកគេរស់នៅ ក្នុងនាមជាពលរដ្ឋពេញសិទ្ធិ ដូចពលរដ្ឋកម្ពុជាគ្រប់រូប ។

## ឧបសម្ព័ន្ធទី ១: បញ្ជីសំណួរសំរាប់សំភាសន៍តាមគ្រួសារ

ឈ្មោះអ្នកសំភាសន៍:.................................... កាលបរិច្ឆេទនៃការសំភាសន៍:..............................

ឈ្មោះអ្នកដែលត្រូវបានសំភាសន៍:.................... ត្រួតពិនិត្យដោយ:.............................................

**សេចក្តីផ្តើម:** ខ្ញុំឈ្មោះ ..........................ខ្ញុំជាសិស្សដែលចូលរួមក្នុងវគ្គស្តីពីការវិភាគបញ្ហាអភិវឌ្ឍន៍ យើងកំពុងស្វែងយល់អោយបានប្រសើរជាងនេះ នូវស្ថានភាព និងបទពិសោធន៍របស់ជនពិការរាងកាយ។ ខ្ញុំសូមសួរសំនួរខ្លះៗដល់លោកឬលោកស្រី អំពីបទពិសោធន៍របស់លោកឬលោកស្រី និងបទពិសោធន៍របស់ជនពិការនៅក្នុងគ្រួសារ របស់ អស់លោក ឬលោកស្រី ។

**ប្រវត្តិ:** កំណត់សំគាល់របស់អ្នកសំភាសន៍: សូមមេត្តាគូររង្វង់មូលទៅលើចំលើយដែលសមស្របទៅនឹងសំណួរដែលបានសួរ។ សូមគូររង្វង់នៅក្នុងចម្លើយតែមួយចំពោះសំណួរទាំងអស់ដែលបានសួរ លើកលែងតែក្នុងករណីបញ្ជាក់អោយគូសលើសពីមួយចំលើយ ។ សូម សរសេរ NA សំរាប់ចំលើយទាំងឡាយណា ដែលមិនសមស្រប ។ សូមសរសេរ DK សំរាប់អ្នកផ្តល់ចំលើយដែលបានឆ្លើយថា "មិនដឹង" ។

1.01 លេខរៀងនៃចំនួនសំភាសន៍.........( សូមទុកចន្លោះនេះទំនេរ ក្រុម ADI នឹងបំពេញពេលក្រោយ )

1.02 ឈ្មោះឃុំ

| | | | |
|---|---|---|---|
| អង្គរទ្រេត | 1 | ស្វាយអន្ទរ | 4 |
| ដីរឮន | 2 | មេបុណ្យ | 5 |
| ព្រៃខ្លា | 3 | ពពឺស | 6 |

1.03 ឈ្មោះភូមិ

| | | | |
|---|---|---|---|
| ឫស្សីធ្លក (អង្គរទ្រេត) | 1 | ក្រចាបទីបី (ព្រៃខ្លា) | 13 |
| ចំការគួយ (ដីរពួន) | 2 | ពោធិចិនដាំ (ស្វាយអន្ទរ) | 14 |
| ត្បូងក្តី (ដីរពួន) | 3 | ព្រៃខ្មែក (ស្វាយអន្ទរ) | 15 |
| ព្រៃភ្លាំង (ដីរពួន) | 4 | ចចកទីមួយ (មេបុណ្យ) | 16 |
| គាំប្រជីស (ដីរពួន) | 5 | ចចកទីពីរ (មេបុណ្យ) | 17 |
| ថ្កូវ (ដីរពួន) | 6 | ភ្នំគង់ (មេបុណ្យ) | 18 |
| តងឡងទី១ (ព្រៃខ្លា) | 7 | មេបុណ្យ (មេបុណ្យ) | 19 |
| តងឡងទី២ (ព្រៃខ្លា) | 8 | ថ្កូវ (មេបុណ្យ) | 20 |
| ព្រៃខ្លាទី ១ (ព្រៃខ្លា) | 9 | ហាបូ (មេបុណ្យ) | 21 |
| ព្រៃខ្លាទី២ (ព្រៃខ្លា) | 10 | ខ្សោកជើង (ពពីស) | 22 |
| ក្រចាបទីមួយ (ព្រៃខ្លា) | 11 | ខ្សោកត្បូង (ពពីស) | 23 |
| ក្រចាបទីពីរ (ព្រៃខ្លា) | 12 | | |

| | | | |
|---|---|---|---|
| 1.04 ចំនួនសមាជិកគ្រួសារ | a. ប្រុស | b.ស្រី | c. សរុប |
| 1.05 ចំនួនសមាជិកគ្រួសារដែលអាចជួយរកប្រាក់ចំណូល | a. ប្រុស | b.ស្រី | c. សរុប |

## ប្រវត្តិទូទៅរបស់ជនពិការ:

1.06 ទំនាក់ទំនងនៃអ្នកដែលត្រូវបានសំភាសន៍ ទៅនឹងជនពិការនៅក្នុងគ្រួសារ

| | |
|---|---|
| ជនពិការជាអ្នកដែលត្រូវបានសំភាសន៍ | 1 |
| ម្តាយរបស់ជនពិការ | 2 |
| ឱពុករបស់ជនពិការ | 3 |
| បងប្អូនប្រុសឬស្រីរបស់ជនពិការ | 4 |
| មីង ឬ ពូរបស់ជនពិការ | 5 |
| ជីដូនជីតារបស់ជនពិការ | 6 |
| ប្រពន្ធរបស់ជនពិការ | 7 |

1.07 ភេទរបស់ជនពិការនៅក្នុងគ្រួសារ

| | |
|---|---|
| ភេទប្រុស | 1 |
| ភេទស្រី | 2 |

1.08 អាយុរបស់ជនពិការនៅក្នុងគ្រួសារ  សូមសរសេរអាយុពិត......................

1.09 កំរិតសិក្សារបស់ជនពិការនៅក្នុងគ្រួសារ-  សូមសរសេរកំរិតថ្នាក់ដែលរៀនចប់.............

1.10 ស្ថានភាពគ្រួសារ របស់ជនពិការនៅក្នុងគ្រួសារ

| | |
|---|---|
| បានរៀបការ | 1 |
| មេម៉ាយ ឬពោះម៉ាយ | 2 |
| បែកគ្នា ឬ លែងលះគ្នា | 3 |
| នៅលីវ | 4 |

1.11 ប្រភេទនៃពិការភាពផ្នែករាងកាយ របស់ជនពិការនៅក្នុងគ្រួសារ

| | | | |
|---|---|---|---|
| ដាច់ជើង ( ជើង) | 1 | ស្វិតសាច់ដុំ | 13 |
| ដាច់ដៃ ( ដៃ) | 2 | ជើងខ្វេ | 14 |
| ពិការខួរក្បាល | 3 | ភ្លាត់ឆ្អឹងត្រគាក | 15 |
| ពិការស្វិតដៃជើង | 4 | ឆ្អឹងជើងកោង | 16 |
| ពិការដោយខ្វិនជើងទាំងពីរ | 5 | ឆ្អឹងខ្នងកោង | 17 |
| ពិការដោយស្លាប់មួយចំហៀងខ្លួន | 6 | ពុកឆ្អឹង | 18 |
| ស្លាប់អវៈយវៈទាំងអស់ | 7 | ខ្សោយសាច់ដុំ | 19 |
| បាក់ឆ្អឹង | 8 | កប់សរសៃ | 20 |
| របួសសន្លាក់ | 9 | ផ្សេងៗ ( បញ្ជាក់)................ | 21 |
| របួសភ្លើង | 10 | | |
| ពិការពីកំណើត | 11 | | |
| គមខ្នង ( ពក) | 12 | | |

1.12 តើមូលហេតុអ្វីដែលបណ្តាលអោយជនពិការនៅក្នុងគ្រួសារ ក្លាយជាពិការ?

| | |
|---|---|
| ដោយជម្ងឺ ឬ រោគា | 1 |
| ដោយពិការពីកំណើត | 2 |
| ដោយគ្រោះថ្នាក់ (ចរាចរ ឬធ្លាក់) | 3 |
| ដោយជាន់មីន | 4 |
| ដោយសារសង្គ្រាម ឬជំលោះ | 5 |
| អំពើហឹង្សាក្នុងគ្រួសារ | 6 |
| ផ្សេង១ (សូមបញ្ជាក់) | 7 |

1.13 តើជនពិការទទួលរងពិការភាពរាងកាយ ដោយសារតែចូលបំរើកងទ័ពឬ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| ទេ (ពិការក្រោមអាយុ ១៨ឆ្នាំ) | 3 |

1.14 តើមានរយៈពេលប៉ុន្មានឆ្នាំមកហើយ ដែលជនពិការទទួលរងនូវពិការភាពរាងកាយ ? (ចំណាំៈ បើសិនជាជនពិការមានពិការភាពតាំងពីកំណើត សូមសរសេរអាយុរបស់ជនពិការនោះ )

សូមសរសេរចំនួនឆ្នាំ ..........................................................

**បំលាស់ទីតាំងរបស់ជនពិការៈ**

1.15a បច្ចុប្បន្ននេះ តើជនពិការអាចផ្លាស់ទីតាំងខ្លួនឯងនៅក្នុងបរិវេណផ្ទះ (ឡើងលើ ចុះក្រោមផ្ទះ ចេញ និងចូល ក្នុងបន្ទប់គេង ) បានដែរឬទេ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| ទេ (ពិការក្រោមអាយុ ៥ឆ្នាំ) | 3 |

1.15b បើបាទ ឬចាស តើជនពិការប្រើឧបករណ៍ (ជើង ឬដៃសិប្បនិមិត្ត គ្រឿងជំនួយសំរាប់ធ្វើចលនា ជើងទ្រ ឬ រទេះរុញ ។ល។ ) ឬទេ?

| | |
|---|---|
| បាទ ឬចាស | 1 |
| ទេ | 2 |
| N/A (ជនពិការមិនអាចផ្លាស់ទីដោយខ្លួនឯងបាន) | 98 |

1.15c បើជនពិការប្រើឧបករណ៍ ( ជើង ឬដៃសិប្បនិម្មិត គ្រឿង ជំនួយសំរាប់ធ្វើចលនា ជើងទ្រ ឬ រទេះរុញ ។ល។ ) តើជនពិការអាចផ្លាស់ទីដោយខ្លួនឯងនៅជុំវិញបរិវេណផ្ទះបានទេ មុនពេលទទួលឧបករណ៍ជំនួយទាំងនោះ ?

| | |
|---|---|
| បាទ ឬចាស | 1 |
| ទេ | 2 |
| N/A ( មិនប្រើឧបករណ៍ទេ) | 98 |

1.16a បច្ចុប្បន្ននេះ តើជនពិការអាចចូលទៅបង្គន់ដោយខ្លួនឯងបានទេ?

| | |
|---|---|
| បាទ ឬចាស | 1 |
| ទេ | 2 |
| ទេ ( ពិការក្រោមអាយុ ៥ឆ្នាំ) | 3 |

1.16b បើបាទឬចាស តើជនពិការមានប្រើឧបករណ៍ជំនួយ ( ជើង ឬដៃសិប្បនិម្មិត គ្រឿងជំនួយសំរាប់ ធ្វើចលនា ជើងទ្រ ឬ រទេះរុញ ។ល។ ) ឬទេ?

| | |
|---|---|
| បាទ ឬចាស | 1 |
| ទេ | 2 |
| N/A ( ជនពិការមិនអាចទៅបង្គន់ខ្លួនឯងបានទេ) | 98 |

1.16c បើសិនជាជនពិការប្រើឧបករណ៍ជំនួយ ( ជើង ឬដៃសិប្បនិម្មិត គ្រឿងជំនួយសំរាប់ធ្វើចលនា ជើងទ្រ ឬ រទេះរុញ ។ល។ ) តើជនពិការអាចទៅបន្ទប់ទឹកដោយខ្លួនឯងបានទេ មុនពេលទទួលឧបករណ៍ ជំនួយទាំងនោះ ?

| | |
|---|---|
| បាទ ឬចាស | 1 |
| ទេ | 2 |
| N/A ( ជនពិការមិនប្រើឧបករណ៍ជំនួយទាំងនោះទេ) | 98 |

1.17a បច្ចុប្បន្ននេះ តើជនពិការអាចទៅងូតទឹកដោយខ្លួនឯងបានទេ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| ទេ ( ពិការក្រោមអាយុ ៥ឆ្នាំ) | 3 |

1.17b បើបាទ ឬចាស តើជនពិការប្រើឧបករណ៍ជំនួយ ( ជើង ឬដៃសិប្បនិមិត្ត គ្រឿងជំនួយសំរាប់ ធ្វើចលនា ជើងទ្រ ឬ រទេះរុញ ។ល។ ) ឬទេ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| N/A (ជនពិការមិនអាចងូតទឹកបានខ្លួនឯងទេ) | 98 |

1.17c បើជនពិការប្រើឧបករណ៍ជំនួយ ( ជើង ឬដៃសិប្បនិមិត្ត គ្រឿងជំនួយធ្វើចលនា ជើងទ្រ ឬ រទេះរុញ ។ល។ ) តើជនពិការអាចទៅងូតទឹកដោយខ្លួនឯងបានទេ មុនពេលទទួលឧបករណ៍ជំនួយ ទាំងនោះ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| N/A (ជនពិការមិនប្រើឧបករណ៍ជំនួយទាំងនោះទេ) | 98 |

1.18a បច្ចុប្បន្ននេះ តើជនពិការអាចផ្លាស់ទីដោយខ្លួនឯងទៅតាមផ្ទះអ្នកជិតខាងបានទេ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| ទេ (ពិការក្រោមអាយុ ៥ឆ្នាំ) | 3 |

1.18b បើបាទ ឬចាស តើជនពិការមានប្រើឧបករណ៍ជំនួយ ( ជើង ឬដៃសិប្បនិមិត្ត គ្រឿងជំនួយធ្វើចលនា ជើងទ្រ ឬ រទេះរុញ ។ល។ ) ឬទេ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| N/A (ជនពិការមិនអាចផ្លាស់ទីទៅតាមផ្ទះអ្នកជិតខាងខ្លួនឯងទេ) | 98 |

1.18c បើជនពិការមានប្រើឧបករណ៍ជំនួយ( ជើង ឬដៃសិប្បនិមិត្ត គ្រឿងជំនួយធ្វើចលនា ជើងទ្រ ឬ រទេះរុញ ។ល។ ) តើជនពិការអាចផ្លាស់ទីទៅតាមផ្ទះអ្នកជិតខាង ដោយខ្លួនឯងបានទេ មុនពេលទទួល ឧបករណ៍ជំនួយទាំងនោះ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| N/A (ជនពិការមិនប្រើឧបករណ៍ជំនួយទាំងនោះទេ) | 98 |

1.19a បច្ចុប្បន្ននេះ តើជនពិការអាចទៅវត្តដែលនៅជិតៗដោយខ្លួនឯងបានទេ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| ទេ (ពិការក្រោមអាយុ ១០ឆ្នាំ) | 3 |

1.19b បើបាទ ឬចាស តើជនពិការមានប្រើឧបករណ៍ជំនួយ (ជើង ឬដៃសិប្បនិមិត្ត គ្រឿងជំនួយធ្វើ ចលនា ជើងទ្រ ឬ រទេះរុញ) ។ល។ ឬទេ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| N/A (ជនពិការមិនអាចទៅវត្តជិតៗបានទេ) | 98 |

1.19c បើជនពិការមានប្រើឧបករណ៍ជំនួយ (ជើង ឬដៃសិប្បនិមិត្ត គ្រឿងជំនួយធ្វើចលនា ជើងទ្រ ឬ រទេះរុញ) ។ល។ តើជនពិការអាចទៅវត្តដែលនៅជិតៗដោយខ្លួនឯងបានទេ មុនពេលទទួលឧបករណ៍ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| N/A (ជនពិការមិនប្រើឧបករណ៍ជំនួយទាំងនោះទេ) | 98 |

1.20a បច្ចុប្បន្ននេះ តើជនពិការអាចទៅផ្សារដែលនៅជិតៗដោយខ្លួនឯងបានទេ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| ទេ (ពិការក្រោមអាយុ ១០ឆ្នាំ) | 3 |

1.20b បើបាទ ឬចាស តើជនពិការមានប្រើឧបករណ៍ជំនួយ (ជើង ឬដៃសិប្បនិមិត្ត គ្រឿងជំនួយធ្វើ ចលនា ជើងទ្រ ឬ រទេះរុញ) ។ល។ ឬទេ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| N/A (ជនពិការមិនអាចទៅផ្សារជិតៗដោយខ្លួនឯងបានទេ) | 98 |

1.20c បើជនពិការមានប្រើឧបករណ៍ជំនួយ ( ជើង ឬដៃសិប្បនិមិត្ត គ្រឿងជំនួយធ្វើចលនា ជើងទ្រ ឬរទេះរុញ) ។ល ។ តើជនពិការអាចទៅផ្សារដែលនៅជិតៗដោយខ្លួនឯងបានទេ មុនពេលទទួលឧបករណ៍ ជំនួយទាំងនោះ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| N/A ( ជនពិការមិនប្រើឧបករណ៍ជំនួយទាំងនោះទេ) | 98 |

1.21a បច្ចុប្បន្ននេះ តើជនពិការអាចទៅសាលាឃុំបាន ដោយខ្លួនឯងបានទេ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| ទេ ( ពិការក្រោមអាយុ ១៥ឆ្នាំ) | 3 |

1.21b បើបាទ ឬចាស តើជនពិការមានប្រើឧបករណ៍ជំនួយ ( ជើង ឬដៃសិប្បនិមិត្ត គ្រឿងជំនួយធ្វើ ចលនា ជើងទ្រ ឬ រទេះរុញ ) ។ល ។ ឬទេ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| N/A ( ជនពិការមិនអាចទៅសាលាឃុំដោយខ្លួនឯងបានទេ) | 98 |

1.21c បើជនពិការមានប្រើឧបករណ៍ជំនួយ ( ជើង ឬដៃសិប្បនិមិត្ត គ្រឿងជំនួយធ្វើចលនា ជើងទ្រ ឬ រទេះរុញ ) ។ល ។ តើជនពិការអាចទៅសាលាឃុំដោយខ្លួនឯងបានទេ មុនពេលទទួលឧបករណ៍ជំនួយ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| N/A ( ជនពិការមិនប្រើឧបករណ៍ជំនួយទាំងនោះទេ) | 98 |

1.22a បច្ចុប្បន្ននេះ តើជនពិការអាចទៅទីរួមខេត្តព្រៃវែង ដោយខ្លួនឯងបានទេ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| ទេ ( ពិការក្រោមអាយុ ១៥ឆ្នាំ) | 3 |

1.22b បើបាទ ឬចាស តើជនពិការមានប្រើឧបករណ៍ជំនួយ ( ជើង ឬដៃសិប្បនិមិត្ត គ្រឿងជំនួយធ្វើ ចលនា ជើងទ្រ ឬ រទេះរុញ ) ។ល។ ឬទេ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| N/A ( ជនពិការមិនអាចទៅទីរួមខេត្តព្រៃវែងដោយខ្លួនឯងបានទេ) | 98 |

1.22c បើជនពិការមានប្រើឧបករណ៍ជំនួយ ( ជើង ឬដៃសិប្បនិមិត្ត គ្រឿងជំនួយធ្វើចលនា ជើងទ្រ ឬ រទេះរុញ ) ។ល។ តើជនពិការអាចទៅទីរួមខេត្តព្រៃវែងដោយខ្លួនឯងបានទេ មុនពេលទទួលឧបករណ៍ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| N/A ( ជនពិការមិនប្រើឧបករណ៍ជំនួយទាំងនោះទេ) | 98 |

**កម្មសិទ្ធិដីធ្លី និងផលិតកម្មកសិកម្ម:**

2.01 តើគ្រួសារអស់អ្នក ( គ្រួសាររបស់ជនពិការ) នៅបច្ចុប្បន្ននេះ មានដីស្រែទេ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |

2.02 បើបាទ ឬចាស តើក្រុមគ្រួសាររបស់អ្នក បច្ចុប្បន្ននេះមានដីស្រែប៉ុន្មានហិកតា ?

សូមសរសេរជាហិកតា.................................

N/A 98

2.03 តើគ្រួសារអស់អ្នក ( គ្រួសាររបស់ជនពិការ) បច្ចុប្បន្ននេះមានជួលដីស្រែពីគេឬទេ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |

2.04 បើបាទ ឬចាស តើគ្រួសាររបស់អ្នក បច្ចុប្បន្ននេះមានជួលដីស្រែ ប៉ុន្មានហិកតា?

សូមសរសេរជាហិកតា...........................................

N/A 98

2.05 តើគ្រួសាររបស់អ្នកធ្លាប់លក់ដីស្រែទេ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |

2.06 បើបាទ ឬចាស តើគ្រួសាររបស់អ្នកធ្លាប់លក់ដីស្រែទំហំប៉ុន្មានហិកតា ?

សូមសរសេរជាហិកតា..................................

| | |
|---|---|
| N/A | 98 |

2.07 បើបាទ ឬចាស តើគ្រួសាររបស់អ្នកធ្លាប់លក់ដីស្រែនោះ ដោយសារយកទៅបង់ថ្លៃសុខភាព របស់ជនពិការនៅក្នុងគ្រួសារឬ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| N/A | 98 |

2.08 តើគ្រួសាររបស់អ្នកធ្លាប់បញ្ចាំដីស្រែទេ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |

2.09 បើបាទ ឬចាស តើគ្រួសាររបស់អ្នកធ្លាប់ដាក់បញ្ចាំដីស្រែទំហំប៉ុន្មានហិកតា ?

សូមសរសេរជាហិកតា.............................................

| | |
|---|---|
| N/A | 98 |

2.10 បើបាទ ឬចាស តើគ្រួសាររបស់អ្នកធ្លាប់បញ្ចាំដីស្រែនោះ ដោយសារបង់ថ្លៃសុខភាពរបស់ជនពិការ នៅក្នុងគ្រួសារឬ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| N/A | 98 |

2.11 តើគ្រួសាររបស់អ្នកបានធ្វើស្រែវស្សាទេ កាលពីឆ្នាំមុននេះ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| N/A | 98 |

2.12 តើគ្រួសាររបស់អ្នកបានធ្វើស្រែប្រាំងទេ កាលពីឆ្នាំមុននេះ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| N/A | 98 |

2.13 បើគ្រួសាររបស់អ្នកបានធ្វើស្រែប្រាំង ឬស្រែវស្សាកាលពីឆ្នាំមុននេះ តើគ្រួសាររបស់អ្នក បានប្រើគោក្របីផ្ទាល់ខ្លួនឬទេ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| N/A | 98 |

2.14 តើទំហំដីស្រែប៉ុន្មានហិកតា ដែលក្រុមគ្រួសាររបស់អ្នកបានធ្វើ កាលពីឆ្នាំមុននេះ ?

| ដីស្រែ | a. ទំហំដីស្រែដែលបានធ្វើស្រែវស្សាកាលពីឆ្នាំមុន ................................. N/A 98 | b. ទំហំដីស្រែដែលបានធ្វើស្រែប្រាំងក្នុងឆ្នាំមុន .............................. N/A 98 | c. ទំហំដីស្រែដែលបានធ្វើកាលពីឆ្នាំមុនសរុប .............................. N/A 98 |
|---|---|---|---|

2.15 ទិន្នផលស្រូវជាគីឡូក្រាម ដែលក្រុមគ្រួសាររបស់អ្នកប្រមូលផលបាន កាលពីឆ្នាំមុននេះ ? (**ចំណាំ ១ថាំង= ២៤ គក រឺឯ១តៅ= ១២ គក**)

| ដីស្រែ | a. ទិន្នផលស្រូវវស្សា កាលពីឆ្នាំមុននេះ ..........................គក N/A 98 | b. ទិន្នផលស្រូវប្រាំង កាលពីឆ្នាំមុននេះ ..............................គក N/A 98 | c. ទិន្នផលស្រូវសរុប កាលពីឆ្នាំមុននេះ ..........................គក N/A 98 |
|---|---|---|---|

2.16 តើទិន្នផលស្រូវដែលប្រមូលបានរាល់ឆ្នាំ ជាធម្មតា គ្រប់គ្រាន់សំរាប់ផ្គត់ផ្គង់គ្រួសារអ្នកឬទេ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| N/A (គ្រួសារមិនបានធ្វើស្រែ) | 98 |

2.17 បើ ទេ តើជាធម្មតា គ្រួសាររបស់អ្នកខ្វះអង្កររយៈពេលប៉ុន្មានខែ ?

សូមសរសេរចំនួនខែដែលខ្វះខាត......................

N/A (គ្រួសារមិនបានធ្វើស្រែ) 98

2.18 តាំងពីពេលដែលអ្នកបានក្លាយជាជនពិការ (ឬតាំងពីមានជនពិកានៅក្នុងក្រុមគ្រួសាររបស់អ្នក ) តើទិន្នផលស្រូវដែលបានប្រមូល ជាធម្មតា បានកើន ឬបានថយចុះ ឬនៅដដែលដូចមុន?

| | |
|---|---|
| ទិន្នផលស្រូវបានកើន | 1 |
| ទិន្នផលស្រូវបានថយចុះ | 2 |
| ទិន្នផលស្រូវនៅដដែល | 3 |
| ជនពិការនៅក្នុងគ្រួសារបានទទួលរងពិការភាព អស់ រយៈពេលជាង ១៥ ឆ្នាំ | 4 |
| N/A (គ្រួសារមិនបានធ្វើស្រែ) | 98 |

2.19 តាំងពីអ្នកបានក្លាយជាជនពិការ (ឬតាំងពីមានជនពិការនៅក្នុងក្រុមគ្រួសាររបស់អ្នក) តើប្រាក់ចំណូលជារួមក្នុងគ្រួសាររបស់អ្នកបានកើន បានថយចុះ ឬនៅដដែល?

| | |
|---|---|
| ប្រាក់ចំណូលបានកើនឡើង | 1 |
| ប្រាក់ចំណូលបានថយចុះ | 2 |
| ប្រាក់ចំណូលនៅដដែល | 3 |
| ជនពិការនៅក្នុងគ្រួសារបានទទួលរងពិការភាព អស់ រយៈពេលជាង ១៥ ឆ្នាំ | 4 |

**យុទ្ធសាស្ត្រចិញ្ចឹមជីវិត:**

3.01 តើជនពិការនៅក្នុងក្រុមគ្រួសាររបស់អ្នក បានចូលរួមជួយធ្វើស្រែកាលពីឆ្នាំមុននេះឬទេ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| ទេ (ក្មេងក្រោមអាយុ១៥ឆ្នាំ) | 3 |
| N/A (គ្រួសារមិនធ្វើស្រែ) | 98 |

3.02 បើបាទ ឬចាស តើការងារអ្វីដែលជនពិការបានជួយធ្វើ នៅពេលធ្វើស្រែកាលពីឆ្នាំមុននេះទេ ? (សូមមេត្តាគូសចំលើយលើសពីមួយ បើសមស្រប)

| | |
|---|---|
| a. ភ្ជួរ | b. រាស់ |
| c. ព្រោះស្រូវ | d. ដកសំណាប |
| e. ស្ទូង | f. បាចជីដាក់ស្រែ |
| g. ដកស្មៅ | h. ច្រូតកាត់ |
| i. បោកបែនស្រូវ | j. ជញ្ជូនស្រូវពីស្រែទៅផ្ទះ |
| k. លើកភ្លឺស្រែ | |

3.03 តើគ្រួសាររបស់អ្នក មានដាំបន្លែ និងដាំដំណាំផ្សេងៗទៀតទេ (បន្លែ អំពៅ ។ល។) ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |

3.04 បើបាទ ឬចាស តើជនពិការនៅក្នុងគ្រួសារបានជួយឬទេ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| ទេ (ក្មេងក្រោមអាយុ១៥ឆ្នាំ) | 3 |
| N/A | 98 |

3.05 តើគ្រួសាររបស់អ្នក មានចញ្ចឹមមាន់ ឬទាទេ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |

3.06 បើបាទ ឬចាស តើជនពិការនៅក្នុងគ្រួសារបានជួយចិញ្ចឹមមាន់ ឬទាឬទេ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| ទេ (ក្មេងក្រោមអាយុ១៥ឆ្នាំ) | 3 |
| N/A | 98 |

3.07 តើគ្រួសាររបស់អ្នក មានចញ្ចឹមជ្រូកទេ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |

3.08 បើបាទ ឬចាស តើជនពិការនៅក្នុងគ្រួសាររបស់អ្នកបានជួយចិញ្ចឹមជ្រូកទេ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| ទេ ( ក្មេងក្រោមអាយុ១៥ឆ្នាំ) | 3 |
| N/A | 98 |

3.09 តើគ្រួសាររបស់អ្នក ធ្វើការនេសាទត្រីឬទេ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |

3.10 បើបាទ ឬចាស តើជនពិការនៅក្នុងគ្រួសាររបស់អ្នកបានជួយនេសាទត្រីឬទេ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| ទេ ( ក្មេងក្រោមអាយុ១៥ឆ្នាំ ) | 3 |
| N/A | 98 |

3.11 តើក្រុមគ្រួសារអស់លោកអ្នករកស្បៀងផ្សេងៗពីស្រះទឹក វាលស្រែ ឬពីព្រៃ (ឧទាហរណ៍ កង្កែប កណ្តុរ ត្រកួន បន្លែព្រៃ និងផ្លែឈើ) ឬទេ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |

3.12 បើបាទ ឬចាស តើជនពិការនៅក្នុងគ្រួសាររបស់អ្នកបានជួយរកម្ហូបពីស្រះទឹក វាលស្រែ ឬពីព្រៃ (ឧទាហរណ៍ កង្កែប កណ្តុរ ត្រកួន បន្លែពីព្រៃ និងផ្លែឈើ) ទេ? ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| ទេ ( ក្មេងក្រោមអាយុ១៥ឆ្នាំ) | 3 |
| N/A | 98 |

3.13 តើក្រុមគ្រួសារអស់លោកអ្នកមានផលិតទំនិញដើម្បីដាក់លក់អោយអ្នកដទៃ (ឧទាហរណ៍ ល្អី វត្ថុធ្វើដោយដៃ ស្រាស និងធ្យូង ។ល។ ឬទេ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |

3.14 បើបាទ ឬចាស តើជនពិការនៅក្នុងគ្រួសាររបស់អ្នកបានជួយផលិតទំនិញដើម្បី ដាក់លក់អោយអ្នកដទៃឬទេ (ឧទាហរណ៍ ល្អី វត្ថុធ្វើដោយដៃ ស្រាស និងធ្យូង ។ល។ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| ទេ (ក្មេងក្រោមអាយុ១៥ឆ្នាំ) | 3 |
| N/A | 98 |

3.15 តើក្រុមគ្រួសាររបស់អ្នកមានប្រកបរបររកស៊ីបន្តិចបន្តួចទេ (ឧទាហរណ៍: ទិញ និងលក់ទំនិញ តូបចាប់ហួយ ជួសជុលកង់ ឬម៉ូតូ ។ល។) ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |

3.16 បើបាទ ឬចាស តើជនពិការនៅក្នុងគ្រួសារអស់លោកអ្នកបានជួយក្នុងមុខរបររកស៊ីនេះទេ (ឧទាហរណ៍: ទិញ និងលក់ទំនិញ តូបចាប់ហួយ ជួសជុលកង់ ឬម៉ូតូ ។ល។) ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| ទេ (ក្មេងក្រោមអាយុ១៥ឆ្នាំ) | 3 |
| N/A | 98 |

3.17 តើគ្រួសាររបស់អ្នកបានរកប្រាក់ចំណូលតាមរយៈការស៊ីឈ្នួលនៅតាមភូមិឬទេ (ឧទាហរណ៍: ស៊ីឈ្នួលស្ទូងដក សង់ផ្ទះ ។ល។)?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |

3.18 បើបាទ ឬចាស តើជនពិការនៅក្នុងគ្រួសាររបស់អ្នក បានជួយរកប្រាក់ចំណូល តាមរយៈ ការស៊ីឈ្នួលនៅតាមភូមិឬទេ (ឧទាហរណ៍ៈ ស៊ីឈ្នួលស្ទូងដក សង់ផ្ទះ ។ល។)?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| ទេ (ក្មេងក្រោមអាយុ១៥ឆ្នាំ) | 3 |
| N/A | 98 |

3.19 តើគ្រួសាររបស់អ្នករកប្រាក់ចំណូល ដោយចំណាកស្រុកទៅក្រៅភូមិ ដែលមានរយៈពេលច្រើនជាងមួយអាទិត្យទេ? (ឧទាហរណ៍ៈ ស៊ីឈ្នួលស្ទូងដក ការងារសំណង់ ការងារកាត់ដេរ ។ល។)

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |

3.20 បើបាទ ឬចាស តើក្រុមគ្រួសាររបស់អ្នក បានរកប្រាក់ចំណូលដោយការងារចំណាកស្រុក នៅ ឯណា ? (សូមមេត្តាគូសចំលើយលើសពីមួយ បើសមស្រប)

a. ខេត្តព្រៃវែង

b. ខេត្តផ្សេងៗទៀតនៅស្រុកខ្មែរ

c. ភ្នំពេញ

d. វៀតណាម

e. ប្រទេសថៃ

f. ផ្សេងៗ (សូមបញ្ជាក់.............................)

3.21 បើបាទ ឬចាស តើជនពិការនៅក្នុងក្រុមគ្រួសាររបស់អ្នករកប្រាក់ចំណូលដោយចំណាកស្រុកនៅក្រៅភូមិដែលមានរយៈពេលច្រើនជាងមួយអាទិត្យឬទេ? (ឧទាហរណ៍ៈ ស៊ីឈ្នួលស្ទូងដក ការងារសំណង់ ការងារកាត់ដេរ ។ល។)

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| ទេ (ក្មេងក្រោមអាយុ១៥ឆ្នាំ) | 3 |
| N/A | 98 |

3.22 បើបាទ ឬចាស តើជនពិការនៅក្នុងក្រុមគ្រួសាររបស់អ្នកបានរកប្រាក់ចំណូលដោយចំណាកស្រុក នៅឯណា ? (សូមមេត្តាគូសចំលើយលើសពីមួយ បើសមស្រប)

a. ខេត្តព្រៃវែង

b. ខេត្តផ្សេងៗទៀតនៅស្រុកខ្មែរ

c. ភ្នំពេញ

d. វៀតណាម

e. ប្រទេសថៃ

f. ផ្សេងៗ (សូមបញ្ជាក់.............................)

3.23 តើជនពិការក្នុងគ្រួសាររបស់អ្នក បានជួយធ្វើការងារផ្សេងៗដូចខាងក្រោម សំរាប់គ្រួសារឬទេ? ((សូមមេត្តាគូសចំលើយលើសពីមួយ បើសមស្រប)

a. ជួយថែទាំក្មេងៗនៅក្នុងគ្រួសារ

b. ជួយថែទាំមនុស្សចាស់នៅក្នុងគ្រួសារ

c. ជួយចំអិនអាហារ

d. ជួយសំអាតផ្ទះ

e. ជួយបោកអ៊ុត

f. ជួយដងទឹក

g. ផ្សេងៗ (សូមបញ្ជាក់................................)

3.24 តើមានសមាជិកគ្រួសារគ្រប់គ្រាន់ក្នុងការជួយរកចំណូលដើម្បីផ្គត់ផ្គង់គ្រួសារឬទេ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |

3.25 តើការចំណាយពេលមើលថែទាំអ្នកពិការនៅក្នុងគ្រួសារ បានធ្វើអោយមានការបាត់បង់លទ្ធភាព ច្រើន ក្នុងការរកចំណូលដើម្បីផ្គត់ផ្គង់គ្រួសារឬទេ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |

## ការចូលរួម និងការរើសអើងនៅនៅក្នុងសង្គមៈ

*ការរើសអើង*

4.01 តើជនពិការក្នុងក្រុមគ្រួសាររបស់អ្នក ត្រូវបានគេហៅឈ្មោះតាមប្រភេទនៃពិការភាពរបស់គាត់/នាងទេ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |

4.02 បើបាទ ឬចាស តើអ្នកហៅនោះជាអ្នកណា ?(សូមមេត្តាគូសចំលើយលើសពីមួយ បើសមស្រប)

a. សមាជិកក្រុមគ្រួសារ
b. មិត្តភក្តិ
c. សិស្សរួមថ្នាក់
d. អ្នកជិតខាង
e. ជនចំឡែក

4.03 តើជនពិការនៅក្នុងគ្រួសាររបស់អ្នកធ្លាប់មានបទពិសោធន៏ ដែលអ្នកផ្សេងធ្វើជាកំប្លែងលេង ដោយការធ្វើត្រាប់តាមរបៀបដែលគេដើរ និយាយស្តី ឬផ្លាស់ទី ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |

4.04 បើបាទឬចាស តើនរណាជអ្នកធ្វើជាកំប្លែងលេង ដោយការធ្វើត្រាប់តាម របៀបដែលជនពិការដើរ និយាយស្តី ឬផ្លាស់ទី ? (សូមមេត្តាគូសចំលើយលើសពីមួយ បើសមស្រប)

a. សមាជិកក្រុមគ្រួសារ
b. មិត្តភក្តិ
c. សិស្សរួមថ្នាក់
d. អ្នកជិតខាង
e. ជនចំឡែក

4.05 តើជនពិការនៅក្នុងគ្រួសារធ្លាប់មានការពិបាកក្នុងការជ្រើសរើសគូស្រករ ដោយសារតែក្រុមគ្រួសារ របស់ខ្លួន ឬគ្រួសារខាងអនាគតភរិយាឬទេ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| N/A (អាយុមិនទាន់ គ្រប់ ការ ) | 98 |

4.06 តើជនពិការនៅក្នុងគ្រួសាររបស់អ្នក ធ្លាប់ត្រូវបានគេបដិសេធនីមិនអោយចូលរៀននៅសាលា ឬទេ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| N/A (អាយុមិនទាន់ អាចចូលរៀន) | 98 |

4.07 តើជនពិការនៅក្នុងគ្រួសាររបស់អ្នក ធ្លាប់ត្រូវបានគេមិនផ្តល់ការងារធ្វើ ដោយសារគាត់ជាជនពិការឬទេ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| N/A (អាយុក្រោម ១៥ឆ្នាំ) | 98 |

4.08 តើជនពិការត្រូវបានគេបដិសេធនីមិនអោយបោះឆ្នោត ដោយសារតែពិការភាពរបស់គាត់/នាងទេ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| N/A (ក្រោមអាយុមិនអាចបោះឆ្នោត) | 98 |

## *ការប្រាស្រ័យទាក់ទងគ្នាក្នុងសង្គម:*

4.09 តើសមាជិកគ្រួសារ ឬសាច់ញាតិដែលរស់នៅក្រៅរង្វង់គ្រួសារ មកលេងជនពិការញឹកញាប់ទេ?

| | |
|---|---|
| ញឹកញាប់ | 1 |
| យូរៗម្តង | 2 |
| មិនដែលសោះ | 3 |

4.10 តើទៅជនពិការទៅលេងសមាជិកគ្រួសារ ឬសាច់ញាតិដែលរស់នៅក្រៅរង្វង់គ្រួសារ ញឹកញាប់ទេ?

| | |
|---|---|
| ញឹកញាប់ | 1 |
| យូរៗម្តង | 2 |
| មិនដែលសោះ | 3 |

4.11 តើ មិត្តភក្តិ មកលេងជនពិការញឹកញាប់ទេ?

| | |
|---|---|
| ញឹកញាប់ | 1 |
| យូរៗម្តង | 2 |
| មិនដែលសោះ | 3 |

4.12 តើជនពិការទៅលេងមិត្តភក្តិ ញឹកញាប់ទេ?

| | |
|---|---|
| ញឹកញាប់ | 1 |
| យូរៗម្តង | 2 |
| មិនដែលសោះ | 3 |

4.13 តើ អ្នកជិតខាង មកលេងជនពិការញឹកញាប់ទេ?

| | |
|---|---|
| ញឹកញាប់ | 1 |
| យូរៗម្តង | 2 |
| មិនដែលសោះ | 3 |

4.14 តើ ជនពិការទៅលេងអ្នកជិតខាង ញឹកញាប់ទេ?

| | |
|---|---|
| ញឹកញាប់ | 1 |
| យូរៗម្តង | 2 |
| មិនដែលសោះ | 3 |

4.15 តើអ្នកធ្វើការឬមន្ត្រីរដ្ឋាភិបាល (គ្រូបង្រៀន អ្នកធ្វើការថែទាំសុខភាព អាជ្ញាធរមូលដ្ឋាន ។ល។) មកលេងជនពិការញឹកញាប់ទេ?

| | |
|---|---|
| ញឹកញាប់ | 1 |
| យូរៗម្តង | 2 |
| មិនដែលសោះ | 3 |

4.16 តើជនពិការទៅជួបអ្នកធ្វើការ ឬមន្ត្រីរដ្ឋាភិបាល (គ្រូបង្រៀន អ្នកធ្វើការថែទាំសុខភាព អាជ្ញាធរមូលដ្ឋាន ។ល។) ញឹកញាប់ទេ?

| | |
|---|---|
| ញឹកញាប់ | 1 |
| យូរៗម្តង | 2 |
| មិនដែលសោះ | 3 |

4.17 តើបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល មកលេងជនពិការញឹកញាប់ទេ?

| | |
|---|---|
| ញឹកញាប់ | 1 |
| យូរៗម្តង | 2 |
| មិនដែលសោះ | 3 |

4.18 តើជនពិការទៅជួបបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ញឹកញាប់ទេ?

| | |
|---|---|
| ញឹកញាប់ | 1 |
| យូរៗម្តង | 2 |
| មិនដែលសោះ | 3 |

## *<u>ការចូលរួមក្នុងពិធីបុណ្យផ្សេងៗក្នុងសហគមន៍</u>*

4.19 តើជនពិការ ចូលរួមនៅក្នុងពិធីបុណ្យតាមសហគមន៍ដូចតទៅនេះទេ? (សូមមេត្តាគូសចំលើយ លើសពីមួយ បើសមស្រប)

a. ពិធីតាមសាលា

b. ពិធីបុណ្យតាមវត្ត (បុណ្យភ្ជុំបិណ្ឌ ចូលឆ្នាំខ្មែរ)

c. ពិធីរៀបការ

d. ពិធីបុណ្យសព

4.20 បើជនពិការមិនបានចូលរួមនៅក្នុងពិធីនៅតាមសហគមន៍ដូចតទៅនេះ តើមានមូលហេតុអ្វីខ្លះ? (សូមមេត្តាគូសចំលើយ លើសពីមួយ បើសមស្រប)

a. ជនពិការគឺនៅក្មេងពេកដើម្បីចូលរួម

b. ជនពិការគឺមានរូបរាងកាយដែលមិនអាចចូលរួមបាន

c. ជនពិការគឺមិនត្រូវបានគេអញ្ជើញ ឬលើកទឹកចិត្តអោយចូលរួមទេ

d. ជនពិការគឺត្រូវបានគ្រួសារមិនបានអនុញ្ញាតិអោយចូលរួម

e. ជនពិការមានការខ្មាស់អៀនពេកដើម្បីចូលរួម

4.21 តើជនពិការបានចូលរួមនៅក្នុងសកម្មភាពណាមួយ នៃសកម្មភាពអភិវឌ្ឍន៍ដូចតទៅនេះទេ ? (សូមមេត្តាគូសចំលើយលើសពីមួយ បើសមស្រប)

a. គំរោងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់

b. ការងារស្បៀងពលកម្ម (ឧទាហរណ៏: ការកសាងផ្លូវ សាលារៀន លូទឹក ។ល។

c. ការងារអភិវឌ្ឍន៏របស់អង្គការក្រៅរដ្ឋាភិបាល (ឧទាហរណ៏: ក្រុមសន្សំ និងឥណទាន ធនាគារស្រូវ ធនាគាសត្វ ក្រុមអ្នកប្រើអណ្តូង ។ល ។)

d. សមាគមភូមិ (ក្រុមចានឆ្នាំង ក្រុមឥណទាន និងគណ:កម្មាធិការវត្ត)

4.22 បើជនពិការមិនបានចូលរួមនៅក្នុងសកម្មភាពអភិវឌ្ឍន៍ទាំងនេះ តើមានមូលហេតុអ្វីខ្លះ? (សូមមេត្តាគូសចំលើយលើសពីមួយ បើសមស្រប)

a. ជនពិការគឺនៅក្មេងពេកដើម្បីចូលរួម

b. ជនពិការគឺមានរូបរាងកាយដែលមិនអាចចូលរួមបាន

c. ជនពិការគឺមិនត្រូវបានគេអញ្ជើញ ឬលើកទឹកចិតអោយចូលរួមទេ

d. ជនពិការគឺត្រូវបានគ្រួសារមិនបានអនុញ្ញាតិអោយចូលរួម

e. ជនពិការមានការខ្មាស់អៀនពេកដើម្បីចូលរួម

4.23 តើជនពិការបានចូលរួមនៅក្នុងការបោះឆ្នោតដូចតទៅនេះទេ? (សូមគូសចំលើយលើសពីមួយ បើសមស្រប)

a. ការបោះឆ្នោតជាតិឆ្នាំ 2003

b. ការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ ឆ្នាំ 2002

c. ការបោះឆ្នោតជាតិឆ្នាំ 1998

4.24 បើជនពិការមិនបានចូលរួមការបោះឆ្នោតទាំងពីរលើកនេះ តើមានមូលហេតុអ្វីខ្លះ?(សូមមេត្តាគូសចំលើយលើសពីមួយ បើសមស្រប)

a. ជនពិការគឺនៅក្មេងពេកដើម្បីចូលរួម

b. ជនពិការគឺមានរូបរាងកាយដែលមិនអាចចូលរួមបាន

c. ជនពិការគឺមិនត្រូវបានគេអញ្ជើញ ឬលើកទឹកចិតអោយចូលរួមទេ

d. ជនពិការគឺត្រូវបានគ្រួសារមិនបានអនុញ្ញាតិអោយចូលរួម

e. ជនពិការមានការខ្មាស់អៀនពេកដើម្បីចូលរួម

f. គ្មានអត្តសញ្ញាណប័ន

4.25 តើជនពិការក្នុងគ្រួសារធ្លាប់បានចូលរួមក្នុងសកម្មភាពកីឡាឬទេ ( បាល់ទះ បាល់បោះ បាល់ទាត់ ) ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |

## *<u>ការជួយឧបត្ថម្ភ និងសេវាកម្មផ្សេងៗ</u>*

5.01 តើជនពិការ (ឬសមាជិកនៃគ្រួសារពិការ)ដឹងថា មានអង្គការ **វីអាយ** ផ្តល់ការព្យាបាលធ្វើអោយរូបរាងកាយប្រសើរឡើង ដោយមិនយកកំរៃ នៅទីរួមខេត្តព្រៃវែងនេះ ទេ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |

5.02 បើមិនដឹងទេ តើជនពិការ (ឬសមាជិកនៃគ្រួសារពិការ) ចង់រៀនសូត្រថែមទៀតអំពីកម្មវិធីការព្យាបាលធ្វើអោយរូបរាងកាយប្រសើរឡើង របស់អង្គការ **វីអាយ** ឬទេ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| N/A ( ដោយសសារដឹងពីកម្មវិធីអង្គការនេះ) | 98 |

5.03 តើជនពិការនៅក្នុងគ្រួសារបានទទួលជំនួយអ្វី ចំពោះពិការភាពរាងកាយឬទេ ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |

5.04 បើបាទ ឬ ចាស តើនរណាជាអ្នកជួយ ? ( សូមមេត្តាគូសចំលើយលើសពីមួយ បើសមស្រប)

a. អង្គការអតីតយុទ្ធជនអន្តរជាតិ (វីអាយ)

b. អង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត ( សូមបញ្ជាក់ ............................)

c. ក្រសួង/មន្ទីរសង្គមកិច្ច

d. ក្រសួង/មន្ទីរសុខាភិបាល ( មជ្ឈមណ្ឌលសុខភាពរបស់រដ្ឋាភិបាល)

e. ក្រសួង/មន្ទីរកសិកម្ម

f. កាកបាទក្រហមកម្ពុជា

g. អង្គការជនពិការ

h. សប្បុរសជន

i. ផ្សេងៗ ( សូមបញ្ជាក់)...........................

5.05 បើបាទ ឬចាស តើប្រភេទនៃជំនួយបែបណា ដែលជនពិការបានទទួល ? ( សូមមេត្តាគូសចំលើយលើសពីមួយ បើសមស្រប)

| | |
|---|---|
| a. ជើងសិប្បនិមិត្ត | b. ដៃសិប្បនិមិត្ត |
| c.ឈើច្រត់ | d.រណប |
| e.រទេះ | f. ព្យាបាលដោយចលនា |
| g. ព្យាលបាលដោយប្រើថ្នាំពេទ្យ | h. ប្រដាប់ទប់ហើយដើរ |
| i. ជួយបណ្តុះបណ្តាលនៅថ្នាក់បឋមសិក្សា | j. បណ្តុះបណ្តាលវិជ្ជាជីវៈ |
| k. បណ្តុះបណ្តាលកីឡា | l. បណ្តុះបណ្តាលសិទ្ធិមនុស្ស |
| m.. ធនធានកសិកម្ម ( គ្រាប់ពូជ ....) | n. សម្ភារៈសង្គ្រោះបន្ទាន់ |
| o. ជំនួយជាវត្ថុ ឬរបស់របរ ( កង់ គោ និងសំភារៈសិក្សា) | p. ផ្សេងៗ ( សូមបញ្ជាក់........) |

5.06 បើបាទ ឬចាស តើនៅឆ្នាំណាដែលជនពិការបានទទួលជំនួយឧបត្ថម្ភដំបូង ?

សូមសរសេរឆ្នាំ ...............
NA..........................98

5.07 បើបាទ ឬចាស តើមានរយៈពេលប៉ុន្មានឆ្នាំ ដែលជនពិការបានទទួលជំនួយឧបត្ថម្ភ?

សូមសរសេរចំនួនឆ្នាំ ........
NA..........................98

5.08 បើបាទ ឬចាស តើជនពិការនៅបន្តទទួលជំនួយបន្តទៀតទេ រហូតដល់សព្វថ្ងៃនេះ ?

បាទ ឬចាស 1
ទេ 2
NA..........................98

5.09 បើបាទ ឬចាស តើនរណានៅបន្តផ្តល់ជំនួយឧបត្ថម្ភរហូតដល់ពេលនេះ? (សូមគូសចំលើយលើសពីមួយ)

a. អង្គការអតីតយុទ្ធជនអន្តរជាតិ (វីអាយ)

b. អង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត (សូមបញ្ជាក់ ...................)

c. ក្រសួង/មន្ទីរសង្គមកិច្ច

d. ក្រសួង/មន្ទីរសុខាភិបាល (មជ្ឈមណ្ឌលសុខភាពរបស់រដ្ឋាភិបាល)

e. ក្រសួង/មន្ទីរកសិកម្ម

f. កាកបាទក្រហមកម្ពុជា

g. អង្គការជនពិការ

h. សប្បុរសជន

i. ផ្សេងៗ (សូមបញ្ជាក់)............................

5.10 បើបាទ ឬចាស តើជាទូទៅជំនួយឧបត្ថម្ភនោះមានប្រយោជន៍យ៉ាងណាខ្លះ?

| | |
|---|---|
| មានប្រយោជន៍ណាស់ | 1 |
| មិនសូវមានប្រយោជន៍ | 2 |
| មិនមានប្រយោជន៍ទេ | 3 |

5.11 តើគ្រួសារដែលមានជនពិការធ្លាប់បានខ្ចីលុយគេ ដើម្បីបង់ថ្លៃសុខភាព ឬថ្លៃព្យាបាលសំរាប់ជនពិការនៅក្នុងគ្រួសារទេ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |

5.12 បើបាទ ឬចាស តើគ្រួសារដែលមានជនពិការ មានលទ្ធភាពសងប្រាក់កំចីទាំងនេះទេ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |
| N/A (មិនដែលខ្ចីលុយបង់ថ្លៃសុខភាពជនពិការទេ) | 98 |

5.13 តើគ្រួសារដែលមានជនពិការធ្លាប់លក់ទ្រព្យសម្បត្តិផ្សេងៗទៀតក្រៅពីលក់ដី (ឧទាហរណ៍: គោក្របីសំរាប់ទុកធ្វើស្រែ គ្រឿងអលង្ការ ។ល។) ដើម្បីបង់ថ្លៃសុខភាព ឬថ្លៃព្យាបាលសំរាប់ជនពិការនៅក្នុងគ្រួសារទេ?

| | |
|---|---|
| បាទ ឬ ចាស | 1 |
| ទេ | 2 |

## ឧបសម្ព័ន្ធទី ២: ឈ្មោះសិក្ខាកាម និងក្រុមអេឌីអាយ
## ក្រុមសិក្ខាកាមស្រាវជ្រាវ (ជំនាន់ទី ១៦)

| | |
|---|---|
| Huoy Socheat | Association for Aid and Relief - Japan |
| Luy Bunthan | Save the Children Australia |
| Khin Mab | Lutheran World Federation |
| Ros Ra | Lutheran World Federation |
| Kim Sovya | Lutheran World Federation |
| Yim Mean | Lutheran World Federation |
| San Sochea | Cambodia Protection of Rights of Women and Children Association |
| Nit Pengsreang | Violence Against Women and Children of Cambodia |
| Leng Thy | Ponleu Ney Kdey Sangkum |
| Sobun Chenda | Association for Development and Our Village Rights |
| Suong Sopheap | Kumnit Thmey Organization |
| Kheiv Sokunthea | Hope and Development |
| Chea Sok Hoeun | Sor Sor Troung |
| Kim Sokhom | Khmer Women's Voice Center |
| Vorng Chantha | Indradavi |

## ក្រុមអេឌីអាយ **(ADI Team Researchers)**

| | |
|---|---|
| Ang Sopha | Cooperation Committee for Cambodia/ADI Project |
| Oeur Il | Cooperation Committee for Cambodia/ADI Project |
| Kung Seakly | Cooperation Committee for Cambodia/ADI Project |
| John McAndrew | Cooperation Committee for Cambodia/ADI Project |

# ឯកសារស្រាវជ្រាវរបស់គំរោងអេឌីអាយ

- ផលប៉ះពាល់នៃឧស្សាហកម្មកាត់ដេរទៅលើជីវភាពរស់នៅ នៅតំបន់ជនបទៈ បទពិសោធន៍ដែលទទួលបានពីកម្មករកាត់ដេរ និង គ្រួសារនៅតំបន់ជនបទ ក្នុងខេត្តព្រៃវែង ខែ តុលា ២០០៥

- អំពើហិង្សាក្នុងគ្រួសារនៅក្នុងតំបន់តាំងទីលំនៅថ្មីតាមជាយដែន នៅប៉ោយប៉ែតដែលមានកំណើនមនុស្សយ៉ាងឆាប់រហ័សៈ ការស្រាវជ្រាវនៅក្នុងភូមិពីរ ក្នុងឃុំប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ខែ ឧសភា ២០០៥

- ការលើកកំពស់ក្នុងការប្រើប្រាស់ធនធានធម្មជាតិរបស់ជនជាតិដើមភាគតិច នៅភាគឦសាននៃប្រទេសកម្ពុជា ខែ ធ្នូ ២០០៤

- ការឆ្លើយតបរបស់ជនជាតិដើមភាគតិច ទៅនឹងការថយចុះនៃធនធានធម្មជាតិៈ ការសិក្សាស្រាវជ្រាវនៅក្នុងភូមិពីររបស់ជនជាតិស្ទៀង នៅស្រុកស្នួល ខេត្តក្រចេះ ខែ កញ្ញា ២០០៤

- ការប្រើប្រាស់គ្រឿងញៀនជាបញ្ហាសង្គមៈ ទស្សនៈរបស់ប្រជាជននៅក្នុងភូមិបី នៅជាយក្រុងបាត់ដំបង ខែមេសា ២០០៤

- បទពិសោធន៍របស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ក្នុងការលើកកំពស់អភិបាលកិច្ចមូលដ្ឋានដោយមានការចូលរួមៈ ករណីសិក្សារបស់ឃុំ/សង្កាត់ចំនួនប្រាំនៅក្នុងប្រទេសកម្ពុជា ខែ មីនា ២០០៤

- ការចេញទៅប្រកបការងារនៅប្រទេសថៃ និងព្រំដែនកម្ពុជា-ថៃៈ និន្នាការនាពេលបច្ចុប្បន្ន នៅភូមិចំនួន៤ ក្នុងខេត្តបាត់ដំបង ខែ ធ្នូ ២០០៣

- ផលប៉ះពាល់នៃឧស្សាហកម្មទេសចរណ៍មកលើជីវភាពរស់នៅរបស់ប្រជាជន នៅតំបន់ឧទ្យានអង្គរ ខែ ធ្នូ ២០០២

- ការសិក្សាស្រាវជ្រាវទ្រង់ទ្រាយតូច ស្តីពីការបែងចែកដីធ្លី នៅប្រទេសកម្ពុជាៈ ចំនុចសំខាន់៧ដែលទទួលបានពីករណីសិក្សាចំនួនបី ខែ វិច្ឆិកា ២០០១